# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤



**វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ**

សហការជាមួយ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

គាំទ្របច្ចេកទេសដោយ៖

អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ

គាំទ្រហិរញ្ញវត្ថុដោយ៖ គំនិតផ្តួចផ្តើម ៥០x២០៣០

# មាតិកា


បុព្វកថា........................................................................vii
អារម្ភកថា........................................................................ix
អក្សរកាត់........................................................................x
**ផ្នែកទី១៖ វិធីសាស្ត្រអង្កេត ........................................................១**
របាយការណ៍សម្ព័ន្ធរបាយការណ៍........................................................៣
សេចក្ដីសង្ខេប ........................................................................៥
ទំហំ វិសាលភាព និងការជ្រើសរើសសំណាកគំរូ........................................១៤
**ផ្នែកទី២៖ ផលិតកម្មដំណាំ........................................................២៥**
ផ្ទៃដីកសិកម្ម........................................................................២៦
ផលិតកម្មដំណាំ ........................................................................២៩
ដំណាំរយៈពេលខ្លី........................................................................៣០
ដំណាំរយៈពេលវែង ........................................................................៣៦
**ផ្នែកទី៣៖ ការចិញ្ចឹមបសុសត្វ និងបសុបក្សី ........................................៤៨**
ការចិញ្ចឹមបសុសត្វ និងបសុបក្សី ........................................................៤៩
បសុសត្វប្រភេទធំ ........................................................................៥០
បសុសត្វប្រភេទតូច ........................................................................៥៥
បសុបក្សី........................................................................៥៨
**ផ្នែកទី៤៖ វារីវប្បកម្ម និងការនេសាទ........................................................៦៧**
វារីវប្បកម្ម និងការនេសាទ ........................................................................៦៨
វារីវប្បកម្ម........................................................................៦៩
ការនេសាទ ........................................................................៧១
**ផ្នែកទី៥៖ សកម្មភាពសេដ្ឋកិច្ច........................................................៧៥**
គ្រឿងម៉ាស៊ីន និងឧបករណ៍សម្ភារបរិក្ខារកសិកម្ម........................................៧៦
ការប្រើប្រាស់គ្រឿងម៉ាស៊ីន និងឧបករណ៍សម្ភារបរិក្ខារកសិកម្ម........................៧៧
កន្លែងរក្សាទុក........................................................................៨៥
សកម្មភាពសេដ្ឋកិច្ច ........................................................................៨៨
គ្រោះហានិភ័យ ........................................................................៩៦

# តារាងទិន្នន័យ រូបភាព និងផែនទីទិន្នន័យ

## រូបភាពទិន្នន័យ


- រូបភាព២.១ ផ្ទៃដីកសិកម្មសរុប តាមប្រភេទទំហំ និងតំបន់ ឆ្នាំ២០២៤ ២៧
- រូបភាព២.២ ផ្ទៃដីកសិកម្ម តាមចំណាត់ថ្នាក់ នៅកម្ពុជា ឆ្នាំ២០២៤ ២៧
- រូបភាព២.៣ វិធីសាស្ត្រគ្រួសារកសិកម្មទទួលបានក្បាលដីនៅកម្ពុជា ឆ្នាំ២០២៤ ២៨
- រូបភាព២.៤ ចំនួនគ្រួសារកសិកម្មដែលរាយការណ៍ពីប្រភេទដំណាំ១០មុខសំខាន់ៗនៅកម្ពុជា ឆ្នាំ២០២៤ ៣០
- រូបភាព២.៥ ផ្ទៃដីដំណាំស្រូវធម្មតា បែងចែកតាមតំបន់ គិតជាហិកតា ឆ្នាំ២០២៤ ៣១
- រូបភាព២.៦ ផ្ទៃដីដំណាំស្រូវក្រអូប បែងចែកតាមតំបន់ គិតជាហិកតា ឆ្នាំ២០២៤ ៣២
- រូបភាព២.៧ ចំនួនគ្រួសារដែលរាយការណ៍ដាំដំឡូងមី តាមតំបន់ ឆ្នាំ២០២៤ ៣៤
- រូបភាព២.៨ ចំនួនគ្រួសារដែលរាយការណ៍ដាំអំពៅ តាមតំបន់ ឆ្នាំ២០២៤ ៣៥
- រូបភាព២.៩ ចំនួនគ្រួសារកសិកម្ម ដាំបន្លែមានផ្លែ តាមប្រភេទដំណាំ នៅកម្ពុជា ឆ្នាំ២០២៤ ៣៦
- រូបភាព២.១០ ចំនួនគ្រួសារកសិកម្មដាំដំណាំផ្លែឈើ តាមប្រភេទដំណាំ នៅកម្ពុជា ឆ្នាំ២០២៤ ៣៧
- រូបភាព២.១១ ចំនួនគ្រួសារដាំដំណាំស្វាយ បែងចែកតាមតំបន់ ឆ្នាំ២០២៤ ៣៧
- រូបភាព ២.១២ ផ្ទៃដីដាំដំណាំចេក បែងចែកតាមតំបន់ គិតជាហិកតា ឆ្នាំ២០២៤ ៣៨
- រូបភាព២.១៣ ចំនួនគ្រួសារកសិកម្មដាំដំណាំខ្នុរ តាមតំបន់ ឆ្នាំ២០២៤ ៣៩
- រូបភាព២.១៤ ចំនួនគ្រួសារកសិកម្មដាំដំណាំស្វាយចន្ទី តាមតំបន់ ឆ្នាំ២០២៤ ៤០
- រូបភាព២.១៥ ផ្ទៃដីដាំដំណាំដូង បែងចែកតាមតំបន់ គិតជាហិកតា ឆ្នាំ២០២៤ ៤០
- រូបភាព៣.១ ចំនួនគ្រួសារកសិកម្មដែលចិញ្ចឹមបសុសត្វ បសុបក្សី តាមតំបន់ ឆ្នាំ២០២៤ ៤៩
- រូបភាព៣.២ ចំនួនគ្រួសារកសិកម្មចិញ្ចឹមគោ និងចំនួនគោ បែងចែកតាមតំបន់ ឆ្នាំ២០២៤ ៥១
- រូបភាព៣.៣ ចំនួនគ្រួសារកសិកម្មចិញ្ចឹមគោបែងចែកតាមហ្វូង កម្ពុជា ឆ្នាំ២០២៤ ៥១
- រូបភាព៣.៤ ចំនួនគោ បែងចែងតាម អាយុ ភេទ កម្ពុជា ឆ្នាំ២០២៤ ៥២
- រូបភាព៣.៥ ចំនួនគោរ បានកើត និងទិញ គិតតាមតំបន់ ឆ្នាំ២០២៤ ៥២
- រូបភាព៣.៦ ចំនួនបម្រែបម្រួលសត្វគោ កម្ពុជា ឆ្នាំ២០២៤ ៥៣
- រូបភាព៣.៧ ចំនួនគ្រួសារ និងចំនួនសត្វក្របីបែងចែកតាមតំបន់ ឆ្នាំ២០២៤ ៥៤
- រូបភាព៣.៨ ចំនួនគ្រួសារកសិកម្មចិញ្ចឹមក្របី បែងចែកតាមចំនួនហ្វូង កម្ពុជា ឆ្នាំ២០២៤ ៥៥
- រូបភាព៣.៩ ចំនួនសត្វក្របី បែងចែកតាម អាយុ ភេទ កម្ពុជា ឆ្នាំ២០២៤ ៥៥
- រូបភាព៣.១០ ចំនួនគ្រួសារចិញ្ចឹមជ្រូក និងចំនួនជ្រូកបែងចែកតាមតំបន់ ឆ្នាំ២០២៤ ៥៦
- រូបភាព៣.១១ ចំនួនគ្រួសារកសិកម្មចិញ្ចឹមជ្រូក បែងចែកតាមចំនួនជ្រូក កម្ពុជា ឆ្នាំ២០២៤ ៥៦
- រូបភាព៣.១២ ចំនួនសត្វជ្រូក បែងចែកតាមអាយុ និងភេទ កម្ពុជា ឆ្នាំ២០២៤ ៥៧
- រូបភាព៣.១៣ ចំនួនជ្រូក បានកើត និងទិញ បែងចែកតាមតំបន់ ឆ្នាំ២០២៤ ៥៧
- រូបភាព៣.១៤ ចំនួនគ្រួសារកសិកម្មចិញ្ចឹមមាន់ បែងចែកតាមតំបន់ ឆ្នាំ២០២៤ ៥៩
- រូបភាព៣.១៥ ចំនួនមាន់សរុប បែងចែកតាមតំបន់ ឆ្នាំ២០២៤ ៦០
- រូបភាព៣.១៦ ចំនួនមាន់បានកើត បែងចែកតាមតំបន់ ឆ្នាំ២០២៤ ៦០
- រូបភាព៣.១៧ បម្រែបម្រួលចំនួនមាន់ កម្ពុជា ឆ្នាំ២០២៤ ៦១
- រូបភាព៣.១៨ ចំនួនគ្រួសារកសិកម្មចិញ្ចឹមទា បែងចែកតាមតំបន់ ឆ្នាំ២០២៤ ៦២
- រូបភាព៣.១៩ ចំនួនទាសរុប បែងចែកតាមតំបន់ ឆ្នាំ២០២៤ ៦២

- រូបភាព៣.២០ ចំនួនទាបានកើត បែងចែកតាមតំបន់ ឆ្នាំ២០២៤ ៦៣
- រូបភាព៣.២១ បម្រែបម្រួលចំនួនទា កម្ពុជា ឆ្នាំ២០២៤ ៦៤
- រូបភាព៣.២២ ការអនុវត្តការផ្តល់ចំណីឱ្យសត្វរបស់គ្រួសារកសិកម្ម កម្ពុជា ឆ្នាំ២០២៤ ៦៤
- រូបភាព៣.២៣ ប្រភេទចំណីសត្វផ្តល់ឱ្យសត្វរបស់គ្រួសារកសិកម្ម កម្ពុជា ឆ្នាំ២០២៤ ៦៥
- រូបភាព៤.១ ចំនួនគ្រួសារកសិកម្មដែលរាយការណ៍អំពីសកម្មភាពវារីវប្បកម្មតាមតំបន់ ឆ្នាំ២០២៤ ៧០
- រូបភាព៤.២ ចំនួនគ្រួសារកាន់កាប់កសិកម្ម ដែលបានរាយការណ៍ពីសកម្មភាពវារីវប្បកម្ម ឆ្នាំ២០២៤ ៧០
- រូបភាព៤.៣ ចំនួនគ្រួសារកសិកម្ម ដែលរាយការណ៍អំពីសកម្មភាពនេសាទ បែងចែកតាមតំបន់ ឆ្នាំ២០២៤ ៧២
- រូបភាព៤.៤ ចំនួនគ្រួសារកាន់កាប់កសិកម្មដែលពាក់ព័ន្ធសកម្មភាពផលត្រីនេសាទនៅកម្ពុជាឆ្នាំ២០២៤(តាមប្រភេទ) ៧២
- រូបភាព៤.៥ ការប្រៀបធៀបរវាងផលនេសាទក្នុងឆ្នាំបច្ចុប្បន្នទៅឆ្នាំមុន នៃគ្រួសារកសិកម្ម ឆ្នាំ២០២៤ ៧៣
- រូបភាព៤.៦ ចំនួនគ្រួសារកាន់កាប់កសិកម្ម បានរាយការណ៍ពីឧបករណ៍នេសាទ ឆ្នាំ២០២៤ ៧៤
- រូបភាព៥.១ គ្រួសារកាន់កាប់កសិកម្មរាយការណ៍អំពីការប្រើប្រាស់ឧបករណ៍/គ្រឿងម៉ាស៊ីន តាមប្រភេទឧបករណ៍/គ្រឿងម៉ាស៊ីន តាមតំបន់ ឆ្នាំ២០២៤ ៧៨
- រូបភាព៥.២ គ្រួសារកាន់កាប់កសិកម្មរាយការណ៍អំពីការប្រើប្រាស់ឧបករណ៍/គ្រឿងម៉ាស៊ីនកសិកម្មច្រើនបំផុតទាំង២០ កម្ពុជាឆ្នាំ២០២៤ ៧៩
- រូបភាព៥.៣ ភាគរយនៃកសិដ្ឋានដែលរាយការណ៍ពីភាពជាម្ចាស់នៃឧបករណ៍/គ្រឿងម៉ាស៊ីនធៀបនឹងអ្នកប្រើប្រាស់ ឧបករណ៍ទាំង១០ ដែលមានភាគរយទាបបំផុតនៃម្ចាស់កសិដ្ឋាន កម្ពុជា ឆ្នាំ២០២៤ ៨១
- រូបភាព៥.៤ ចំនួនគ្រួសារកសិកម្មដែលបានរាយកាណ៍ពីការប្រើប្រាស់ និងមិនប្រើប្រាស់សេវកម្មជួសជុល គ្រឿងម៉ាស៊ីនកសិកម្ម កម្ពុជាឆ្នាំ២០២៤ ៨៤
- រូបភាព៥.៥ ចំនួនគ្រួសារកសិកម្មដែលបានរាយកាណ៍ពីកន្លែងរក្សាទុកនៃប្រភេទដំណាំ កម្ពុជា ឆ្នាំ២០២៤ ៨៤
- រូបភាព៥.៦ ចំនួនគ្រួសារកសិកម្មដែលបានរាយកាណ៍ពីការប្រើប្រាស់ប្រភេទឃ្លាំងសម្រាប់រក្សាទុកធញ្ញជាតិ និងសណ្តែក កម្ពុជាឆ្នាំ២០២៤ ៨៦
- រូបភាព៥.៧ ចំនួនគ្រួសារកសិកម្មប្រើប្រាស់អគារ ឬសំណង់ នៅកម្រិតថ្នាក់ជាតិ កម្ពុជា ឆ្នាំ២០២៤ ៨៦
- រូបភាព៥.៨ ចំនួនគ្រួសារកសិកម្មដែលប្រើប្រាស់អគារ ឬសំណង់ សម្រាប់ចិញ្ចឹមបសុសត្វ និងបសុបក្សី តាមតំបន់ឆ្នាំ២០២៤ ៨៧
- រូបភាព៥.៩ ចំនួនគ្រួសារកសិកម្មដែលធ្វើការឱ្យគ្រួសារកសិកម្មដទៃទៀត តាមតំបន់ ឆ្នាំ២០២៤ ៨៨
- រូបភាព៥.១០ ការចំណាយលើប្រេងឥន្ធនៈអំឡុងរដូវប្រាំងនិងរដូវវស្សា (គិតជាដុល្លារ) តាមរដូវ តាមតំបន់ ឆ្នាំ២០២៤ ៩០
- រូបភាព៥.១១ គោលបំណងចម្បងនៃផលិតកម្មកសិកម្មរបស់គ្រួសារកាន់កាប់កសិកម្ម នៅកម្ពុជា ឆ្នាំ២០២៤ ៩១
- រូបភាព៥.១២ ភាគរយនៃប្រាក់ចំណូលពីកសិកម្មរួមចំណែកដល់ប្រាក់ចំណូលសរុបរបស់គ្រួសារនៅកម្ពុជាឆ្នាំ២០២ ៩២
- រូបភាព៥.១៣ ការចូលរួមនៅក្នុងសមាគមកសិករផ្លូវការ ឬសមាគមកសិករក្រៅផ្លូវការ តាមតំបន់ ឆ្នាំ២០២៤ ៩៣
- រូបភាព៥.១៤ ចំនួនគ្រួសារកសិកម្មដែលបានរាយការណ៍ថា មានសមាជិកយ៉ាងតិចម្នាក់ ដែលមានកម្ចីឥណទាន តាមតំបន់ ឆ្នាំ២០២៤ ៩៤
- រូបភាព៥.១៥ ចំនួនគ្រួសារកសិកម្មដែលបានរាយការណ៍ថា បានប្រើប្រាស់កម្ចីឥណទានមួយចំនួន សម្រាប់គោលបំណងកសិកម្ម តាមតំបន់ ឆ្នាំ២០២៤ ៩៤
- រូបភាព៥.១៦ ចំនួនគ្រួសារកសិកម្មដែលបានរាយការណ៍ថា មានសមាជិកគ្រួសារយ៉ាងតិចម្នាក់ដែលមានកម្ចីឥណទាន តាមប្រភេទកម្ចីឥណទាន ឆ្នាំ២០២៤ ៩៦
- រូបភាព៥.១៧ ចំនួនគ្រួសារកសិកម្មដែលបានរាយការណ៍ថា ជួបគ្រោះហានិភ័យ តាមតំបន់ ឆ្នាំ២០២៤ ៩៧
- រូបភាព៥.១៨ ចំនួនគ្រួសារកសិកម្មដែលបានរាយការណ៍ថា បានទទួលរងគ្រោះហានិភ័យ តាមប្រភេទគ្រោះហានិភ័យ កម្ពុជា ឆ្នាំ២០២៤ ៩៨
- រូបភាព៥.១៩ ចំនួនគ្រួសារកសិកម្មដែលបានស្តារឡើងវិញពីគ្រោះហានិភ័យ តាមតំបន់ ឆ្នាំ២០២៤ ១០០

- រូបភាព៥.២០ ចំនួនគ្រួសារកសិកម្មដែលរាយការណ៍មធ្យោបាយចម្បង ដើម្បីទប់ទល់នឹងគ្រោះហានិភ័យ តាមតំបន់ឆ្នាំ២០២៤ ១០១

## តារាងទិន្នន័យស្ថិតិ

- តារាង១.១ សូចនាករសង្ខេបគ្រួសារកាន់កាប់កសិកម្ម ៨
- តារាង១.២ សូចនាការសង្ខេបនៃផលិតកម្មដំណាំ ៩
- តារាង១.៣ សូចនាករសង្ខេបនៃផលិតកម្មបសុសត្វ បសុបក្សី ១០
- តារាង១.៤ សូចនាករសង្ខេបនៃសកម្មភាពវារីវប្បកម្ម និងនេសាទ ១១
- តារាង១.៥ សូចនាករសង្ខេបនៃសកម្មភាពសេដ្ឋកិច្ច ១២
- តារាង១.៦ ការបែងចែកសំណាកគំរូ ១៨
- តារាង២.១ ដើមឈើ ឬដំណាំជារុក្ខជាតិ ការគណនាបំលែងពីការរាប់ចំនួនដើមឈើទៅជាហិកតា ៤៣
- តារាង៣.១ ចំនួនគ្រួសារកសិកម្មដែលចិញ្ចឹមបសុសត្វ និងបសុបក្សី (គិតជាពាន់) ៤៩
- តារាង៥.១ ប្រភេទឧបករណ៍ដែលបានប្រើប្រាស់តាមប្រភេទម្ចាស់កម្មសិទ្ធគ្រួសារកម្ពុជា ឆ្នាំ២០២៤ ៨២

## ផែនទីទិន្នន័យ

- ផែនទី២.១ គ្រួសារដែលមានដីកសិកម្មតិចជាង ២ហិកតា គិតជាភាគរយ បែងចែកតាមខេត្ត ឆ្នាំ២០២៤ ២៦
- ផែនទី២.២ ទិន្នន័យផលស្រូវធម្មតា បែងចែកតាមខេត្ត ឆ្នាំ២០២៤ ៣១
- ផែនទី២.៣ ទិន្នផលស្រូវក្រអូប បែងចែកតាមខេត្ត ឆ្នាំ២០២៤ ៣៣
- ផែនទី២.៤ ទិន្នផលដំឡូងមី បែងចែកតាមខេត្ត ឆ្នាំ២០២៤ ៣៤
- ផែនទី២.៥ ផលិតកម្មដំណាំស្វាយនៃគ្រួសារប្រកបរបរកសិកម្ម គិតជាភាគរយ បែងចែកតាមខេត្ត ឆ្នាំ២០២៤ ៣៨
- ផែនទី៣.១ គ្រួសារប្រកបរបរកសិកម្មបានចិញ្ចឹមបសុសត្វប្រភេទធំ (គិតជាភាគរយ) បែងចែកតាមខេត្ត ឆ្នាំ២០២៤ ៥០
- ផែនទី៣.២ គ្រួសារប្រកបរបរកសិកម្មបានចិញ្ចឹមបសុបក្សី (គិតជាភាគរយ) បែងចែកតាមខេត្ត ឆ្នាំ២០២៤ ៥៨
- ផែនទី៥.១ គ្រួសារប្រកបរបរកសិកម្មរាយការណ៍ថាចំណូលពីកសិកម្មរួមចំណែក ៦០%-១០០% នៃចំណូលសរុបរបស់គ្រួសារ (គិតជាភាគរយ) បែងចែកតាមខេត្ត ឆ្នាំ២០២៤ ៩២
- ផែនទី៥.២ គ្រួសារប្រកបរបរកសិកម្មរាយការណ៍ថាបានទទួលកម្ចី សម្រាប់ប្រើប្រាស់ក្នុងគោលបំណងធ្វើកសិកម្ម (គិតជាភាគរយ) បែងចែកតាមខេត្ត ឆ្នាំ២០២៤ ៩៥
- ផែនទី៥.៣ គ្រួសារប្រកបរបរកសិកម្មរាយការណ៍ថាជួបគ្រោះហានិភ័យ(គិតជាភាគរយ)បែងចែកតាមខេត្តឆ្នាំ២០២៤ ៩៧
- ផែនទី៥.៤ គ្រួសារប្រកបរបរកសិកម្មរាយការណ៍ថាជួបគ្រោះរាំងស្ងួតជាគ្រោះមហន្តរាយ (គិតជាភាគរយ) បែងចែកតាមខេត្ត ឆ្នាំ២០២៤ ៩៩

# បុព្វកថា

របាយការណ៍អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ ផ្តល់ប្រភពទិន្នន័យយ៉ាងសំខាន់សម្រាប់ការវាយតម្លៃផលិតភាពកសិកម្មនៅកម្ពុជា និងបង្ហាញស្ថានភាពស្តីពីផ្នែកដំណាំ ការចិញ្ចឹមសត្វ ការធ្វើវារីវប្បកម្ម ការនេសាទ និងសកម្មភាពពាក់ព័ន្ធដទៃទៀត ដែលមានសារៈប្រយោជន៍បំផុតសម្រាប់ឆ្លុះបញ្ចាំងអំពីស្ថានភាពកសិកម្ម បរិស្ថាន សេដ្ឋកិច្ច សង្គម និងសន្តិសុខស្បៀងរបស់គ្រួសារកសិកម្មកម្ពុជា។ លើសពីនេះ ទិន្នន័យអង្កេតកសិកម្មកម្ពុជាជាធាតុចូលដ៏សំខាន់ សម្រាប់ការវាស់វែង និងឆ្លុះបញ្ចាំងនៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ការកាត់បន្ថយភាពក្រីក្រ ការគណនាកំណើនសេដ្ឋកិច្ចជាតិ និងកម្មវិធីអភិវឌ្ឍន៍ពាក់ព័ន្ធផ្សេងៗទៀត។

គោលបំណងសំខាន់នៃអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ ដើម្បីជួយជំរុញទិសដៅការអភិវឌ្ឍវិស័យកសិកម្មក្នុងការរួមចំណែកដល់ភាពរីកចម្រើនរបស់ប្រទេសជាតិ និងសុខុមាលភាពរបស់ប្រជាជនកម្ពុជា ឆ្ពោះទៅសម្រេចបានគោលដៅសំខាន់ៗចំនួនបី នៃក្របខណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ឆ្នាំ២០១៦-២០៣០ ដូចខាងក្រោម៖

- **គោលដៅទី១៖** បញ្ចប់ភាពក្រីក្រគ្រប់ទម្រង់នៅគ្រប់ទីកន្លែង
- **គោលដៅទី២៖** បញ្ចប់ភាពអត់ឃ្លាន សម្រេចឱ្យបាននូវសន្តិសុខស្បៀង ធ្វើឱ្យប្រសើរឡើងស្ថានភាពអាហារូបត្ថម្ភ និងលើកកម្ពស់វិស័យកសិកម្មប្រកបដោយចីរភាព
- **គោលដៅទី៥៖** សម្រេចឱ្យបានសមភាពយេនឌ័រ និងបង្កើនភាពអង់អាចដល់ស្ត្រី និងកុមារីគ្រប់រូប។

របាយការណ៍អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ នឹងផ្តល់ជូននូវព័ត៌មាន ទិន្នន័យស្ថិតិអំពីស្ថានភាពវិស័យកសិកម្មដល់គ្រប់ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ អង្គការជាតិ អង្គការអន្តរជាតិ ស្ថាប័នស្រាវជ្រាវ វិស័យឯកជន និងសាធារណជនទូទៅដែលអាចប្រើប្រាស់របកគំហើញទាំងនេះតាមតម្រូវការ។ ទិន្នន័យអង្កេតកសិកម្មកម្ពុជានេះ នឹងបម្រើជាមូលដ្ឋានសម្រាប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តគោលនយោបាយ អភិវឌ្ឍន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន ដើម្បីសម្រេចបាននូវចក្ខុវិស័យរបស់កម្ពុជាសម្រាប់ឆ្នាំ២០៥០ ដែលចាត់ទុកការអភិវឌ្ឍវិស័យកសិកម្មនៃយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណចំពោះរាជរដ្ឋាភិបាលកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ និងកម្មវិធីគំនិតផ្តួចផ្តើមគម្រោង៥០x២០៣០ និងដៃគូអភិវឌ្ឍនានា ដែលបានរួមចំណែកក្នុងការធ្វើឱ្យអង្កេតកសិកម្មកម្ពុជាបញ្ចប់ទៅដោយជោគជ័យ។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរចំពោះថ្នាក់ដឹកនាំ អ្នកគ្រប់គ្រង មន្ត្រីជំនាញវិភាគរបាយការណ៍លទ្ធផលទិន្នន័យតាមផ្នែកនីមួយៗ ក្រុមការងារបច្ចេកទេសអង្កេតកសិកម្មកម្ពុជា មន្ត្រីត្រួតពិនិត្យ និងមន្ត្រីសម្ភាសន៍របស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ដែលបានចូលរួមខិតខំប្រឹងប្រែងបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយស្មារតីយកចិត្តទុកដាក់ខ្ពស់ ក្នុងដំណើរការអនុវត្តការងារអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ និងសូមអរគុណចំពោះប្រជាពលរដ្ឋ ដែលបានចូលរួមសម្ភាសន៍ផ្តល់ចម្លើយធ្វើឱ្យអង្កេតកសិកម្មកម្ពុជាឈានសម្រេចបានជោគជ័យ៕

ថ្ងៃព្រហស្បតិ៍ ១៥រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៥

**រដ្ឋមន្ត្រីក្រសួងផែនការ**

**ប៊ិន ត្រាឈៃ**

# អារម្ភកថា

វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការមានសេចក្តីសោមនស្សរីករាយដោយក្នុងការបង្ហាញជូននូវរបាយការណ៍វិភាគលទ្ធផលចុងក្រោយអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ ដែលទទួលបានពីការសម្ភាសន៍សំណាកគំរូគ្រួសារកសិកម្មចំនួន ១៥ ៦២២គ្រួសារ នៅរាជធានី ខេត្តចំនួន២៥ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ គឺជាអង្កេតប្រចាំឆ្នាំលើកទី៦ នៅក្នុងការធ្វើអង្កេតបន្តបន្ទាប់ (គិតចាប់ពីឆ្នាំ២០១៩ ឆ្នាំ២០២០ ២០២១ ២០២២ ២០២៣ និងឆ្នាំ២០២៤)។

របាយការណ៍វិភាគលទ្ធផលនៃការអង្កេតនេះ ត្រូវបានដឹកនាំប្រតិបត្តិដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងកិច្ចសហប្រតិបត្តិការរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO)។ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ បានទទួលការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសពីរាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ FAO គំនិតផ្តួចផ្តើមនៃគម្រោង៥០x២០៣០។

ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ ត្រូវបានអនុវត្តន៍ដោយអនុលោមតាមកិច្ចព្រមព្រៀងរវាង ក្រសួងផែនការ អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ ប្រចាំកម្ពុជានៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៨។ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ ត្រូវបានធ្វើសម្ភាសន៍ផ្ទាល់ដោយប្រើប្រាស់ម៉ាស៊ីនថាប្លេត (Tablet) ដោយប្រើកម្មវិធី Survey Solution របស់ធនាគារពិភពលោក សម្រាប់សម្ភាសន៍កត់ត្រា និងគ្រប់គ្រងទិន្នន័យ។

ទិន្នន័យដែលប្រមូលបានពីគ្រួសារកសិកម្មត្រូវបានបញ្ចូលនៅក្នុងរបាយការណ៍វិភាគចុងក្រោយនៃការអង្កេតនេះ មានដូចជា៖ ផលិតកម្មដំណាំ បសុសត្វ បសុបក្សី វារីវប្បកម្ម និងនេសាទ ដើម្បីធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិកសិកម្មប្រចាំឆ្នាំ និងបំពេញតម្រូវការរបស់អ្នកធ្វើគោលនយោបាយ របាយការណ៍ស្តីពីគោលដៅអភិវឌ្ឍន៍កសិកម្ម បរិស្ថាន និងសូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ របស់រាជរដ្ឋាភិបាលកម្ពុជា ឬអង្គការសហប្រជាជាតិ អ្នកសិក្សាស្រាវជ្រាវ និងអ្នកពាក់ព័ន្ធដទៃទៀត។

របាយការណ៍អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ គឺជាធាតុចូលដ៏សំខាន់ក្នុងការរៀបចំគោលនយោបាយ កម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្មឱ្យកាន់តែមានប្រសិទ្ធភាព ប្រសិទ្ធផល និងគាំទ្រសូចនាករគោលដៅឆ្ពោះទៅរក "យុទ្ធសាស្រ្តបញ្ចកោណ" របស់រាជរដ្ឋាភិបាល ដើម្បីសម្រេចបាននូវគោលដៅដែលបានរំពឹងទុកសម្រាប់ "ចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០" ។

របាយការណ៍លទ្ធផលអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ ត្រូវបានបើកចំហសម្រាប់កិច្ចពិភាក្សាព្រមទាំងទទួលនូវរាល់មតិយោបល់ ឬអនុសាសន៍ ដើម្បីកែលម្អរបាយការណ៍លទ្ធផលវិភាគទិន្នន័យអង្កេតកសិកម្មនាពេលខាងមុខឱ្យកាន់តែប្រសើរឡើង។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណជ្រាលជ្រៅចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួងស្ថាប័នពាក់ព័ន្ធ ក្រុមការងារបច្ចេកទេសអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ ជំនាញការអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ និងមន្ត្រីដែលពាក់ព័ន្ធទាំងអស់ដែលបានចូលរួមអនុវត្តន៍ការងារប្រមូល ចងក្រង វិភាគទិន្នន័យស្ថិតិ និងសរសេររបាយការណ៍អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ ឱ្យសម្រេចបានជោគជ័យ ប្រកបដោយគុណភាព និងប្រសិទ្ធភាព៕

**នាយកវិទ្យាស្ថានជាតិស្ថិតិ**

**ទ្រី ឫទ្ធា**

# អក្សរកាត់

| | |
|---|---|
| CAS | អង្កេតកសិកម្មកម្ពុជា Cambodia Agriculture Survey |
| CIAS | អង្កេតចន្លោះជំរឿនកសិកម្មកម្ពុជា Cambodia Inter-Censal Agriculture Survey |
| CSES | អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា Cambodia Socio-Economic Survey |
| FAO | អង្គការស្បៀង និងកសិកម្ម នៃសហប្រជាជាតិ Food and Agriculture Organization |
| GDP | ផលិតផលក្នុងស្រុកសរុប Gross Domestic Product |
| Ha | ហិកតា Hectare |
| Kg | គីឡូក្រាម Kilograms |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ Ministry of Agriculture Forestry and Fisheries |
| MOP | ក្រសួងផែនការ Ministry of Planning |
| NIS | វិទ្យាស្ថានជាតិស្ថិតិ National Institute of Statistics |
| PPS | ទំហំសមាមាត្រថៃជន្យ Probability Proportional to Size |
| RGC | រាជរដ្ឋាភិបាលកម្ពុជា Royal Government of Cambodia |
| TC | គណៈកម្មាធិការបច្ចេកទេស Technical Committee |
| USD | ដុល្លារអាមេរិក United States Dollar |

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤

## ផ្នែកទី១: វិធីសាស្ត្រអង្កេត



**វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ**

សហការជាមួយ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

គាំទ្របច្ចេកទេសដោយ៖

អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ

គាំទ្រហិរញ្ញវត្ថុដោយ៖ គំនិតផ្តួចផ្តើម ៥០x២០៣០

# រចនាសម្ព័ន្ធរបាយការណ៍

របាយការណ៍អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ ត្រូវបានចែកជាប្រាំផ្នែកនៃរបាយការណ៍ដែលគ្របដណ្តប់នូវទិដ្ឋភាពសំខាន់ៗផ្សេងគ្នាដូចខាងក្រោម៖

**ផ្នែកទី១៖ វិធីសាស្ត្រប្រមូលទិន្នន័យ និងឯកសារយោង**

ផ្នែកនេះគ្របដណ្តប់នូវព័ត៌មាននៃការអង្កេតទាំងមូលរួមមាន៖ បុព្វកថា អារម្ភកថា អក្សរកាត់ សូចនាករសង្ខេបនៃវិធីសាស្ត្រអង្កេត វិសាលភាពនៃការអង្កេត ទីតាំងភូមិសាស្ត្រ រយៈពេលនៃការអង្កេត កាលបរិច្ឆេទយោង និងតារាងបញ្ជីសំណាកគំរូ ។

**ផ្នែកទី២៖ ផលិតកម្មដំណាំ**

ផ្នែកនេះគ្របដណ្តប់លើផលិតកម្មដំណាំនៅកម្ពុជា រួមបញ្ចូលទាំងព័ត៌មានទាក់ទងនឹងចំនួនគ្រួសារកាន់កាប់កសិកម្ម ផលិតកម្មដំណាំរយៈពេលខ្លី និងដំណាំរយៈពេលវែង។ ការប្រើប្រាស់ផ្ទៃដីកសិកម្ម ផ្ទៃដីដាំដុះ ផ្ទៃដីប្រមូលផល ទិន្នផលដំណាំ ការប្រើប្រាស់ជី ប្រព័ន្ធធារាសាស្ត្រ ប្រភេទគ្រាប់ពូជ/ពូជរុក្ខជាតិដាំដុះ ប្រភេទដីដែលប្រើប្រាស់ ផលប៉ះពាល់នៃសំណឹកដី និងតម្លៃនៃការលក់ផលិតផលដំណាំ។

**ផ្នែកទី៣៖ ការចិញ្ចឹមបសុសត្វ បសុបក្សី**

ផ្នែកនេះគ្របដណ្តប់លើការកាន់កាប់គ្រួសារកសិកម្ម រួមបញ្ចូលទាំងចំនួនគ្រួសារចិញ្ចឹមបសុសត្វ និងបសុបក្សីចំនួនសត្វសរុបនៅកម្ពុជា ចំនួនសត្វជាមធ្យមក្នុងមួយគ្រួសារ គោលបំណងនៃការចិញ្ចឹមសត្វ តម្លៃនៃការលក់សត្វ និងថ្លៃដើមផលិត។

**ផ្នែកទី៤៖ វារីវប្បកម្ម និងនេសាទ**

ផ្នែកនេះគ្របដណ្តប់លើការកាន់កាប់គ្រួសារកសិកម្ម ដែលពាក់ព័ន្ធនឹងវារីវប្បកម្ម និងនេសាទ រួមបញ្ចូលទាំងចំនួនគ្រួសារធ្វើវារីវប្បកម្មតាមប្រភេទផ្សេងៗគ្នា ចំនួនផ្ទៃដីសរុបសម្រាប់វារីវប្បកម្ម ប្រភេទវារីសត្វចិញ្ចឹម និងបរិមាណផលិតផលដែលបានផលិត គ្រួសារចូលរួមក្នុងសកម្មភាពនេសាទតាមប្រភេទទឹក ប្រភេទវារីសត្វ និងបរិមាណសរុបនេសាទបាន។

**ផ្នែកទី៥៖ គ្រឿងម៉ាស៊ីន ឧបករណ៍សម្ភារបរិក្ខារកសិកម្ម សេដ្ឋកិច្ច និងគ្រោះហានិភ័យ**

ផ្នែកនេះគ្របដណ្តប់លើការកាន់កាប់របស់គ្រួសារកសិកម្ម ដែលពាក់ព័ន្ធនឹងកម្មសិទ្ធិនៃប្រភេទគ្រឿងយន្តឧបករណ៍សម្ភារបរិក្ខារកសិកម្មប្រើប្រាស់ដោយយេនឌ័រ រួមបញ្ចូលទាំងកន្លែងជួសជុលគ្រឿងយន្តកសិកម្ម និងអគារ ឬសំណង់ដែលប្រើសម្រាប់រក្សាទុកដំណាំ និងទីជម្រកបសុសត្វ ឬបសុបក្សី លទ្ធភាពទទួលបានហិរញ្ញវត្ថុ និងប្រាក់កម្ចី ការចំណាយរបស់គ្រួសារកាន់កាប់កសិកម្ម កម្លាំងពលកម្មដែលបានប្រើដោយគ្រួសារ

កាន់កាប់កសិកម្មផ្ទាល់ ឬដោយគ្រួសារកាន់កាប់កសិកម្មផ្សេងៗទៀត ការកំណត់សំខាន់នៃផលិតកម្មកសិកម្ម និងការចូលរួមក្នុងសមាគមកសិករផ្លូវការ ឬក្រៅផ្លូវការ និងផលប៉ះពាល់នៃគ្រោះហានិភ័យ។

ផ្នែកទាំង៥ខាងលើ អាចទាញយកពីគេហទំព័រ *http://www.nis.gov.kh/index.php/km* របស់វិទ្យាស្ថានជាតិស្ថិតិ។ របាយការណ៍នេះ មានគោលបំណងផ្តល់នូវទិដ្ឋភាពទូទៅ នៃទិន្នន័យដែលបានរួមបញ្ចូលនៅក្នុងការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤។ ទោះបីជាយ៉ាងណាក៏ដោយទិន្នន័យមិនទាន់គ្រប់ដណ្តប់ទូលំទូលាយពេញលេញនៅឡើយ ហើយសំណួរមួយចំនួនមិនត្រូវបានវិភាគក្នុងវិសាលភាពនៃឯកសារទាំងនេះទេ។ ព័ត៌មានត្រូវបានវិភាគ និងបង្ហាញក្នុងករណីភាគច្រើននៅថ្នាក់ជាតិ និងតំបន់។ អ្នកប្រើប្រាស់ទិន្នន័យគួរស្វែងយល់និងធ្វើការវិភាគក្នុងការប្រើប្រាស់ដោយខ្លួនឯង តាមរយៈការប្រើប្រាស់តារាងទិន្នន័យពេញលេញដែលត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិ https://camstat.nis.gov.kh (CAMSAT) និងមីក្រូទិន្នន័យ (Microdata) មានអស័យដ្ឋានគេហទំព័រ https://microdata.nis.gov.kh ។

# សេចក្ដីសង្ខេប

## ទិដ្ឋភាពទូទៅ នៃវិធីសាស្ត្រអង្កេត

អង្កេតកសិកម្មកម្ពុជាត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ២០២៤ ក្នុងគោលបំណងដើម្បីប្រមូល ចងក្រងព័ត៌មាន វិភាគទិន្នន័យស្ថិតិកសិកម្មស៊ីជម្រៅក្នុងផ្នែកការដាំដុះដំណាំ ការចិញ្ចឹមបសុសត្វ បសុបក្សី ការធ្វើវារីវប្បកម្ម និងការនេសាទ។ ទិន្នន័យស្ថិតិដែលប្រមូលបានពីការអង្កេតនេះផ្ដល់សារៈប្រយោជន៍ដល់អ្នករៀបចំធ្វើផែនការ គោលនយោបាយ និងកម្មវិធីអភិវឌ្ឍនានាសម្រាប់ការលើកកម្ពស់គុណភាពវិស័យកសិកម្ម និងនេសាទនៅកម្ពុជាឱ្យកាន់តែប្រសើរឡើង។

វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាស្ថាប័នរបស់រដ្ឋាភិបាលដែលមានតួនាទីទទួលខុសត្រូវ និងបានទទួលការអនុញ្ញាតឱ្យធ្វើការអង្កេតនេះ។ វិទ្យាស្ថានជាតិស្ថិតិមានតួនាទី និងភារកិច្ចក្នុងការប្រមូល ចងក្រង វិភាគទិន្នន័យស្ថិតិតាមរយៈការធ្វើជំរឿន និងអង្កេតនានា ដោយឡែកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាអ្នកប្រើប្រាស់ជាចម្បងនូវទិន្នន័យអង្កេតនេះ។

គោលបំណងចម្បង នៃការធ្វើអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ ដើម្បីផ្ដល់ទិន្នន័យស្ដីពីស្ថានភាពវិស័យកសិកម្មនៅកម្ពុជា ដល់អ្នករៀបចំផែនការ កសាងគោលនយោបាយ និងកម្មវិធីអភិវឌ្ឍផ្សេងៗរបស់រាជរដ្ឋាភិបាល និងវិស័យឯកជន។ បន្ទាប់ពីអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩ និង ២០២០ ដែលបានប្រើប្រាស់បញ្ជីសំណាកគំរូតែមួយដូចគ្នា អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១ ឆ្នាំ២០២២ និងឆ្នាំ២០២៣ បានប្រើប្រាស់បញ្ជីសំណាកគំរូតែមួយដូចគ្នា។ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ ដែលបានប្រើប្រាស់សំណាកគំរូយកចេញពីជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣ (CAC2023 Sampling Frame)។ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ ត្រូវបានប្រើប្រាស់វិធីសាស្ត្រស្ថិតិដើម្បីជ្រើសរើសភូមិសំណាកគំរូនៅទូទាំងកម្ពុជា។

ការប្រមូលទិន្នន័យអង្កេតនេះ ត្រូវបានធ្វើឡើងដោយប្រើប្រាស់វិធីសាស្ត្រសម្ភាសន៍អ្នកផ្ដល់ចម្លើយដោយផ្ទាល់ និងប្រើប្រាស់ម៉ាស៊ីនថេប្លេត។ បញ្ជីសំណួរសម្រាប់ការអង្កេតនេះត្រូវបានបង្កើតឡើងនៅក្នុងកម្មវិធីអង្កេត (Survey Solutions) របស់ធនាគារពិភពលោក។ ការប្រើប្រាស់កម្មវិធីកាពី (CAPI) សម្រាប់សម្ភាសន៍ គឺចំណេញពេលវេលា មិនចំណាយលើការវាយបញ្ចូលទិន្នន័យ បង្កើនសមត្ថភាពចំណេះដឹងជំនាញលើបច្ចេកវិទ្យាកុំព្យូទ័រ និងការត្រួតពិនិត្យគុណភាព និងមានលទ្ធភាពទាញតារាងស្ថិតិធ្វើការវិភាគទិន្នន័យបានឆាប់រហ័សជាងមុន។

សំណាកគំរូគ្រួសារកសិកម្មដែលរស់នៅទូទាំងប្រទេសត្រូវបានជ្រើសរើសយកមកធ្វើការសម្ភាស លើកលែងសង្កាត់ចំនួន១១នៅរាជធានីភ្នំពេញ ត្រូវបានចាត់ជាទីប្រជុំជន និងមិនបានរាប់បញ្ចូលក្នុងការធ្វើជំរឿនកសិកម្មឆ្នាំ២០២៣។ សម្រាប់ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ គ្រួសារសំណាកគំរូសរុបចំនួន ១៥ ៦២២ គ្រួសារកសិកម្មត្រូវបានសម្ភាសន៍ពេញលេញ។ បន្ថែមពីលើការប្រមូលទិន្នន័យតាមលក្ខណៈគ្រួសារកសិកម្ម ទិន្នន័យដាច់ដោយឡែកមួយទៀតបានកំណត់គោលដៅលើសហគ្រាសកសិកម្មខ្នាតធំ ដែលដំណើរការដោយសាជីវកម្ម

សហករណ៍ និងស្ថាប័នរដ្ឋាភិបាល ឬឯកជន ដែលសំដៅដល់ការកាន់កាប់ផ្នែកយុត្តាធិការក្នុងវិស័យមិនមែនគ្រួសារ។ ការប្រមូលនេះត្រូវបានធ្វើឡើងជាជំរឿននៃការកាន់កាប់មិនមែនគ្រួសារទាំងអស់ដែលគេស្គាល់ និងអាចចូលប្រើបាន។ សហគ្រាសកសិកម្មសរុបចំនួន៥២០ ត្រូវបានរួមបញ្ចូលនៅក្នុងការប្រមូលទិន្នន័យអង្កេតកសិកម្មឆ្នាំ២០២៤ ។

ព័ត៌មានលម្អិតអំពីនីតិវិធីនៃការជ្រើសរើសសំណាកគំរូ វិធីសាស្ត្រអង្កេត និងប្រតិបត្តិការប្រមូលទិន្នន័យសម្រាប់អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២២ មានការអធិប្បាយពន្យល់លម្អិតនៅក្នុងជំពូកទី១–វិសាលភាពការគ្របដណ្តប់និងការជ្រើសរើសសំណាកគំរូ។ ការសម្ភាសផ្នែកគ្រួសារកាន់កាប់កសិកម្មត្រូវបានធ្វើឡើងចាប់ពីខែវិច្ឆិកា ដល់ខែធ្នូ ឆ្នាំ២០២៤។ កាលបរិច្ឆេទយោងសម្រាប់ការអង្កេតនេះ គឺក្នុងរយៈពេល១២ខែកន្លងមកដោយគិតចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤។ ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ មានមន្ត្រីសម្ភាសន៍សរុបចំនួន ៣៣៧នាក់ ដែលបានចូលរួមក្នុងការចុះសម្ភាសប្រមូលទិន្នន័យនេះ មន្ត្រីត្រួតពិនិត្យគុណភាពទិន្នន័យចំនួន ៤៦នាក់ ដែលទទួលខុសត្រូវក្នុងការត្រួតពិនិត្យគុណភាពទិន្នន័យ និងមន្ត្រីត្រួតពិនិត្យនៅមណ្ឌលសម្ភាសន៍ចំនួន ៤៦នាក់ ទទួលខុសត្រូវជួយសម្របសម្រួលមន្ត្រីសម្ភាសន៍ ក្នុងការដោះស្រាយបញ្ហានៅតាមមូលដ្ឋានជួយទំនាក់ទំនងជាមួយមេភូមិ និងការលើកកម្ពស់កិច្ចសហការជាមួយគ្រួសារកាន់កាប់កសិកម្ម ឱ្យបានដំណើរការរលូននៅក្នុងប្រតិបត្តិការអង្កេតនេះ។ មន្ត្រីអង្កេតត្រូវបានជ្រើសរើសចេញពីវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ត្រីនៅតាមមន្ទីរផែនការខេត្ត និងមន្ទីរកសិកម្មរុក្ខា ប្រមាញ់ និងនេសាទ រាជធានី ខេត្ត។ តាមដែលអាចធ្វើបានអ្នកចាត់ចែង និងអ្នកគ្រប់គ្រងការងារនៅតែដដែលដូចឆ្នាំមុនៗ ដើម្បីពង្រឹងបទពិសោធន៍ និងចំណេះដឹងដែលទទួលបាន។

ការអង្កេតកសិកម្មកម្ពុជាបានប្រើប្រាស់និយមន័យ "គ្រួសារកាន់កាប់កសិកម្ម" ដែលកំណត់ក្នុងឯកសារណែនាំស្តីអំពីជំរឿនកសិកម្មពិភពលោកដែលបានបោះផ្សាយឆ្នាំ២០២០ (WCA 2020) និងយុទ្ធសាស្ត្រសកលដើម្បីលើកកម្ពស់ស្ថិតិកសិកម្ម និងជនបទ។ ការកាន់កាប់កសិកម្មត្រូវបានកំណត់ថា ជាអង្គភាពសេដ្ឋកិច្ច នៃផលិតកម្មកសិកម្មស្ថិតក្រោមការគ្រប់គ្រងតែមួយ ដែលរួមមាន បសុសត្វ បសុបក្សី ដែលបានរក្សាទុក និងផ្ទៃដីដែលបានប្រើប្រាស់ទាំងស្រុង ឬមួយផ្នែកសម្រាប់គោលបំណងផលិតកម្មកសិកម្ម ដោយមិនគិតពីស្ថានភាពកម្មសិទ្ធិ ទម្រង់នៃការកាន់កាប់ ឬទំហំឡើយ។ ការគ្រប់គ្រងណាមួយ អាចត្រូវបានអនុវត្តន៍ដោយបុគ្គល ឬគ្រួសារដោយបុគ្គលពីរនាក់ ច្រើននាក់ ឬច្រើនគ្រួសាររួមគ្នា ជាក្រុម ឬកុលសម្ព័ន្ធ ឬដោយនីតិបុគ្គលដូចជាសាជីវកម្ម សហគមន៍ ឬស្ថាប័នរដ្ឋាភិបាល។ ដីនៅដែលស្ថិតក្រោមការកាន់កាប់កសិកម្មអាចមានក្បាលដីមួយឬច្រើន ដែលមានទីតាំងនៅតំបន់ដាច់ដោយឡែកមួយឬច្រើន ឬនៅក្នុងភូមិសាស្ត្រ ឬរដ្ឋបាលដែនដីមួយឬច្រើនដោយផ្តល់ក្បាលដី ដែលមានមធ្យោបាយផលិតកម្មដូចគ្នា ដូចជា ពលកម្ម អគារកសិដ្ឋាន គ្រឿងយន្ត ឬកម្លាំងអូសទាញ។ វិសាលភាពនៃសកម្មភាពកសិកម្មមានដូចជាការដាំដំណាំរយៈពេលវែង ឬដំណាំរយៈពេលខ្លី ការបង្កាត់ពូជរុក្ខជាតិ ផលិតកម្មសត្វ ឬការធ្វើកសិកម្មចម្រុះ។ សកម្មភាពសេដ្ឋកិច្ចមិនមែនកសិកម្មផ្សេងទៀត ដូចជា វារីវប្បកម្ម ការនេសាទ និងព្រៃឈើ ត្រូវបានចាត់ទុកថាជាពិពិធកម្មនៃការកាន់កាប់កសិកម្ម។ ខុសពីនៃការធ្វើអង្កេតកសិកម្មកម្ពុជានៅឆ្នាំមុនៗ ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤បានប្រើប្រាស់កម្រិតអប្បបរមាសម្រាប់សកម្មភាពកសិកម្ម ដើម្បីបង្កើតលទ្ធផលស្របតាមជំរឿនកសិកម្មកម្ពុជា២០២៣ ដែលក្នុងនោះគ្រួសារ

មានសិទ្ធិទទួលបានការអង្កេត ប្រសិនបើពួកគេដាំដំណាំលើផ្ទៃដីយ៉ាងហោចណាស់ ០,០៣ ហិកតា និង/ឬ មានបសុសត្វធំចំនួន ២ និង/ឬ បសុសត្វតូចចំនួន ៣ និង/ឬ បសុបក្សី ២៥ក្បាល។

នៅក្នុងការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ គឺជាការជ្រើសរើសសំណាកគំរូមានកម្រិតកំណត់ ដូច្នេះ ទិន្នន័យដែលផលិត វិភាគបកស្រាយ ឬប្រៀបធៀប ត្រូវពឹងផ្អែកលើប្រភពទិន្នន័យផ្សេងទៀតផងដែរ។ អ្នកប្រើប្រាស់ទិន្នន័យ ឬអ្នកអាន អាចយោងទៅលើរបាយការណ៍អង្កេតកសិកម្មកម្ពុជាពេញលេញ នៅក្នុងផ្នែកដែនកំណត់នៃជំពូកទី១។ ជាទូទៅអ្នកប្រើប្រាស់ទិន្នន័យ ឬអ្នកអានគួរស្វែងយល់ដោយខ្លួនឯង ពីដែនកំណត់នៃទិន្នន័យអង្កេត វិសាលភាពនៃការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំនៅកម្ពុជានិងការកំណត់នៃកម្រងសំណួរអង្កេត និងវិធីសាស្ត្រសម្ភាសន៍។

## សូចនាករសង្ខេប

ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ ប្រើប្រាស់កម្រងសំណួរជាចម្បងមួយសម្រាប់ការកាន់កាប់កសិកម្មជាលក្ខណៈគ្រួសារហើយកម្រងសំណួរដូចគ្នានេះ ក៏ត្រូវបានប្រើប្រាស់ដើម្បីប្រមូលទិន្នន័យពីការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំផងដែរ។ ទម្រង់កម្រងសំណួរនេះ រួមមាន១៥ ជំពូកសំខាន់ៗគឺ៖

១. អត្តសញ្ញាណនៃអ្នកតបសម្ភាសន៍ និងការណែនាំខ្លួនស្នើសុំការសម្ភាស

១ក. សមាជិកគ្រួសារ

២. ចរិកលក្ខណៈនៃគ្រួសារ/កសិដ្ឋាន

៣. ការកាន់កាប់ដី និងការអនុវត្តកសិកម្ម

៤. ផលិតកម្មដំណាំ

៥. ការប្រើប្រាស់គ្រាប់ពូជ ការអនុវត្តកសិកម្ម និងធាតុចូល

៦. អគារ ឬសំណង់មិនមែនលំនៅឋានដែលប្រើសម្រាប់ដំណាំ

៧. ផលិតកម្មបសុសត្វ

៨. ផលិតកម្មបសុបក្សី

៩. អគារមិនមែនលំនៅឋាន (បសុសត្វ បសុបក្សី)

១០. វារីវប្បកម្ម និង/ឬការនេសាទត្រី

១១. សកម្មភាពសេដ្ឋកិច្ច

១២. គ្រឿងម៉ាស៊ីន និងឧបករណ៍សម្ភារបរិក្ខារកសិកម្ម

១៣. យុទ្ធសាស្ត្រដោះស្រាយបញ្ហាប្រឈម និងការបម្រែបម្រួលអាកាសធាតុ ឬបរិស្ថាន

១៤. កម្រិតនៃអសន្តិសុខស្បៀងដែលគ្រួសារបានជួបប្រទះ

១៥. បញ្ចប់ការសម្ភាស

ទិន្នន័យសំខាន់ៗកម្រិតថ្នាក់ជាតិ និងកម្រិតតំបន់ ទាញចេញពីការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ បែងចែកតាមតំបន់ វាលទំនាប បឹងទន្លេសាប ឆ្នេរសមុទ្រ និង ភ្នំនិងខ្ពង់រាប ត្រូវបានបង្ហាញក្នុងតារាងដូចខាងក្រោម៖

**តារាង១.១៖ សូចនាករសង្ខេប គ្រួសារកាន់កាប់កសិកម្ម**

| គ្រួសារកាន់កាប់កសិកម្ម | | | | | |
|---|---|---|---|---|---|
| | **កម្ពុជា** | **តំបន់វាលទំនាប** | **តំបន់បឹងទន្លេសាប** | **តំបន់ឆ្នេរសមុទ្រ** | **តំបន់ភ្នំនិងខ្ពង់រាប** |
| ចំនួនគ្រួសារកសិកម្ម (គិតជាពាន់) | ១ ៨៦៨ | ៧៣២ | ៧២២ | ១២៣ | ២៩១ |
| **គោលបំណងចម្បងនៃផលិតកម្មកសិកម្មរបស់គ្រួសារកសិកម្ម៖** | | | | | |
| ចម្បងសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ | ៥២% | ៥៥% | ៤៥% | ៧៤% | ៥១% |
| ចម្បងសម្រាប់លក់ | ៤៨% | ៤៥% | ៥៥% | ២៦% | ៤៩% |
| ភាគរយនៃគ្រួសារកសិកម្មមានតែដីជុំវិញលំនៅឋានប៉ុណ្ណោះ | ៩% | ៨% | ១១% | ១០% | ៤% |

*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

**តារាង១.២ សូចនាករសង្ខេបនៃផលិតកម្មដំណាំ**

| ផលិតកម្មដំណាំ | | | | | |
|---|---|---|---|---|---|
| | **កម្ពុជា** | **តំបន់វាលទំនាប** | **តំបន់បឹងទន្លេសាប** | **តំបន់ឆ្នេរសមុទ្រ** | **តំបន់ភ្នំនិងខ្ពង់រាប** |
| ចំនួនគ្រួសារបានដាំដុះដំណាំ (គិតជាពាន់) | ១ ៧៦៧ | ៦៩៥ | ៦៧៥ | ១១៣ | ២៨៣ |
| ភាគរយនៃគ្រួសារបានដាំដុះដំណាំ | ៩៥% | ៩៥% | ៩៣% | ៩២% | ៩៧% |
| ដំណាំដែលពេញនិយមចំនួនប្រាំ ដែលបានដាំដុះដោយគ្រួសារកសិកម្ម | ១. ស្រូវធម្មតា | ១. ស្រូវធម្មតា | ១. ស្រូវធម្មតា | ១. ស្រូវធម្មតា | ១. ស្រូវធម្មតា |
| | ២.ស្វាយ | ២. ចេក | ២. ស្វាយ | ២. ដូង | ២. ស្វាយចន្ទី |
| | ៣. ដូង | ៣. ដូង | ៣. ចេក | ៣. ស្វាយ | ៣. ដំឡូងមី |
| | ៤. ចេក | ៤. ស្វាយ | ៤. ដូង | ៤. ចេក | ៤. ស្វាយ |
| | ៥. ស្រូវក្រអូប | ៥. ស្រូវក្រអូប | ៥. ស្រូវក្រអូប | ៥. ស្រូវក្រអូប | ៥. ដូង |

*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

### តារាង១.៣ សូចនាករសង្ខេបនៃផលិតកម្មបសុសត្វ បសុបក្សី

| សកម្មភាពចិញ្ចឹមបសុសត្វ បសុបក្សី | | | | | |
|---|---|---|---|---|---|
| | កម្ពុជា | តំបន់វាលទំនាប | តំបន់បឹងទន្លេសាប | តំបន់ឆ្នេរសមុទ្រ | តំបន់ភ្នំនិងខ្ពង់រាប |
| ចំនួនគ្រួសារកសិកម្មដែលបានចិញ្ចឹមបសុសត្វ បសុបក្សី ក្នុងអំឡុងពេលឆ្នាំយោង (គិតជាពាន់) | ១ ៣៤៣ | ៥១៣ | ៥២៥ | ១០៦ | ១៩៨ |
| ភាគរយនៃគ្រួសារកសិកម្មដែលបានចិញ្ចឹមបសុសត្វ/បសុបក្សី ក្នុងអំឡុងពេលឆ្នាំយោង | ៧២% | ៧០% | ៧៣% | ៨៦% | ៦៨% |
| ចំនួនគ្រួសារកសិកម្មដែលបានចិញ្ចឹមសត្វគោក្នុងអំឡុងពេលឆ្នាំយោង (គិតជាពាន់) | ៦៧៩ | ២៩១ | ២៣៦ | ៥៤ | ៩៩ |
| ចំនួនសត្វគោជាមធ្យមក្នុងមួយគ្រួសារ | ៤,៥ | ៤,០ | ៤,៩ | ៣,០ | ៦,១ |
| ចំនួនគ្រួសារកសិកម្មដែលបានចិញ្ចឹមសត្វមាន់ក្នុងអំឡុងពេលឆ្នាំយោង (គិតជាពាន់) | ១ ០៣៤ | ៣៧៧ | ៤០៥ | ៩៧ | ១៥៥ |
| ចំនួនសត្វមាន់ជាមធ្យមក្នុងមួយគ្រួសារ | ២៤ | ២៤ | ២៤ | ៣៣ | ២២ |

*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

**តារាង១.៤៖ សូចនាករសង្ខេបនៃសកម្មភាពវារីវប្បកម្ម និងនេសាទ**

| សកម្មភាពវារីវប្បកម្ម និងនេសាទ | | | | | |
|---|---|---|---|---|---|
| | កម្ពុជា | តំបន់វាលទំនាប | តំបន់បឹងទន្លេសាប | តំបន់ឆ្នេរសមុទ្រ | តំបន់ភ្នំនិងខ្ពង់រាប |
| ចំនួនគ្រួសារកសិកម្មដែលបានចូលរួមធ្វើវារីវប្បកម្ម (គិតជាពាន់) | ៦៨១ | ៥៥ | ១៨ | ៥ | ២ |
| ភាគរយគ្រួសារកសិកម្មដែលបានចូលរួមធ្វើវារីវប្បកម្ម | ៤% | ៧% | ៣% | ៤% | ១% |
| ចំនួនគ្រួសារកសិកម្មដែលបានចូលរួមសកម្មភាពនេសាទ (គិតជាពាន់) | ៣៨៧ | ១០៦ | ១៧៤ | ២៧ | ៨០ |
| ភាគរយគ្រួសារកសិកម្មដែលបានចូលរួមសកម្មភាពនេសាទ | ២១% | ១៤% | ២៤% | ២២% | ២៨% |

*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

តារាង១.៥៖ សូចនាករសង្ខេបនៃសកម្មភាពសេដ្ឋកិច្ច

| សកម្មភាពសេដ្ឋកិច្ច | កម្ពុជា | តំបន់វាលទំនាប | តំបន់បឹងទន្លេសាប | តំបន់ឆ្នេរសមុទ្រ | តំបន់ភ្នំនិងខ្ពង់រាប |
|---|---|---|---|---|---|
| ភាគរយនៃគ្រួសារកសិកម្មដែលមានចំណូលបានមកពីសកម្មភាពកសិកម្មទាំងស្រុង | ៥,២% | ៤,១% | ៥,៣% | ៤,២% | ៨,២% |
| ការចូលរួមចំណែកចំណូលបានពីកសិកម្មជាមួយនឹងចំណូលសរុបគ្រួសារដោយប្រៀបធៀបទៅឆ្នាំមុន៖ | | | | | |
| ភាគរយគ្រួសារបានរាយការណ៍មានចំណូលពីកសិកម្មទាបជាងឆ្នាំមុន | ២៥% | ២៣% | ២៧% | ២២% | ២៣% |
| ភាគរយគ្រួសារបានរាយការណ៍មានចំណូលពីកសិកម្មប្រហែលគ្នាឆ្នាំមុន | ៦៧% | ៧០% | ៦៣% | ៧៣% | ៧០% |
| ភាគរយគ្រួសារបានរាយការណ៍មានចំណូលពីកសិកម្មច្រើនជាងឆ្នាំមុន | ៨% | ៧% | ១០% | ៦% | ៧% |

*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

ការអង្កេតចន្លោះជំរឿនទូទៅប្រជាជននៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤ បានប៉ាន់ស្មានគ្រួសារចំនួន ៣ ៧៣៥ ៦៥៩ គ្រួសារនៅកម្ពុជាឆ្នាំ២០២៤[1]។ ដោយឡែករបាយការណ៍អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ បានប៉ាន់ប្រមាណមានគ្រួសារចំនួន ១ ៨៦៨ ១៦០ គ្រួសារ ដែលចូលរួមក្នុងវិស័យកសិកម្ម។ ដូច្នេះគ្រួសារប្រមាណ ៥០ ភាគរយ នៃគ្រួសារទាំងអស់នៅកម្ពុជាបានចូលរួមក្នុងផលិតកម្មកសិកម្ម។ ការប៉ាន់ប្រមាណចំនួន ៩ភាគរយ នៃគ្រួសារកាន់កាប់កសិកម្ម បានរាយការណ៍ពីសកម្មភាពកសិកម្មនៅលើដីជុំវិញលំនៅដ្ឋានតែប៉ុណ្ណោះ។ យោងតាមការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ បានប៉ាន់ប្រមាណចំនួនមធ្យមនៃការកាន់កាប់ក្បាលដីមានប្រមាណ ១,៧ ក្បាលដីក្នុងមួយគ្រួសារ។

គ្រួសារកសិកម្មចំនួន ៩៥ ភាគរយ ត្រូវបានរាយការណ៍ថាមានសកម្មភាពដាំដំណាំនៅទូទាំងកម្ពុជា។ ដំណាំសំខាន់ៗដែលបានដាំដុះគឺ (១) ស្រូវធម្មតា (២) ស្វាយ (៣) ដូង និង (៤) ចេក និង (៥) ស្រូវក្រអូប។ គ្រួសារកាន់កាប់កសិកម្មចំនួន ៧២ ភាគរយ ត្រូវបានរាយការណ៍ថាមានសកម្មភាពចិញ្ចឹមបសុសត្វ បសុបក្សី

[1] ចំនួនគ្រួសារយោងតាមលទ្ធផលអង្កេតចន្លោះជំរឿនទូទៅប្រជាជននៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២៤អាចទាញយកបានតាមរយៈគេហទំព័រ៖ https://www.nis.gov.kh/nis/CIPS/Cambodia%20Inter-censal%20Population%20Survey%202024.pdf)

ឬសត្វល្អិត។ គ្រួសារកសិកម្មចំនួន ៦៧៩ ០០០ ដែលបានចិញ្ចឹម គោ ក្របី ជាចម្បងក្នុងរយៈពេល ១២ ខែកន្លងមក។ គ្រួសារកសិកម្មចំនួន ១,០៣៤ លានគ្រួសារ ដែលបានរាយការណ៍ថាបានចិញ្ចឹមមាន់ជាចម្បង ក្នុងរយៈពេល១២ ខែកន្លងមក។ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ បានប៉ាន់ប្រមាណថា ៤ ភាគរយ នៃគ្រួសារកសិកម្មបានចូលរួមក្នុងសកម្មភាពវារីវប្បកម្ម និង ២១ ភាគរយបានចូលរួមក្នុងសកម្មភាពនេសាទ។

អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ បានសួរសំណួរអំពីសេដ្ឋកិច្ចជាច្រើនដល់អ្នកតបសម្ភាសន៍។ គ្រួសារកសិកម្មត្រូវបានស្នើសុំឱ្យប៉ាន់ស្មានពីចំណែកនៃប្រាក់ចំណូលសរុបក្នុងគ្រួសារ ដែលត្រូវបានគណនាដោយប្រាក់ចំណូលពីកសិកម្មរបស់ពួកគេ។ ការប៉ាន់ប្រមាណ ៥,២ ភាគរយនៃគ្រួសារកាន់កាប់កសិកម្មក្នុងគ្រួសារទាំងអស់បានរាយការណ៍ថាប្រាក់ចំណូលសរុបរបស់គ្រួសារទាំងអស់ត្រូវបានរាប់បញ្ចូលថាជាប្រាក់ចំណូលពី កសិកម្ម។

លើសពីនេះទៀត អ្នកតបសម្ភាសន៍ត្រូវបានស្នើសុំឱ្យប្រៀបធៀបប្រាក់ចំណូលកសិកម្មរបស់ពួកគេក្នុងអំឡុងពេលយោងទៅនឹងប្រាក់ចំណូលកសិកម្មរបស់ពួកគេក្នុងអំឡុងពេលឆ្នាំមុន។ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣ បានប៉ាន់ប្រមាណថា ២៥ភាគរយ នៃគ្រួសារកាន់កាប់កសិកម្មក្នុងគ្រួសារបានរាយការណ៍ពីប្រាក់ចំណូលពីកសិកម្មទាបជាងឆ្នាំមុន ៦៧ភាគរយ បានរាយការណ៍ពីប្រាក់ចំណូលពីកសិកម្មស្រដៀងនឹងឆ្នាំមុន ហើយ ៨ ភាគរយបានរាយការណ៍ពីប្រាក់ចំណូលពីកសិកម្មច្រើនជាងឆ្នាំមុន។

## ទំហំ វិសាលភាព និងការជ្រើសរើសសំណាកគំរូ

ការធ្វើអង្កេតកសិកម្មកម្ពុជាក្នុងឆ្នាំ២០២៤ នៅកម្ពុជា គឺជាកិច្ចការ ប្រមូល និងចងក្រងព័ត៌មានស្ថិតិមានលក្ខណៈស៊ីជម្រៅ ផ្ដោតលើការដាំដំណាំ ការចិញ្ចឹមបសុសត្វបសុបក្សី ការធ្វើវារីវប្បកម្ម និងនេសាទ។ ទិន្នន័យដែលប្រមូលបានពីការអង្កេតនេះមានសារៈសំខាន់បំផុតសម្រាប់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការរៀបចំផែនការ គោលនយោបាយ កម្មវិធីអភិវឌ្ឍនានាដើម្បីលើកកម្ពស់វិស័យកសិកម្មនៅកម្ពុជា។ អង្កេតកសិកម្មប្រចាំឆ្នាំ២០២៤ គឺជាការអង្កេតប្រចាំឆ្នាំលើកទីប្រាំមួយ គិតចាប់ពីការធ្វើអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១ នៅព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ២០១៩ ២០២០ ២០២១ ២០២២ ២០២៣ និង២០២៤)។

វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាស្ថាប័នរបស់រដ្ឋាភិបាលកម្ពុជា ដែលបានទទួលការអនុញ្ញាតពីរាជរដ្ឋាភិបាល និងមានភារកិច្ចទទួលខុសត្រូវក្នុងការធ្វើអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ នេះ។ វិទ្យាស្ថានជាតិស្ថិតិ មានតួនាទី និងភារកិច្ចធ្វើជំរឿន និងអង្កេត ដោយឡែកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាអ្នកប្រើប្រាស់ចម្បងនៃទិន្នន័យដែលផលិតចេញពីការអង្កេតនេះ។

## គោលបំណង

ការអង្កេតកសិកម្មកម្ពុជានេះ មានបំណងធ្វើបច្ចុប្បន្នភាពទិន្នន័យស្ដីពីសកម្មភាពកសិកម្មនៅកម្ពុជា ដែលប្រើប្រាស់ដោយអ្នករៀបចំផែនការ និងអ្នកកសាងគោលនយោបាយ។ ជាពិសេសទិន្នន័យអង្កេតនេះ ផ្ដល់សារៈប្រយោជន៍៖

១. ការផ្ដល់នូវបច្ចុប្បន្នភាពនៃបញ្ជីមេសំណាកគំរូ (Sampling Frame) សម្រាប់ការធ្វើអង្កេតកសិកម្មកម្ពុជា
២. ការផ្ដល់ទិន្នន័យនៅកម្រិតថ្នាក់ជាតិ និងកម្រិតតំបន់ ក្នុងនោះទិន្នន័យមួយចំនួនក៏មាននៅថ្នាក់ខេត្ត
៣. ការផ្ដល់ទិន្នន័យអំពីរចនាសម្ព័ន្ធបច្ចុប្បន្ននៃការកាន់កាប់កសិកម្មនៅកម្ពុជា ដូចជា ការដាំដំណាំ ការចិញ្ចឹមបសុសត្វ និងបសុបក្សី ព្រមទាំងការធ្វើសកម្មភាពវារីវប្បកម្ម និងនេសាទផងដែរ។

វិសាលភាពគ្របដណ្ដប់ពេញលេញនៃការអង្កេតនេះ អាចត្រូវបានពិនិត្យនៅក្នុងព័ត៌មានលម្អិតនៃកម្រងសំណួរដែលមាននៅលើគេហទំព័រ (https://www.nis.gov.kh)។

ទិន្នន័យទាំងនេះបង្កើតសក្ដានុពលសម្រាប់ការវិភាគទូលំទូលាយដែលអាចធំជាងវិសាលភាពនៃរបាយការណ៍នេះ។ គួរកត់សម្គាល់ថា របាយការណ៍នេះរួមបញ្ចូលទិន្នន័យនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងទិន្នន័យនៅថ្នាក់ខេត្ត ដែលមានជាតារាងលម្អិតនៅលើគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ (https://microdata.nis.gov.kh/index.php) ។

## វិធីសាស្ត្រ

ការអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩ និងការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ ប្រើប្រាស់សំណាកគំរូដូចគ្នា។ ស្រដៀងគ្នានោះដែរការធ្វើអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១ និងការធ្វើអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣ បានប្រើប្រាស់សំណាកគំរូដូចគ្នា។ ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១ ប្រើប្រាស់មណ្ឌលជំរឿន

ជាគោលជ្រើសរើសចេញពីជំរឿនទូទៅប្រជាជននៅកម្ពុជាឆ្នាំ២០១៩។ គ្រួសារដែលរស់នៅក្នុងមណ្ឌលជំរឿនទាំងនោះត្រូវបានចុះបញ្ជីគ្រួសារ ដើម្បីស្វែងរកសកម្មភាពកសិកម្មទាំងឡាយដែលមាន ដោយប្រើព័ត៌មាននេះ ជាមូលដ្ឋានគ្រួសារកសិកម្មត្រូវបានចាត់ថ្នាក់ និងជ្រើសរើសយកជាសំណាកគំរូ សម្រាប់ការប្រមូលទិន្នន័យបន្ថែម។ ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ មិនមានសកម្មភាពពិនិត្យលក្ខណៈបុគ្គលទេ ប៉ុន្តែជំនួសមកវិញ ដោយការជ្រើសរើសសំណាកគំរូភូមិ នៅទូទាំងកម្ពុជាពីបញ្ជីសំណាកគំរូជំរឿនកសិកម្មឆ្នាំ២០២៣។ គ្រួសារនៅក្នុងតំបន់ភូមិទាំងនេះត្រូវបានពិនិត្យសម្រាប់សកម្មភាពកសិកម្មណាមួយ ដោយប្រើព័ត៌មានមូលដ្ឋាននេះ គ្រួសារកសិកម្មត្រូវបានតម្រៀប និងយកគំរូសម្រាប់ការប្រមូលទិន្នន័យបន្ថែម។

មន្ត្រីសម្ភាសន៍ត្រូវបានជ្រើសរើសមកពីមន្ទីរផែនការ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត។ មន្ត្រីត្រួតពិនិត្យនៅមណ្ឌលសម្ភាសន៍ ( FS ) និងមន្ត្រីត្រួតពិនិត្យគុណភាពទិន្នន័យ ( DS ) ត្រូវបានជ្រើសរើសពីវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ មន្ត្រីសម្ភាសន៍ និងមន្ត្រីត្រួតពិនិត្យទាំងអស់ត្រូវបានធ្វើការបណ្តុះបណ្តាលមុននឹងចុះប្រតិបត្តិការអង្កេតនេះ។ កិច្ចខិតខំប្រឹងប្រែងរួមគ្នារវាងក្រសួងទាំងពីរ បានធ្វើឡើងនៅទូទាំងកម្ពុជា ចាប់តាំងពីការប្រមូលទិន្នន័យរហូតដល់ការវិភាគ និងចងក្រងទិន្នន័យ។

ការប្រមូលទិន្នន័យអង្កេតនេះ ត្រូវបានធ្វើឡើងដោយប្រើប្រាស់វិធីសាស្ត្រសម្ភាសន៍អ្នកផ្តល់ចម្លើយដោយផ្ទាល់ និងប្រើប្រាស់ម៉ាស៊ីនថេប្លេត។ បញ្ជីសំណួរសម្រាប់ការអង្កេតនេះត្រូវបានបង្កើតឡើងនៅក្នុងកម្មវិធីអង្កេត (Survey Solutions) របស់ធនាគារពិភពលោក។ ការប្រើប្រាស់កម្មវិធីកាពី (CAPI) សម្រាប់សម្ភាសន៍ គឺចំណេញពេលវេលា មិនចំណាយលើការវាយបញ្ចូលទិន្នន័យ បង្កើនសមត្ថភាពចំណេះដឹងជំនាញលើបច្ចេកវិទ្យាកុំព្យូទ័រ និងការត្រួតពិនិត្យគុណភាព និងមានលទ្ធភាពទាញតារាងស្ថិតិធ្វើការវិភាគទិន្នន័យបានឆាប់រហ័សជាងមុន។

## វិសាលភាពនៃការអង្កេត

កម្រងសំណួរបានប្រមូលទិន្នន័យផ្តោតលើទិដ្ឋភាពមួយចំនួននៃការកាន់កាប់កសិកម្ម រួមទាំងព័ត៌មានប្រជាសាស្ត្រ សហកម្មសិទ្ធិករ សមាជិកគ្រួសារ សកម្មភាពផលិតកម្មដំណាំ ការចិញ្ចឹមបសុសត្វ បសុបក្សី សកម្មភាពវារីវប្បកម្ម និងនេសាទ បរិស្ថាន ស្ថានភាពសេដ្ឋកិច្ចក្នុងអំឡុងពេល១២ខែកន្លងមក ដែលប្រើប្រាស់នៅក្នុងកសិដ្ឋាន ព័ត៌មានអំពីលំនៅឋាន និងទ្រព្យសម្បត្តិគ្រួសារ។

អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤នេះ រួមបញ្ចូលម៉ូឌុលចុងក្រោយនៃវិធីសាស្ត្រផ្តួចផ្តើមពីគម្រោង ៥០x២០៣០ គឺម៉ូឌុល "គ្រឿងចក្រឧបករណ៍ និងទ្រព្យសម្បត្តិ (MEA)"។ នេះគឺបន្ទាប់ពីម៉ូឌុលប្រាក់ចំណូលការងារ និងផលិតភាព (ILP) នៅក្នុងអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១ និងម៉ូឌុលផលិតកម្ម និងបរិស្ថាន (PME) ក្នុងឆ្នាំ២០២២ (អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣ ដែលស្ថិតនៅក្នុងឆ្នាំជំរឿន រួមបញ្ចូលតែម៉ូឌុលស្នូល ហើយមិនរួមបញ្ចូលម៉ូឌុលបង្វិលណាមួយទេ)។

## ទីតាំងភូមិសាស្ត្រគ្របដណ្ដប់

សំណាកគំរូគ្រួសារកសិកម្ម ដែលរស់នៅទូទាំងប្រទេស ត្រូវបានជ្រើសរើសយកមកធ្វើការសម្ភាស លើកលែងខណ្ឌចំនួន៦នៅរាជធានីភ្នំពេញ ក្រុងចំនួន១ នៅខេត្តព្រះសីហនុ និងក្រុងចំនួន១ នៅខេត្តសៀមរាប ត្រូវបានចាត់ជាទីប្រជុំជន និងមិនបានរាប់បញ្ចូលក្នុងការអង្កេតនេះទេ។ គ្រួសារកសិកម្មគឺមានសក្ដានុពលក្នុងការជ្រើសរើសជាសំណាកគំរូ សម្រាប់ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ ក៏ដូចជាការអង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ២០១៩ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២០ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២១ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២២ កសិកម្មកម្ពុជាឆ្នាំ២០២៣ ផងដែរ។ ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ ត្រូវបានជ្រើសរើសសំណាកគំរូគ្រួសារកសិកម្មសរុបចំនួន១៥ ៦២២ ត្រូវបានសម្ភាសន៍ផងដែរ។

បន្ថែមពីលើការអង្កេតគ្រួសារ កិច្ចការប្រមូលទិន្នន័យធ្វើដាច់ដោយឡែកសំដៅលើសហគ្រាសកសិកម្មធំៗ ដែលដំណើរការដោយសាជីវកម្ម សហគមន៍ និងស្ថាប័នរដ្ឋាភិបាល ឬឯកជន ដែលសំដៅដល់ការកាន់កាប់លក្ខណៈសហគ្រាសខ្នាតធំ នៅក្នុងវិស័យមិនមែនលក្ខណៈគ្រួសារ។ ការប្រមូលនេះត្រូវបានបង្កើតឡើងតាមរយៈជំរឿនមិនមែនលក្ខណៈគ្រួសារដែលគេស្គាល់ និងអាចចូលប្រើបាន។ ទោះជាយ៉ាងណាវាត្រូវបានទទួលស្គាល់ថាសហគ្រាសទាំងអស់មិនស្ថិតនៅក្នុងប្រទេសដែលអាចត្រូវបានរាប់បញ្ចូលនោះទេ ដោយសារតែបញ្ហាប្រឈមនៃដំណើរការ។ បញ្ជីនៃការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំត្រូវបានចងក្រងពីអ្នកដែលត្រូវបានកំណត់នៅក្នុងកិច្ចការអង្កេត និងជំរឿនពីមុន រួមជាមួយនឹងការកាន់កាប់ថ្មីដែលត្រូវបានរាយការណ៍ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ សរុបមក ទិន្នន័យត្រូវបានប្រមូលពីសហគ្រាសកសិកម្មខ្នាតធំចំនួន៥២០ ដែលមានសារៈសំខាន់ជាងនៅក្នុងជុំមុន ដែលមានសហគ្រាសប្រហែល៣០០ ទៅ៤០០។

## កម្រងសំណួរអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤

អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ ត្រូវបានធ្វើឡើងតាមរយៈការសម្ភាសផ្ទាល់ទល់មុខគ្នាដោយប្រើម៉ាស៊ីនកុំព្យូទ័រ ដែលបានបង្កើតជាកម្រងសំណួរជាភាសាអង់គ្លេស និងភាសាខ្មែរ និងបានចែករំលែកនៅលើគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិ (http://www.nis.gov.kh/index.php/km/) គឺអាចទាញចេញពីកម្មវិធីនេះបាន។

## ពេលវេលា និងរយៈពេលយោងនៃអង្កេត

អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ ត្រូវបានធ្វើឡើងដោយផ្ដោតទៅលើការកាន់កាប់កសិកម្មលក្ខណៈគ្រួសារ ហើយសកម្មភាពប្រមូលទិន្នន័យនៅក្នុងអំឡុងខែវិច្ឆិកា ដល់ខែធ្នូ ឆ្នាំ២០២៤។

រយៈពេលយោងនៃការអង្កេតគឺសួរក្នុង១២ខែកន្លងមក ដោយគិតចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ ត្រូវបានកំណត់ជាកាលបរិច្ឆេទយោងសម្រាប់ការប្រមូលទិន្នន័យនេះ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយសូចនាករមួយចំនួនបានបញ្ជាក់ពេលវេលាជាក់លាក់ ដោយមិនបានប្រើកាលបរិច្ឆេទយោងទេ ហេតុដូច្នេះសម្រាប់ទិន្នន័យអំពីសូចនាករនោះប្រើប្រាស់ទៅតាមការចាំបាច់។ ឧទាហរណ៍៖ ចំនួនបសុសត្វ បសុបក្សីដែលមាននៅថ្ងៃសម្ភាសន៍ ដោយគិតយកថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៤ ជាកាលបរិច្ឆេទយោង។

## គំរោងបញ្ជីសំណាកគំរូ

ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ បញ្ជីសំណាកគំរូជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣ (CAC 2023) ត្រូវបានយកមកប្រើប្រាស់។ បញ្ជីសំណាកនេះមានភូមិប្រមាណ ១៤ ៥០០ សម្រាប់ភូមិនីមួយៗមានការប្រមូលយកព័ត៌មានដូចតទៅ៖ រាជធានី/ខេត្ត ក្រុង/ខណ្ឌ/ស្រុក ឃុំ/សង្កាត់ (ជនបទ/ទីប្រជុំជន) និងចំនួនគ្រួសារសរុប។ គោលដៅប្រជាជន គឺគ្រួសារដែលប្រកបរបរកសិកម្ម វារីវប្បកម្ម និង/ឬនេសាទ។ មានភូមិមួយចំនួននៅទីជនបទដែលស្ថិតនៅក្នុងក្រុង/ស្រុកទីប្រជុំជនមិនត្រូវបានរាប់បញ្ចូលក្នុងការជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣៖

- រាជធានីភ្នំពេញ ខណ្ឌចំការមន
- រាជធានីភ្នំពេញ ខណ្ឌដូនពេញ
- រាជធានីភ្នំពេញ ខណ្ឌ៧មករា
- រាជធានីភ្នំពេញ ខណ្ឌទួលគោក
- រាជធានីភ្នំពេញ ខណ្ឌមានជ័យ
- រាជធានីភ្នំពេញ ខណ្ឌសែនសុខ
- រាជធានីភ្នំពេញ ខណ្ឌឫស្សីកែវ
- រាជធានីភ្នំពេញ ខណ្ឌពោធិ៍សែនជ័យ
- រាជធានីភ្នំពេញ ខណ្ឌច្បារអំពៅ
- រាជធានីភ្នំពេញ ខណ្ឌជ្រោយចង្វារ
- រាជធានីភ្នំពេញ ខណ្ឌបឹងកេងកង

មិនដូចទៅនឹងការអង្កេតឆ្នាំមុនៗ សម្រាប់ការធ្វើអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ ដើម្បីអនុវត្តតាមរយៈការជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣ (CAC 2023) បានកំណត់យកកម្រិតអប្បបរមាមួយ ដើម្បីកំណត់គ្រួសារដែលចូលរួមក្នុងសកម្មភាពកសិកម្ម។ ដោយគ្រួសារនីមួយៗនឹងត្រូវជ្រើសរើសសម្រាប់អង្កេត ប្រសិនបើគ្រួសារទាំងនោះដាំដំណាំលើផ្ទៃដីយ៉ាងហោចណាស់ ០,០៣ ហិកតា និង/ឬមានបសុសត្វធំចំនួន ២ និង/ឬបសុសត្វតូចចំនួន ៣ និង/ឬ បសុបក្សីចំនួន ២៥ ក្បាលយ៉ាងតិច។ សម្រាប់ដំណើរការអង្កេតកសិកម្មកម្ពុជាប្រចាំឆ្នាំ គឺមិនបានកំណត់លើទំហំផ្ទៃដីអតិបរិមាទេ ចំនួនបសុសត្វ បសុបក្សីដែលមានចិញ្ចឹមមានចំនួនតិចក៏ចាត់ជាគ្រួសារកសិកម្មផងដែរ ធ្វើដូចនេះដើម្បីផ្តល់ឱកាសដល់គ្រួសារកសិកម្មតូចៗត្រូវបានជ្រើសរើសជាសំណាកគំរូក្នុងអង្កេតនេះ។ ទោះបីជាយ៉ាងណាក៏ដោយ ដោយផ្អែកលើនីតិវិធី នៃការជ្រើសយកសំណាកត្រូវបានពន្យល់លម្អិតខាងក្រោម ការកាន់កាប់កសិកម្មជាលក្ខណៈគ្រួសារដែលមានផ្ទៃដីធំ ឬចំនួនបសុសត្វ ឬបសុបក្សីច្រើនត្រូវបានកំណត់អត្តសញ្ញាណ និងបញ្ចូលក្នុងក្រុមសំណាកផ្សេងគ្នា ដើម្បីអាចជ្រើសយកបានគ្រួសារកសិកម្មទាំងនោះ។

## វិធីសាស្ត្រជ្រើសរើសសំណាកគំរូ

ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ ប្រើប្រាស់វិធីសាស្ត្រជ្រើសរើសសំណាកគំរូពីរដំណាក់កាលគឺ ដំណាក់កាលទី១ ជ្រើសរើសយកភូមិ និងដំណាក់កាលទី២ ជ្រើសរើសយកគ្រួសារកសិកម្ម។ ភូមិជំរឿន ចំនួន ១ ៣៥៥ ត្រូវបានជ្រើសរើសសម្រាប់ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ ហើយភូមិអង្កេតនីមួយៗ ត្រូវបានជ្រើសយកចំនួន ១២ គ្រួសារកសិកម្ម សម្រាប់ធ្វើការសម្ភាសប្រមូលព័ត៌មានលម្អិត។ ដូច្នេះអង្កេត កសិកម្មកម្ពុជាឆ្នាំ២០២៤ បានជ្រើសរើសទំហំគ្រួសារសំណាកគំរូសរុបចំនួន ១៦ ២៦០ គ្រួសារ (គ្រួសារ ចំនួន១៨ ៩៥៨ ត្រូវបានរួមបន្ថែមអ្នកឆ្លើយតបក្នុងករណីកម្រិតខុចខាតនៃសំណាកគំរូពីជំរឿនកសិកម្ម ឆ្នាំ២០២៣មានភាពកម្រិតខ្ពស់)សរុបចំនួន ១៥ ៦២២ គ្រួសារកសិកម្មដែលត្រូវបានសម្ភាសន៍ដោយជោគជ័យ ភូមិអង្កេតចំនួន ១ ៣៥៥ ត្រូវបានបែងចែកទៅខេត្តជាដែនស្ថិតិ (Statistical Domains) តាមសមាមាត្រទៅ នឹងចំនួនគ្រួសារនៅជនបទ។ តារាងទី១ ខាងក្រោមបង្ហាញបំណែងចែកស្ដីពីការជ្រើសរើសសំណាកគំរូ សម្រាប់អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤។ ភូមិជំរឿននៅក្នុងរាជធានី ខេត្ត ឈ្មោះភូមិទាំងអស់ត្រូវបានតម្រៀប តាមលំដាប់លេខកូដភូមិសាស្ត្រ ស្រុក ឃុំ និងដៅសម្គាល់ថា ភូមិស្ថិតនៅទីជនបទ-ទីប្រជុំជនបន្ទាប់មកធ្វើ ការជ្រើសរើសសំណាកជាលក្ខណៈប្រព័ន្ធចៃដន្យតាមទំហំគ្រួសារដោយគិត សមាមាត្រប្រហាក់ប្រហែលគ្នា។

**តារាង១.៦ ការបែងចែកសំណាកគំរូ**

| រាជធានី ខេត្ត | ចំនួនសរុបនៃគ្រួសារកសិកម្មពីជំរឿនកសិកម្ម ឆ្នាំ២០២៣ | ចំនួនភូមិ ដែលបានជ្រើសរើសសំណាកគំរូ CAS ២០២៤ | ចំនួនគ្រួសារកសិកម្មដែលបានសម្ភាសន៍ CAS ២០២៤ |
|---|---|---|---|
| **តំបន់វាលទំនាប** | ៧៣២ ៣១៤ | ៥៥០ | ៦ ៣៩១ |
| ភ្នំពេញ | ៦ ២៣៨ | ៤៥ | ៥៤០ |
| ព្រៃវែង | ១៧៧ ៩៤១ | ១៣១ | ១ ៥០៩ |
| ស្វាយរៀង | ១១០ ៩៩១ | ៥៩ | ៦៧៥ |
| តាកែវ | ១៥៣ ១៦២ | ៨៩ | ១ ០៤៦ |
| ត្បូងឃ្មុំ | ៩៤ ៣៩០ | ៧២ | ៨៤៨ |
| កណ្ដាល | ៦៩ ៤០១ | ៧៨ | ៨៦៤ |
| កំពង់ចាម | ១២០ ១៩១ | ៧៦ | ៩០៩ |
| **តំបន់បឹងទន្លេសាប** | ៧០៧ ២៤០ | ៤៥០ | ៥ ១១៣ |
| ប៉ៃលិន | ១០ ១៨១ | ២៦ | ៣១០ |

| | | | |
|---|---|---|---|
| បន្ទាយមានជ័យ | ១២៧ ៦១៣ | ៦០ | ៦៩២ |
| បាត់ដំបង | ១២១ ៦២៩ | ៩៥ | ៩៨៤ |
| ឧត្តរមានជ័យ | ៣៣ ៩២១ | ២២ | ២៤២ |
| សៀមរាប | ១២៩ ៥៤៦ | ៧៤ | ៨៧១ |
| កំពង់ឆ្នាំង | ៩២ ៩៣៨ | ៥៦ | ៦៤៧ |
| កំពង់ធំ | ៩៦ ៨៨៤ | ៧២ | ៨៥០ |
| ពោធិ៍សាត់ | ៩៤ ៥២៨ | ៤៥ | ៥១៧ |
| **តំបន់ឆ្នេរសមុទ្រ** | ១២៤ ១៥០ | ១៤១ | ១ ៦៤៧ |
| កំពត | ៩៩ ២៦៦ | ៨៤ | ៩៨៦ |
| កែប | ៥ ០៣៥ | ១៣ | ១៥៤ |
| កោះកុង | ១៣ ៨៨៣ | ២៦ | ២៩១ |
| ព្រះសីហនុ | ៥ ៩៦៦ | ១៨ | ២១៦ |
| **តំបន់ភ្នំ និងខ្ពង់រាប** | ២៨៦ ១០០ | ២១៤ | ២ ៤៧១ |
| កំពង់ស្ពឺ | ១១៨ ១៧០ | ៧៦ | ៨៨៥ |
| ក្រចេះ | ៥៣ ១៣៧ | ៣៩ | ៤៥៧ |
| មណ្ឌលគិរី | ១៤ ៦៧២ | ១៩ | ២១១ |
| ព្រះវិហារ | ៣៩ ៤៨៥ | ៣២ | ៣៧២ |
| រតនគិរី | ៣៦ ៣៦៣ | ២៩ | ៣៣៨ |
| ស្ទឹងត្រែង | ២៤ ២៧៣ | ១៩ | ២០៨ |
| **សរុប** | ១ ៨៤៩ ៨០៤ | ១ ៣៥៥ | ១៥ ៦២២ |

*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

## វិធីសាស្ត្រគណនាមេគុណ និងការប៉ាន់ស្មាន

នីតិវិធីនៃការជ្រើសរើសសំណាកគំរូ និងការចាត់ថ្នាក់ ដូចដែលបានរៀបរាប់លម្អិតខាងលើ បានបង្ហាញថាមានប្រូបាប៊ីលីតេនៃការជ្រើសរើសគ្រួសារកសិកម្មមានក្នុងកម្រិតខុសៗគ្នា។ ដោយពិចារណាចំណុចនេះ ការគណនាមេគុណត្រូវបានធ្វើឡើង សម្រាប់គ្រួសារកសិកម្មនីមួយៗនៅក្នុងសំណាក និងបានអនុវត្តចំពោះទិន្នន័យដែលបានរាយការណ៍សម្រាប់កំណត់ត្រានោះ។ មេគុណសម្រាប់អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ ត្រូវបានកែតម្រូវសម្រាប់ករណីគ្មានចម្លើយ និងការខូចគុណភាព ហើយបានក្រិតតាមខ្នាត ដោយប្រើចំនួនគ្រួសារកសិកម្មតាមខេត្តដែលទទួលបានតាមរយៈជំរឿនកសិកម្មកម្ពុជាឆ្នាំ២០២៣ (CAC2023)។ ជាចុងក្រោយទិន្នន័យដែលបានរាយការណ៍នេះ ត្រូវបានបូកសរុបនៅកម្រិតខេត្ត តំបន់ និងថ្នាក់ជាតិ។

## វិធីសាស្ត្រនៃការធ្វើអង្កេត

ទិន្នន័យទាំងអស់នៅក្នុងអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ ត្រូវបានប្រមូលទិន្នន័យតាមរយៈការបញ្ជូនមន្ត្រីសម្ភាសន៍ទៅសម្ភាសន៍ដោយផ្ទាល់ជាលក្ខណៈបុគ្គល ដោយប្រើកុំព្យូទ័រ (CAPI) ជាជំនួយ ដោយមានមន្ត្រីត្រួតពិនិត្យគុណភាពទិន្នន័យ និងមន្ត្រីត្រួតពិនិត្យនៅមណ្ឌលសម្ភាសន៍ជាអ្នកត្រួតពិនិត្យផ្ទាល់ ដោយទទួលបានការបណ្តុះបណ្តាលច្បាស់លាស់ ហើយអ្នកឆ្លើយតបសម្ភាសន៍ជាបុគ្គលពេញវ័យ មានចំណេះដឹងគ្រប់គ្រាន់អំពីសកម្មភាពកសិកម្មក្នុងកសិដ្ឋាន អ្នកឆ្លើយតបសម្ភាសន៍ជាម្ចាស់កសិដ្ឋានត្រូវបានផ្តល់អាទិភាពឱ្យចូលរួម។ ក្នុងករណីម្ចាស់កសិដ្ឋានអវត្តមាន មន្ត្រីសម្ភាសន៍អាចសម្ភាសន៍ ប្តី/ប្រពន្ធ ឬសមាជិកគ្រួសារ ដែលមានចំណេះដឹង អាចឆ្លើយតបសម្ភាសន៍បានផងដែរ។ មានការណែនាំថា ពុំត្រូវធ្វើសម្ភាសន៍ ឬសួរព័ត៌មានពីអ្នកជិតខាង ឬគ្រួសារផ្សេងទៀតឡើយ អំពីការកាន់កាប់កសិកម្មដែលកំពុងស្ថិតក្នុងការអង្កេតនេះ។

ទិន្នន័យក្នុងការអង្កេតនេះត្រូវបានសម្ភាសន៍ដោយប្រើប្រាស់កម្រងសំណួរគោល ដែលមានពន្យល់លម្អិតនៅក្នុងឯកសារសៀវភៅណែនាំមន្ត្រីសម្ភាសន៍នៃអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ ដែលចែងពីទស្សនទាននិយមន័យ និងនីតិវិធីដែលត្រូវអនុវត្ត សម្រាប់ការប្រមូលទិន្នន័យ។ សេចក្តីព្រាងកម្រងសំណួរ និងឯកសារណែនាំ ត្រូវបានរៀបចំឡើងដោយផ្អែកលើអនុសាសន៍អំពីតម្រូវការទិន្នន័យ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងគម្រោងគំនិតផ្តួចផ្តើម ៥០ x ២០៣០ ដើម្បីបំពេញកង្វះខាតទិន្នន័យកសិកម្ម។ កម្រងសំណួរ និងឯកសារណែនាំស្តីពីការប្រមូលទិន្នន័យនៃអង្កេតកសិកម្មកម្ពុជា ត្រូវបានកែសម្រួលដោយផ្អែកលើបទពិសោធន៍ និងលទ្ធផលដែលទទួលបានក្នុងអំឡុងពេលសម្ភាសន៍សាកល្បងចំនួនពីរដង។ ឯកសារណែនាំមន្ត្រីសម្ភាសន៍នៃអង្កេតកសិកម្មកម្ពុជា ត្រូវបានបំពេញបន្ថែមដោយការត្រួតពិនិត្យលើភាពស៊ីសង្វាក់គ្នានៃទិន្នន័យ ដែលធ្វើឡើងពីចម្ងាយដោយក្រុមអ្នកគ្រប់គ្រងទិន្នន័យ និងនៅក្នុងដំណើរការផ្ទៀងផ្ទាត់ទិន្នន័យជាបន្តបន្ទាប់នៅពេលក្រោយមក។

ទិន្នន័យដែលប្រមូលបានទាំងអស់ ត្រូវបានរក្សាទុកនៅលើម៉ាស៊ីនមេ (Cloud Server) របស់ Amazon អ្នកគ្រប់គ្រងម៉ាស៊ីនមេ អាចទាញយកទិន្នន័យនេះក្នុងទម្រង់ផ្សេងៗ នៅពេលណាមួយក្នុងអំឡុងពេលប្រមូលទិន្នន័យ និងរហូតដល់ខែឧសភា ឆ្នាំ២០២៤ នៅពេលដែលម៉ាស៊ីនមេត្រូវបានបិទ។

## យន្តការជំនួយក្នុងការសម្ភាស

មុននឹងចាប់ផ្តើមចុះសម្ភាសន៍ប្រមូលទិន្នន័យតាមមូលដ្ឋាន គម្រោងអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ បានទទួលលិខិតអនុញ្ញាតពីថ្នាក់ដឹកនាំក្រសួងផែនការ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីចែកជូនដល់មន្ត្រីនៅមូលដ្ឋាន និងអ្នកតបសម្ភាសន៍ទៅតាមការចាំបាច់ ដើម្បីទទួលកិច្ចសហការពីគ្រប់គ្រួសារសម្ភាសន៍ និងសហគ្រាសកសិកម្មនានាដែល ធ្វើសកម្មភាពកសិកម្មនៅក្នុងប្រទេស។

## ប្រតិបត្តិការប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យទាំងអស់សម្រាប់អង្កេតកសិកម្មកម្ពុជាបានធ្វើឡើង ដោយមន្ត្រីសម្ភាសន៍ដែលបានទទួលការបណ្តុះបណ្តាលអំពីវិធីប្រមូលទិន្នន័យ ហើយមន្ត្រីសម្ភាសន៍ត្រូវបានជ្រើសរើសពីក្នុងចំណោមមន្ត្រីដែលមានសមត្ថភាពនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត នៃក្រសួងផែនការ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយផ្អែកលើការសម្ភាសជម្រុះ។ ដោយសារអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ ពាក់ព័ន្ធនឹងការប្រមូលទិន្នន័យពីការកាន់កាប់កសិកម្មជាលក្ខណៈគ្រួសារ និងការកាន់កាប់សហគ្រាសកសិកម្មខ្នាតធំ ការបណ្តុះបណ្តាលនេះត្រូវបានបែងចែក២វគ្គ គឺវគ្គទី១៖ បណ្តុះបណ្តាលគ្រូបង្គោល ដែលមានមន្ត្រីត្រួតពិនិត្យគុណភាពទិន្នន័យ និងត្រួតពិនិត្យនៅមណ្ឌលសម្ភាសន៍ទាំងអស់ចូលរួម នៅទីស្តីការក្រសួងផែនការ និងវគ្គទី២៖ គឺការបណ្តុះបណ្តាលមន្ត្រីសម្ភាសន៍ ដែលធ្វើឡើងនៅតាមរាជធានីខេត្ត។ មន្ត្រីទាំងអស់ទទួលបានការបណ្តុះបណ្តាលដ៏ទូលំទូលាយអំពីទស្សនទាន និយមន័យ និងនីតិវិធីសម្រាប់ការប្រមូលទិន្នន័យ។

មន្ត្រីត្រួតពិនិត្យគុណភាពទិន្នន័យ មានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យគុណភាពទិន្នន័យ។ សម្រាប់គម្រោងនេះទាំងមូលមាន អ្នកគ្រប់គ្រងទិន្នន័យចំនួន ៨៦នាក់ ដែលជាមន្ត្រីមកពីវិទ្យាស្ថានជាតិស្ថិតិ។ មន្ត្រីត្រួតពិនិត្យនៅមណ្ឌលសម្ភាសន៍ មានភារៈទទួលខុសត្រូវក្នុងការជួយមន្ត្រីសម្ភាសន៍ ក្នុងការដោះស្រាយបញ្ហានៅតាមភូមិសាស្ត្រ លើកទឹកចិត្តឱ្យមានទំនាក់ទំនងល្អជាមួយបុគ្គលទាក់ទងនៅតាមភូមិ និងជំរុញកិច្ចសហប្រតិបត្តិការពីគ្រួសារកសិកម្មដែលជាអ្នកផ្តល់ចម្លើយ។ សម្រាប់គម្រោងនេះ មានមន្ត្រីត្រួតពិនិត្យនៅភូមិសម្ភាសន៍ចំនួន ៤៦នាក់ ក្នុងនោះ ២៤នាក់មកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង២២ នាក់មកពីវិទ្យាស្ថានជាតិស្ថិតិ ។ មន្ត្រីសម្ភាសន៍សរុបទាំងអស់មាន ៣៣៧នាក់ ក្នុងនោះ ១៩៧នាក់មកពីមន្ទីរផែនការរាជធានី ខេត្ត និង ១៤០នាក់ជាមន្ត្រីមកពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី ខេត្តផងដែរ។ មន្ត្រីសរុបទាំងអស់មានចំនួន ៤២៩នាក់បានចូលរួមក្នុងការចុះប្រមូលទិន្នន័យ ប៉ុន្តែមានមន្ត្រីចំនួនច្រើនជាងនេះបានទទួលការបណ្តុះបណ្តាល ដោយមួយចំនួនត្រូវបានរក្សាទុកជាមន្ត្រីបម្រុងសម្រាប់គម្រោងកសិកម្មនេះ។ លើសពីនេះទៀត មន្ត្រីមកពីវិទ្យាស្ថានជាតិស្ថិតិចំនួន ១១ នាក់ នៅស្នាក់ការកណ្តាល (HQ) បានទទួលការបណ្តុះបណ្តាលអំពីការប្រើប្រាស់កម្មវិធី (Survey Solutions) ដើម្បីពិនិត្យ និងសម្រេចទទួលយកតារាងសំណួរចុងក្រោយពីមន្ត្រីសម្ភាសន៍។

លទ្ធផលនៃអង្កេតកសិកម្មកម្ពុជាប្រកបដោយគុណភាព គឺអាស្រ័យទៅលើដំណើរការ សម្ភាសន៍កត់ត្រាប្រមូលទិន្នន័យពីគ្រួសារកាន់កាប់កសិកម្ម ។ ទោះបីជាការបណ្តុះបណ្តាលបានធ្វើឡើងយ៉ាងត្រឹមត្រូវ ហើយដំណើរការ ប្រមូលទិន្នន័យបានប្រព្រឹត្តទៅយ៉ាងមានប្រសិទ្ធភាពក៏ដោយ ប្រសិនបើក្នុងអំឡុងពេលដំណើរការ

ប្រមូលទិន្នន័យ គ្មានការត្រួតពិនិត្យគុណភាពដោយប្រសិទ្ធភាពទេនោះ ទិន្នន័យចុងក្រោយនឹងនៅតែគ្មានគុណភាព។ អង្កេតកសិកម្មកម្ពុជា មានការត្រួតពិនិត្យ និងមធ្យោបាយទំនាក់ទំនងជាច្រើនកម្រិត ដូចដែលបានចែងលម្អិតក្នុងឯកសារណែនាំមន្ត្រីសម្ភាសន៍នៃការអង្កេតកសិកម្មកម្ពុជា។ តួនាទីសម្រាប់ការត្រួតពិនិត្យ និងការទាក់ទង ត្រូវបានបង្កើតឡើងរួមជាមួយគោលការណ៍ណែនាំយ៉ាងទូលំទូលាយ ដែលរំលេចចេញនូវសកម្មភាពខុសៗគ្នា និងនីតិវិធីត្រួតពិនិត្យគុណភាព ដើម្បីតាមដានវឌ្ឍនភាពនៃការកត់ត្រាទិន្នន័យឱ្យបានត្រឹមត្រូវសម្រាប់អង្កេតកសិកម្មកម្ពុជា និងដើម្បីអាចរកឃើញបញ្ហាណាមួយភ្លាមៗ នៅក្នុងពេលចុះប្រមូលទិន្នន័យ។ ការប្រើប្រាស់ CAPI សម្រាប់ប្រមូលទិន្នន័យ អាចមានភាពងាយស្រួលក្នុងការត្រួតពិនិត្យទិន្នន័យទាន់ពេលវេលានូវលំហូរ និងគុណភាពទិន្នន័យ។

## ការប្រព្រឹត្តិកម្មទិន្នន័យ

បន្ទាប់ពីការសម្ភាសគ្រួសារកសិកម្មបានបញ្ចប់ មន្ត្រីសម្ភាសន៍ត្រូវបញ្ជូនកម្រងសំណួរដែលបានបំពេញរួចតាមកម្មវិធី Survey Solutions ទៅកាន់មន្ត្រីត្រួតពិនិត្យគុណភាពទិន្នន័យ ដោយមានការត្រួតពិនិត្យយ៉ាងហ្មត់ចត់ ប្រសិនបើរកឃើញកំហុស ឬទិន្នន័យដែលគួរសង្ស័យ មន្ត្រីត្រួតពិនិត្យគុណភាពទិន្នន័យនឹងបញ្ជូនកម្រងសំណួរត្រឡប់ទៅឱ្យមន្ត្រីសម្ភាសន៍វិញ ដោយសរសេរមូលហេតុបញ្ជាក់ ដើម្បីសម្ភាសន៍ឡើងវិញជាមួយអ្នកតបសម្ភាសន៍តាមការចាំបាច់ ហើយបញ្ជូនមកមន្ត្រីត្រួតពិនិត្យគុណភាពវិញ។ នៅពេលមន្ត្រីត្រួតពិនិត្យគុណភាពទិន្នន័យបានផ្ទៀងផ្ទាត់តារាងសំណួរត្រឹមត្រូវ ហើយសម្រេចបញ្ជូនតារាងសំណួរទៅឱ្យមន្ត្រីស្នាក់ការកណ្តាលជាអ្នកសម្រេចចុងក្រោយ។

ប្រសិនបើក្នុងអំឡុងពេលត្រួតពិនិត្យនេះ មន្ត្រីនៅទីស្នាក់ការកណ្តាលរកឃើញមានកំហុសណាមួយ ឬទិន្នន័យគួរឱ្យសង្ស័យ តារាងសំណួរនោះអាចត្រូវបញ្ជូនទៅមន្ត្រីត្រួតពិនិត្យគុណភាពទិន្នន័យ រួចបញ្ជូនបន្តទៅមន្ត្រីសម្ភាសន៍វិញ ដើម្បីធ្វើការផ្ទៀងផ្ទាត់ ឬកែតម្រូវតាមការចាំបាច់។

ការសម្អាតទិន្នន័យ និងការគណនាតួលេខប៉ាន់ប្រមាណក្នុងការអង្កេតនេះ ត្រូវបានធ្វើឡើងដោយប្រើកម្មវិធី RStudio ការពិនិត្យភាពត្រឹមត្រូវនៃទិន្នន័យត្រូវបានកំណត់ចាប់តាំងពីពេលដែលការបង្កើតកម្រងសំណួរនៅក្នុង (CAPI) មកម្លេះ ដោយសារកម្មវិធី Survey Solutions អាចឱ្យមានការត្រួតពិនិត្យភាពស៊ីសង្វាក់គ្នានៅក្នុងប្រព័ន្ធប្រមូលទិន្នន័យ។ បន្ទាប់ពីតារាងសំណួរត្រូវបានបញ្ចប់រួចរាល់ ការសម្អាតទិន្នន័យត្រូវបានចាប់ផ្តើមភ្លាមៗ មានការកំណត់ភាពមិនប្រក្រតីនៃទិន្នន័យដោយយោងទៅតាមការប្រៀបធៀបទិន្នន័យជំរឿនមុនៗ ការកំណត់តម្លៃ ឬបរិមាណដែលអាចទទួលយកបានជាអតិបរមា និងអប្បបរមាសម្រាប់ធាតុផលិតកម្មកសិកម្ម ហើយបានធ្វើការផ្ទៀងផ្ទាត់នូវភាពមិនប្រក្រតីនោះ ដោយសួរត្រឡប់ទៅអ្នកឆ្លើយតបសម្ភាសន៍ និង/ឬមន្ត្រីសម្ភាសន៍។ លើសពីនេះ បន្ទាប់ពីសម្អាតទិន្នន័យរួចរាល់ មានការអនុវត្តជំហានមួយទៀតគឺការសន្មត់ទិន្នន័យ ការងារនេះត្រូវបានធ្វើឡើងដើម្បីសន្មត់តួលេខដែលបាត់ដោយសារគ្មានចម្លើយក្នុងពេលសម្ភាសន៍។

## ស្តង់ដានៃការបោះពុម្ពផ្សាយ

ក្នុងការរៀបចំការបោះពុម្ពជារបាយការណ៍ចុងក្រោយនេះ មានការបង្កើតស្តង់ដាសម្រាប់ការរៀបចំតារាងទិន្នន័យ Excel online on the NIS website (http://www.nis.gov.kh/index.php/km/) ស្តង់ដាទាំងនេះមានដូចជា៖

- តួលេខទាំងអស់ដែលទាក់ទងនឹងចំនួនគ្រួសារ ត្រូវបានបង្គត់ទៅរកលេខជិតបំផុតគិតជាពាន់
- ភាគរយដែលបានគណនាតែងតែផ្អែកលើទិន្នន័យដើមទោះជាយ៉ាងនេះដោយសារការបង្គត់លេខតារាងមួយចំនួនដែលមានតួលេខជាភាគរយអាចមានផលបូកសរុបមិនស្មើ ១០០ ភាគរយ
- នៅក្នុងប្រអប់ទទេមិនមានតួលេខមានន័យថាចំនួនគ្រួសារមានតិចជាង ១០០០ ឬមានកម្រិតមេគុណលំអៀងខ្ពស់ (CV) ចាប់ពី ៣៥ ភាគរយ ឡើងទៅ ហើយគេអាចរកឃើញអ្នកឆ្លើយសំណួរទាំងអស់នោះបានយ៉ាងងាយស្រួល ប៉ុន្តែបើមានលក្ខខណ្ឌណាមួយក្នុងចំណោមពីរខាងលើត្រូវបានបង្ហាញនោះតារាងតួលេខនឹងទទេមិនមានទិន្នន័យឡើយ។

ស្តង់ដាខាងលើធ្វើឱ្យមានដែនកំណត់នៃការចេញផ្សាយទិន្នន័យមានគុណភាពទាប ដោយសារតែ តួលេខនៅក្នុងខេត្ត ឬតំបន់មានចំនួនតិច យោងទៅតាមស្តង់ដាររាយការណ៍របស់វិទ្យាស្ថានជាតិស្ថិតិ។

## ដែនកំណត់នៃអង្កេតកសិកម្មកម្ពុជា

នៅក្នុងការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ ក៏ដូចការធ្វើអង្កេតសំណាកគំរូផ្សេងៗផងដែរ គឺតែងតែមានដែនកំណត់ចំពោះទិន្នន័យដែលផលិត និងដែនកំណត់នៃការបកស្រាយមិនអាចធ្វើការប្រៀបធៀបជាមួយប្រភពទិន្នន័យផ្សេងបាន។ ចំពោះអ្នកអាន ឬអ្នកប្រើប្រាស់ទិន្នន័យដែលមាននៅក្នុងរបាយការណ៍នេះ ត្រូវពិចារណាជាសំខាន់ចំពោះដែនកំណត់ដូចខាងក្រោម៖

- ទិន្នន័យស្វ័យរាយការណ៍៖ អ្នកផ្តល់ចម្លើយមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ត្រូវបានស្នើសុំឱ្យផ្តល់ព័ត៌មានអំពីការកាន់កាប់កសិកម្មនោះ។ ព័ត៌មានទាំងនេះអាចទទួលផលប៉ះពាល់ពីការចងចាំរបស់អ្នកផ្តល់ចម្លើយក្នុងអំឡុងពេលយោងលើប្រភេទសំណួរជាច្រើនក្នុងកម្រងសំណួរ ដោយផ្តោតក្នុងរយៈពេល១២ខែកន្លងមក ។
- រយៈពេលចងចាំរបស់អ្នកតបសម្ភាសន៍៖ ទិន្នន័យស្វ័យរាយការណ៍ក៏អាចរងការប៉ះពាល់បន្ថែមក្នុងអំឡុងពេលយោងដោយផ្ទាល់ និងអំឡុងពេលប្រមូលទិន្នន័យផងដែរ ដោយសារពេលវេលាមានការយឺតយ៉ាវ ទើបការប្រមូលទិន្នន័យមានការពន្យាពេលច្រើនខែឆ្ងាយពីអំឡុងពេលយោង។
- កម្រងសំណួរ និងនីតិវិធីសម្ភាសន៍៖ នៅក្នុងអង្កេតកសិកម្មកម្ពុជា ត្រូវបានប្រឹងប្រែងតាមការបណ្តុះបណ្តាលមន្ត្រីសម្ភាសន៍ និងមន្ត្រីត្រួតពិនិត្យជាប្រព័ន្ធស៊ីសង្វាក់គ្នា ក្នុងដំណើរការប្រមូលទិន្នន័យនេះ។ ការបណ្តុះបណ្តាលលើខ្លឹមសារសំណួរនីមួយៗ ដល់មន្ត្រីសម្ភាសន៍ គឺត្រូវបានប្រើប្រាស់ស្តង់ដាដូចៗគ្នានៅទូទាំងប្រទេស ប៉ុន្តែជាលក្ខណៈបុគ្គលរបស់មន្ត្រីសម្ភាសន៍ អាចធ្វើឱ្យចាកឆ្ងាយពីខ្លឹមសារនៃសំណួរអាចប៉ះពាល់ដល់ការឆ្លើយតបសំណួរ និងជះឥទ្ធិពលដល់លទ្ធផលចុងក្រោយនៃការអង្កេតនេះ។

ដូចដែលមើលឃើញនៅក្នុងរបាយការណ៍អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ ស្រាប់ជាលទ្ធផល ដែលបានចេញផ្សាយផ្តោតលើទិន្នន័យកម្រិតជាតិ និងតំបន់/តំបន់តែប៉ុណ្ណោះ មិនបានលម្អិតដល់ថ្នាក់ក្រោមជាតិទេ ព្រោះទិន្នន័យមានដែនកំណត់ និងដើម្បីកាត់បន្ថយពេលវេលាក្នុងការសរសេររបាយការណ៍ ប៉ុន្តែទិន្នន័យកម្រិតថ្នាក់ក្រោមជាតិទាំងអស់ នឹងត្រូវបានផ្តល់ជូននៅក្នុងឯកសារទិន្នន័យលម្អិតដែលមានផ្សព្វផ្សាយនៅក្នុងគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិ។

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤

## ផ្នែកទី២: ផលិតកម្មដំណាំ



**វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ**

សហការជាមួយ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

គាំទ្របច្ចេកទេសដោយ៖

អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ

គាំទ្រហិរញ្ញវត្ថុដោយ៖ គំនិតផ្តួចផ្តើម ៥០x២០៣០

# ផ្ទៃដីកសិកម្ម និងផលិតកម្មដំណាំ

កម្ពុជាមានផ្ទៃដីកសិកម្មសរុបប្រមាណ ៤ ៤៣៤ ០០០ ហិកតា សម្រាប់គ្រួសារកសិកម្ម។ តំបន់ដែលមានផ្ទៃដីកសិកម្មធំជាងគេបំផុតគឺ តំបន់បឹងទន្លេសាប មានប្រមាណ ២ ២០០ ០០០ហិកតា តំបន់វាលទំនាបមានប្រមាណ ១ ០៨០ ០០០ហិកតា តំបន់ភ្នំ និងខ្ពង់រាប មានប្រមាណ ១ ០១២ ០០០ហិកតា ហើយតំបន់ឆ្នេរសមុទ្រ មានផ្ទៃដីកសិកម្មតិចជាងគេបំផុតប្រមាណ ១៤១ ០០០ហិកតា ។




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

គ្រួសារកសិកម្ម ភាគច្រើនមានការកាន់កាប់ផ្ទៃដីទំហំតូច។ ចំពោះគ្រួសារកាន់កាប់កសិកម្មដែលមានដីធ្វើកសិកម្មតិចជាង១ហិកតា មានចំនួនប្រមាណ ៤២% នៃចំនួនគ្រួសារកសិកម្មសរុប ហើយទំហំជាមធ្យមនៃដីធ្វើកសិកម្មនៅទូទាំងកម្ពុជាគឺមាន ២,៤ហិកតា ក្នុងមួយគ្រួសារ។ នៅតំបន់ឆ្នេរសមុទ្រគ្រួសារកសិកម្មមានទំហំដីធ្វើកសិកម្មតិចជាងគេបង្អស់ជាមធ្យមប្រមាណ ១,២ហិកតា ក្នុងមួយគ្រួសារ។ ចំណែកឯនៅតំបន់បឹងទន្លេសាប និងតំបន់ភ្នំនិងខ្ពង់រាប គ្រួសារកសិកម្មមានដីធ្វើកសិកម្មធំជាងគេ ជាមធ្យមមានប្រមាណ ៣,១ ហិកតា និង ៣,៥ ហិកតា ក្នុងមួយគ្រួសារ តាមលំដាប់លំដោយ។

រូបភាព២.១. ផ្ទៃដីកសិកម្មសរុប តាមប្រភេទទំហំ និងតំបន់ ឆ្នាំ២០២៤




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

ទោះបីជាដីកសិកម្មអាចត្រូវបានប្រើប្រាស់សម្រាប់សកម្មភាពច្រើនយ៉ាងក៏ដោយ ផលិតកម្មដំណាំរយៈពេលខ្លី គឺជាការប្រើប្រាស់ដីចម្បងជាងគេនៅក្នុងកម្ពុជា។ ផ្ទៃដីកសិកម្មប្រហែល ៣,៣លានហិកតា ត្រូវបានប្រើប្រាស់សម្រាប់ផលិតកម្មដំណាំរយៈពេលខ្លី។ ក្នុងការប្រៀបធៀបអំពីការដាំដំណាំរយៈពេលវែង ដែលជាការប្រើប្រាស់ដីធំជាងគេទីពីរ គឺប្រហែលមួយភាគបី ដែលមានផ្ទៃដីប្រើប្រាស់ចំនួន ៨១៣ ០០០ ហិកតា។ ដីទំនេរបណ្តោះអាសន្ន ជាការប្រើប្រាស់ដីធំជាងគេទីបី មានប្រមាណតែ ១៥២ ០០០ហិកតាប៉ុណ្ណោះ ក្នុងការប្រៀបធៀប។

រូបភាព២.២. ផ្ទៃដីកសិកម្ម តាមចំណាត់ថ្នាក់ នៅប្រទេសកម្ពុជា ឆ្នាំ២០២៤




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

ទំហំក្បាលដីកសិកម្មដែលបានទទួលពីកេរមរតក មានចំនួន ១,៤ លានក្បាលដី។ ទំហំក្បាលដីដែលបានទិញ មានចំនួន ៦២៤ ០០០ក្បាលដី។ ទំហំក្បាលដីកសិកម្ម ចំនួន ១៩ ០០០ ហិកតា បានរាយការណ៍ដោយគ្រួសារកសិកម្មថាបានផ្លាស់ប្តូរលំនៅដ្ឋានដោយគ្មានការអនុញ្ញាត ទោះបីជាការលំអៀងរបស់អ្នកឆ្លើយតបអាចបណ្តាលឱ្យមានការរាយការណ៍តិចតួចក៏ដោយ។

រូបភាព២.៣ វិធីសាស្ត្រគ្រួសារកសិកម្មទទួលបានក្បាលដី នៅកម្ពុជា ឆ្នាំ២០២៤




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

# ផលិតកម្មដំណាំ

សកម្មភាពចម្បង នៃគ្រួសារកាន់កាប់កសិកម្មនៅក្នុងកម្ពុជា គឺការដាំដុះ និងការប្រមូលផល ដំណាំរយៈពេលខ្លី និងដំណាំរយៈពេលវែង។ ក្នុងចំណោមគ្រួសារកាន់កាប់កសិកម្មសរុបចំនួន ១,៨៧លាន បានរាយការណ៍ថា បានចូលរួមដាំដំណាំចំនួន ១,៧៧លានគ្រួសារ ។

ដំណាំរយៈពេលខ្លី គឺជាដំណាំដែលមានវដ្តលូតលាស់តិចជាងមួយឆ្នាំ ហើយក្រោយពេលប្រមូលផល ត្រូវបានសាបព្រោះឡើងវិញ ឬដាំឡើងវិញសម្រាប់វដ្តផលិតកម្មផ្សេងទៀត ។ ដំណាំរយៈពេលខ្លីដែលបង្ហាញ ក្នុងការអង្កេតកសិកម្មកម្ពុជា គឺជាដំណាំដែលដាំដុះតាមរដូវកាលក្នុងអំឡុងពេលឆ្នាំយោង។ ដំណាំ រយៈពេលវែង គឺជាដំណាំដែលមានវដ្តលូតលាស់លើសពីមួយឆ្នាំដែលកំពុងដាំដុះ ។

ដោយសារប្រភេទដំណាំជាច្រើនដែលដាំដុះនៅកម្ពុជា និងកិច្ចប្រឹងប្រែងដើម្បីកាត់បន្ថយបន្ទុកលើ អ្នកឆ្លើយតប និងរយៈពេលសម្ភាសន៍ ដូច្នេះទិន្នន័យលម្អិតត្រូវបានប្រមូលសម្រាប់តែដំណាំសំខាន់ជាងគេ ៣២ មុខប៉ុណ្ណោះនៅកម្ពុជា ដែលត្រូវបានកំណត់ដោយ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ សម្រាប់ ដំណាំសំខាន់ទាំង ៣២ មុខនេះ អ្នកតបសម្ភាសន៍ បានផ្តល់ព័ត៌មានដែលទាក់ទងនឹងផ្ទៃដីដាំដុះ ផ្ទៃដី ប្រមូលផល បរិមាណផលប្រមូលបាន ការប្រើប្រាស់ជី ការប្រើប្រាស់ថ្នាំកសិកម្ម ការប្រើប្រាស់ប្រព័ន្ធ ស្រោចស្រព និងគោលបំណងចម្បងនៃផលិតកម្មដំណាំ សម្រាប់លក់ ឬ សម្រាប់ប្រើប្រាស់ក្នុងគ្រួសារ។ ដើម្បីកាត់បន្ថយបន្ទុកលើអ្នកឆ្លើយតបសម្ភាសន៍ ទិន្នន័យសម្រាប់ដំណាំរយៈពេលវែង ត្រូវបានប្រមូល ផ្ទៃដី គិតជាហិកតា ឬជាចំនួនដើមដែលបានដាំដោយផ្អែកលើចម្លើយរបស់អ្នកតបសម្ភាសន៍។ ដូចនេះទិន្នន័យដែល បានរាយការណ៍ពីចំនួនដើមដែលបានដាំ ត្រូវបានបំលែងទៅជាហិកតា ដោយផ្អែកលើមេគុណបំលែងដែល បានផ្តល់ឲ្យដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ឧបសម្ព័ន្ធ ១) ។

ប្រការសំខាន់ គឺអ្នកប្រើប្រាស់ទិន្នន័យត្រូវកត់សម្គាល់ថា នីតិវិធីដែលបានប្រើនៅក្នុងអង្កេតកសិកម្ម ឆ្នាំ២០២៤ ខុសប្លែកពីនីតិវិធីដែលបានប្រើនៅក្នុងកិច្ចប្រឹងប្រែងវាយតម្លៃកសិកម្មផ្សេងទៀតនៅកម្ពុជា។ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ គឺជាការជ្រើសរើសសំណាកគំរូដោយចៃដន្យ តាមវិធីសាស្ត្រទិន្នន័យដែល បានរាយការណ៍ ក្នុងការកាន់កាប់កសិកម្មរយៈពេលឆ្នាំយោងជាក់លាក់ គឺចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤ ហើយបានគ្របដណ្តប់គ្រប់កម្រិត ទាំងកម្រិតគ្រួសារកសិកម្ម និងសហគ្រាសកសិកម្មខ្នាតធំ ។ ជាលទ្ធផល ចំនួនផ្ទៃដីសរុប បរិមាណផលិតផល និងទិន្នផល ដែលបាន គណនាសម្រាប់ដំណាំនានា អាចខុសគ្នាពីប្រភពទិន្នន័យផ្សេងទៀត ។

រូបទី២.៤ បានបង្ហាញពីការដាំដំណាំ១០មុខសំខាន់មាន៖ ស្រូវធម្មតា ចេក ស្វាយ ដូង ស្រូវក្រអូប ដំឡូងមី ស្វាយចន្ទី ខ្នុរ ក្រូចឆ្មា និងស្លឹកគ្រៃ។ គ្រួសារកាន់កាប់កសិកម្មចំនួន ១.២៦លាន បានរាយការណ៍ថា បានដាំស្រូវធម្មតា ហើយការដាំដំណាំធំទីពីរមានគ្រួសារកសិកម្មចំនួន ៥៥៥ ០០០ បានដាំដំណាំស្វាយ និង ដំណាំដូង។

រូបភាព១២.៤ ចំនួនគ្រួសារកសិកម្មដែលរាយការណ៍ពីប្រភេទដំណាំ១០មុខសំខាន់ៗ
នៅកម្ពុជា ឆ្នាំ២០២៤




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

# ដំណាំរយៈពេលខ្លី

## គ្រាប់ធញ្ញជាតិ

ដំណាំសំខាន់ៗចំនួន២មុខ ដែលដាំដោយគ្រួសារកសិកម្មនៅកម្ពុជាគឺ ស្រូវ និងពោត។ ពូជស្រូវដែលដាំមានដូចជា ស្រូវធម្មតា ស្រូវក្រអូប និងស្រូវដំណើប។ ពោត ត្រូវបានចាត់ជាពូជពោត ស លឿង និងស្វាយ ។

ក្នុងចំណោមស្រូវទាំង៣ប្រភេទ មានការដាំពូជស្រូវធម្មតាទូទៅច្រើនជាងគេ លើផ្ទៃដីដាំដុះ មានប្រមាណ ២,៥៩ លានហិកតា និងផ្ទៃដីប្រមូលផលមានប្រមាណ ២,៥៦ លានហិកតា។ ទិន្នផលស្រូវ ធម្មតាត្រូវបានប៉ាន់ប្រមាណថាទទួលបានជាមធ្យម ៣ ២០០ គីឡូក្រាមក្នុង១ហិកតា ដោយបរិមាណផលសរុបដែលប្រមូលបាននៅកម្ពុជាមានប្រមាណ ៨,១៨ លានតោន នៃស្រូវធម្មតា។ តំបន់បឹងទន្លេសាបជាតំបន់ដែលបានដាំដុះស្រូវធម្មតាច្រើនជាងគេ លើទំហំផ្ទៃដី ១,៣៦ លានហិកតា ចំណែកតំបន់វាលទំនាបមានដំណាំស្រូវលើផ្ទៃដីទំហំ ៨៦៣ ០០០ហិកតា តំបន់ភ្នំ និងខ្ពង់រាប មានដំណាំស្រូវលើផ្ទៃដីទំហំ ២៧៣ ០០០ហិកតា និងតំបន់ឆ្នេរសមុទ្រ មានដំណាំស្រូវលើផ្ទៃដីទំហំ ៩៥ ០០០ហិកតា។

រូបភាព២.៥ ផ្ទៃដីដំណាំស្រូវធម្មតា បែងចែកតាមតំបន់ គិតជាហិកតា ឆ្នាំ២០២៤




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

ពូជស្រូវក្រអូប ត្រូវបានដាំលើផ្ទៃដីប្រមាណ ៥៥៨ ០០០ហិកតា នៅកម្ពុជា ដោយមានផ្ទៃដីប្រមូលផល ទំហំប្រមាណ ៥៥១ ០០០ ហិកតា។ ទិន្នផលជាមធ្យមក្នុងមួយហិកតា នៃពូជស្រូវក្រអូបមានប្រមាណ ២ ៣៦០គីឡូក្រាម ក្នុង១ហិកតា ហើយមានបរិមាណផលសរុប ដែលប្រមូលបានប្រមាណ ១,៣ លានតោន ខុសពីពូជស្រូវធម្មតា ផលិតកម្មស្រូវក្រអូបភាគច្រើនត្រូវបានប្រមូលផលនៅតំបន់បឹងទន្លេសាប ដែលមានផ្ទៃដីដាំដុះប្រមាណ ៣៨៤ ០០០ហិកតា។

រូបភាព៧.៦ ផ្ទៃដីដំណាំស្រូវក្រអូប បែងចែកតាមតំបន់ គិតជាហិកតា ឆ្នាំ២០២៤




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

ដំណាំពោត ត្រូវបានដាំដុះដោយគ្រួសារកសិកម្មលើផ្ទៃដីប្រមាណ ៩៩ ០០០ ហិកតា នៅប្រទេស កម្ពុជា ចំណែកតំបន់បឹងទន្លេសាប មានផ្ទៃដីដាំដុះច្រើនជាងគេប្រមាណ ៨៩ ០០០ ហិកតា ។ ទិន្នផលជាមធ្យមមានប្រមាណ ៥ ៧២០ គីឡូក្រាមក្នុង១ហិកតា ដោយបរិមាណផលសរុបដែលប្រមូលបាន មានប្រមាណ ៥៤៨ ០០០ តោន នៅកម្ពុជា។

## ដំណាំយកមើម

ដំណាំយកមើមដែលបានដាំដោយគ្រួសារកសិកម្ម មានដូចជា ដំឡូងមី ដំឡូងជ្វា ត្រាវ សាគូ និងប៉ិគក់ ។ ផ្ទៃដីដាំដំឡូងមី មានទំហំផ្ទៃដីច្រើនជាងគេរហូតដល់ ៤៩២ ០០០ហិកតា និងផ្ទៃដីប្រមូលផល ៤៨៣ ០០០ ហិកតា។ ទិន្នផលដំឡូងមីជាមធ្យមទទួលបានប្រមាណ ១២ ៦៩០ គីឡូក្រាមក្នុងមួយហិកតា ជាមួយនឹងបរិមាណផលសរុបទូទាំងកម្ពុជា មានចំនួនប្រមាណ ៦,១២ លានតោន។

រូបភាព២.៧ ចំនួនគ្រួសារដែលរាយការណ៍ដាំដំឡូងមី តាមតំបន់ ឆ្នាំ២០២៤




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

## ដំណាំសម្រាប់គ្រឿងទេស គ្រឿងក្រអូប និង រុក្ខជាតិឱសថ

ការអង្កេតនេះ ក៏បានប្រមូលព័ត៌មានអំពីដំណាំគ្រឿងទេស គ្រឿងក្រអូប និងរុក្ខជាតិ ឱសថ ដូចជា ស្លឹកគ្រៃ ជីអង្កាម និងស្លឹកម្លូ។ គ្រួសារកសិកម្ម បានរាយការណ៍ពីការដាំស្លឹកគ្រៃ មានចំនួន ១២៣ ០០០ គ្រួសារ ហើយគ្រួសារដាំជីអង្កាមមានចំនួន ៣៩ ០០០គ្រួសារ ដាំរមៀតមានចំនួន ១៣ ០០០ និងគ្រួសារដាំជីវ៉ាន់ស៊ុយមានចំនួនប្រហែល ៣ ០០០។

## ដំណាំឧស្សាហកម្ម

ដំណាំឧស្សាហកម្ម នៅក្នុងការអង្កេតនេះ គឺដំណាំអំពៅ។ គ្រួសារកសិកម្មដាំអំពៅសរុបនៅកម្ពុជា ត្រូវបានប៉ាន់ប្រមាណថាមាន ១៧ ០០០ គ្រួសារ និងមានគ្រួសារកសិកម្មនៅតំបន់វាលទំនាប និងតំបន់បឹងទន្លេសាបចំនួនប្រហាក់ប្រហែលគ្នាប្រមាណ ១៣ ០០០គ្រួសារបានដាំដំណាំអំពៅ។ នៅកម្ពុជាទិន្នផលដំណាំអំពៅសរុបប្រមាណ ១៤ ០០០ គីឡូក្រាមក្នុង១ហិកតា។

រូបភាព១២.៨ ចំនួនគ្រួសារដែលរាយការណ៍ដាំអំពៅ តាមតំបន់ ឆ្នាំ២០២៤




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

## ដំណាំបន្លែ

បន្លែជាច្រើនប្រភេទត្រូវបានដាំដុះនៅទូទាំងប្រទេស រួមទាំងបន្លែស្លឹក ឬដើម។ បន្លែផ្លែ ឫស មើម បន្លែបៃតង។ល។ បន្លែស្លឹក ឬដើមរួមមាន ស្លឹកខ្ទឹម ស្ពៃខ្មៅ ស្ពៃក្រញាញ់ ស្ពៃស និងត្រកួន។ ការអង្កេតនេះ មានព័ត៌មានពីបន្លែផ្លែដូចជា ម្ទេស ត្រសក់ ត្រប់ ននោង ល្ពៅ ផ្លែឪឡឹក និងត្រឡាច។ បន្លែបៃតង រួមមាន សណ្តែកកួរ។ បន្លែផ្សេងទៀតរួមមានផ្កាខាត់ណាខៀវ។

គ្រួសារកសិកម្មប្រមាណ ៥១ ០០០ គ្រួសារ បានរាយការណ៍ថាបានដាំននោង។ ចំនួនគ្រួសារដែលបានរាយការណ៍ថាដាំត្រសក់មានប្រមាណ ២២ ០០០គ្រួសារ នៅកម្ពុជា ជាមួយទំហំផ្ទៃដីដាំដុះ និងផ្ទៃដីប្រមូលផលប្រមាណ ៣ ៦០០ ហិកតា ។ ទិន្នផលសរុបនៃត្រសក់ប្រមាណ ៣៨ ០០០ តោន។ គ្រួសារកសិកម្មប្រមាណ ២២ ០០០ គ្រួសារ បានរាយការណ៍ថាបានដាំត្រប់ ហើយទិន្នផលជាមធ្យមទទួល

បាន ៩ ៣២០ គីឡូក្រាមក្នុង១ហិកតា។ គ្រួសារកសិកម្មប្រមាណ ៨ ០០០គ្រួសារ បានរាយការណ៍ថាបានដាំល្ពៅ នៅកម្ពុជា និងគ្រួសារកសិកម្មបានដាំឪឡឹកមានប្រមាណ ៤ ០០០ គ្រួសារ ។

រូបភាព២.៩ ចំនួនគ្រួសារកសិកម្ម ដាំបន្លែមានផ្លែ តាមប្រភេទដំណាំ នៅកម្ពុជា ឆ្នាំ២០២៤




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

# ដំណាំរយៈពេលវែង

## ដំណាំហូបផ្លែ

ដំណាំពពួកក្រូច ជាដំណាំដែលត្រូវបានរកឃើញថាបានដាំដុះច្រើនជាងគេនៅកម្ពុជា ហើយដំណាំដែលស្ថិតក្នុងការអង្កេតកសិកម្មនេះ មានដូចជា ក្រូចថ្លុង ក្រូចឆ្មា និងក្រូចពោធិ៍សាត់។ គ្រួសារកសិកម្មប្រមាណ ៣៤ ០០០ គ្រួសារក្នុងកម្ពុជា បានដាំក្រូចពោធិ៍សាត់ លើផ្ទៃដីទំហំសរុបប្រមាណ ៣ ០០០ហិកតា ដោយទិន្នផលជាមធ្យមទទួលបាន ៣ ៩៣០ គីឡូក្រាមក្នុង១ហិកតា។

ប្រភេទដំណាំហូបផ្លែ ដែលបានដាំដុះច្រើនជាងនៅកម្ពុជា រួមមាន ស្វាយ ចេក ខ្នុរ ល្ហុង ត្របែក ទៀបទឹកដោះគោ ទុរេន មៀន និងដំណាំហូបផ្លែផ្សេងទៀត។

រូបភាព២.១០ ចំនួនគ្រួសារកសិកម្មដាំដំណាំផ្លែឈើ តាមប្រភេទដំណាំ នៅកម្ពុជា ឆ្នាំ២០២៤




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

គ្រួសារកសិកម្មប្រមាណ ៥៥៥ ០០០ គ្រួសារក្នុងកម្ពុជា បានដាំស្វាយ លើផ្ទៃដីទំហំសរុបប្រមាណ ៥៤ ០០០ ហិកតា ហើយផ្ទៃដីប្រមូលផលសរុបប្រមាណ ៤២ ០០០ហិកតា គឺជាផ្ទៃដីដាំស្វាយ ធំជាងគេបំផុតនៅកម្ពុជា។ ទិន្នផលគិតជាមធ្យមទទួលបាន ៦ ៥៦០ គីឡូក្រាមក្នុង១ហិកតា សម្រាប់ដំណាំស្វាយ។ បើគិតតាមតំបន់ គ្រួសារកសិកម្មប្រមាណ ២៣៤ ០០០ បានដាំដំណាំស្វាយ នៅតំបន់បឹងទន្លេសាប តាមពីក្រោយដោយតំបន់វាលទំនាប មានគ្រួសារប្រមាណ ១៩៥ ០០០ បានដាំដំណាំស្វាយ និងតំបន់ដែលមានគ្រួសារដាំដំណាំស្វាយតិចជាងគេ គឺតំបន់ឆ្នេរសមុទ្រមានប្រមាណ ៤៩ ០០០។

រូបភាព២.១១ ចំនួនគ្រួសារដាំដំណាំស្វាយ តាមតំបន់ ឆ្នាំ២០២៤




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

គ្រួសារកសិកម្មប្រមាណ ៥៣១ ០០០គ្រួសារ ក្នុងកម្ពុជា បានដាំដំណាំចេក លើផ្ទៃដីទំហំសរុបប្រមាណ ១៤ ០០០ហិកតា ហើយផ្ទៃដីប្រមូលផលសរុបប្រមាណ ៧ ៧០០ ហិកតា។ បរិមាណផលសរុបប្រមាណ ៥៣ ០០០ តោន ដោយទិន្នផលគិតជាមធ្យមទទួលបាន ៦ ៨៨០ គីឡូក្រាមក្នុង១ហិកតា។ តំបន់បឹងទន្លេសាប ជាតំបន់ដែលដាំចេកច្រើនជាងគេបំផុត បានរាយការណ៍ថាមានជាង ៦ ០០០ ហិកតា។

រូបភាព២.១២ ផ្ទៃដីដាំដំណាំចេក បែងចែកតាមតំបន់ គិតជាហិកតា ឆ្នាំ២០២៤




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

គ្រួសារកសិកម្មមានប្រមាណ ១៨០ ០០០ គ្រួសារ ក្នុងកម្ពុជា បានដាំខ្ទឹម លើផ្ទៃដីទំហំសរុបប្រមាណ ២ ២០០ ហិកតា ហើយផ្ទៃដីប្រមូលផលសរុបប្រមាណ ១ ១០០ ហិកតា។ ទិន្នផលគិតជាមធ្យមទទួលបាន ៥ ៦៥០ គីឡូក្រាមក្នុង១ហិកតា។ គ្រួសារកាន់កាប់កសិកម្មប្រមាណ ៧៥ ០០០គ្រួសារ នៅតំបន់វាលទំនាប បានរាយការណ៍ថាបានដាំខ្ទឹមច្រើនជាងគេ។

រូបភាព២.១៣ ចំនួនគ្រួសារកសិកម្មដាំដំណាំខ្ទឹម តាមតំបន់ ឆ្នាំ២០២៤




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

## ស្វាយចន្ទី

ក្នុងចំណោមរុក្ខជាតិដែលផ្តល់គ្រាប់សម្រាប់បរិភោគ ការអង្កេតកសិកម្មនេះ បានប្រមូលទិន្នន័យអំពីដំណាំស្វា និងស្វាយចន្ទី ក្នុងនោះគ្រាប់ស្វាយចន្ទីមានការពេញនិយមជាងគេ។ គ្រួសារកសិកម្មប្រមាណ ២០១ ០០០គ្រួសារ នៅកម្ពុជា បានដាំស្វាយចន្ទី លើទំហំផ្ទៃដី សរុបប្រមាណ ៥០៧ ០០០ ហិកតា ដោយផ្ទៃដីប្រមូលផល ៤៥៥ ០០០ហិកតា និងបរិមាណផលប្រមាណ ៣៧០ ៤០០តោន។ ទិន្នផលជាមធ្យម ៨១០ គីឡូក្រាមក្នុង១ហិកតា។ តំបន់ភ្នំនិងខ្ពង់រាប បានរាយការណ៍ថា បានដាំស្វាយចន្ទី លើទំហំផ្ទៃដីប្រមាណ ២៨៩ ០០០ ហិកតា។

រូបភាព២.១៤ ចំនួនគ្រួសារកសិកម្មដាំដំណាំស្វាយចន្ទី តាមតំបន់ ឆ្នាំ២០២៤




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

## ដំណាំយកប្រេង

ដំណាំយកប្រេង ដែលស្ថិតក្នុងការអង្កេតនេះរួមមាន ដូង និងដូងប្រេង។ ដូង ជាដំណាំដែលពេញនិយមជាងគេក្នុងចំណោមដំណាំទាំងពីរនេះ គ្រួសារកសិកម្មប្រមាណ ៥៥៥ ០០០ គ្រួសារ បានរាយការណ៍ថា បានដាំដំណាំដូង។ ផ្ទៃដីដាំដូងមានទំហំប្រមាណ ២៧ ០០០ហិកតា ដោយផ្ទៃដីប្រមូលផលប្រមាណ ៨ ៥០០ ហិកតា។ បរិមាណផលសរុបប្រមូលបានប្រមាណ ៨០ ០០០ តោន ជាមួយទិន្នផលជាមធ្យម ៩ ៤៧០ គីឡូក្រាម ក្នុង១ហិកតា។ នៅតំបន់វាលទំនាប បានរាយការណ៍ថាបានដាំដូងច្រើនជាងគេបំផុតលើផ្ទៃដីប្រមាណ ៦ ៨០០ ហិកតា។

រូបភាព២.១៥ ផ្ទៃដីដាំដំណាំដូង បែងចែកតាមតំបន់ គិតជាហិកតា ឆ្នាំ២០២៤




*ប្រភព៖ អង្កេតកសិកម្មកម្ពុជា ឆ្នាំ២០២៤*

## ដំណាំម្រេច

គ្រួសារដែលដាំម្រេច មានប្រមាណ ១១ ៤០០គ្រួសារ នៅកម្ពុជា។ ផ្ទៃដីដាំដុះម្រេចសរុប ត្រូវបានប៉ាន់ប្រមាណមាន ៧ ៤០០ ហិកតា និងផ្ទៃដីប្រមូលផល ៧ ០០០ ហិកតា។ ដំណាំម្រេចបានដាំច្រើនជាងគេនៅតំបន់វាលទំនាប និងបឹងទន្លេសាប ដែលមានទំហំផ្ទៃដីដាំដុះប្រមាណ ៨ ០០០ហិកតា។

## ដំណាំកៅស៊ូ

គ្រួសារកសិកម្មប្រមាណ ៥៣ ០០០គ្រួសារ ក្នុងកម្ពុជាបានដាំដំណាំកៅស៊ូ។ ផ្ទៃដីដាំកៅស៊ូសរុបមានប្រមាណ ១៤៦ ០០០ហិកតា ដែលមានផ្ទៃដីប្រមូលប្រមាណ ៩៧ ០០០ ហិកតា នៅកម្ពុជា។ បរិមាណផលសរុបប្រមូលបានប្រមាណ ២៩១ ០០០ តោន ជាមួយទិន្នផលជាមធ្យមមានប្រមាណ ៣ ០១០ គីឡូក្រាមក្នុងមួយហិកតា។ សូមកត់ចំណាំថា ទិន្នន័យក្នុងរបាយការណ៍នេះ ប្រើតែកសិកម្មជាលក្ខណៈគ្រួសារតែប៉ុណ្ណោះ ខណៈពេលដែលផលិតកម្មកៅស៊ូភាគច្រើន នៅក្នុងកម្ពុជាត្រូវបានកាន់កាប់ដោយក្រុមហ៊ុនកសិកម្មឯកជនធំៗ មិនត្រូវបានរាប់បញ្ចូលក្នុងរបាយការណ៍នេះទេ។

## ដំណាំមិនមែនស្បៀង

ដំណាំដែលមិនមែនជាអាហារមានផ្កា រុក្ខជាតិ និងដើមឈើ។ ឫស្សី ដែលប្រើប្រាស់សម្រាប់គោលបំណងជាច្រើនរួមទាំង សម្រាប់សាងសង់ផ្ទះ គ្រឿងសង្ហារិម និងការចម្អិនអាហារ គឺជាដំណាំមិនមែនអាហារនាំមុខគេ ដែលមានគ្រួសារកសិកម្មប្រមាណ ៥ ៤០០ គ្រួសារ បានរាយការណ៍ថាបានដាំឫស្សី។ តំបន់បឹងទន្លេសាប គឺជាតំបន់ដែលមានចំនួនគ្រួសារដាំឫស្សីរហូតដល់ ៣ ០០០ គ្រួសារ ។

## ការកើនឡើងនៃផ្ទៃដីកសិកម្ម និងផលិតកម្មស្រូវ

ការអង្កេតកសិកម្មកម្ពុជា (CAS) ឆ្នាំ២០២៤ បានកត់ត្រានៃការកើនឡើងផ្ទៃដីកសិកម្ម និងផលិតកម្មស្រូវ។ ផ្ទៃដីកសិកម្មសរុបបានកើនពី ៣,៨៥ លានហិកតា ក្នុងការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣ ទៅដល់ ៤,៤៣លានហិកតា ក្នុងការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ ដែលបណ្តាលមកពីការកើនឡើងយ៉ាងច្រើនលើផ្ទៃដីដាំដុះស្រូវធម្មតា ដែលបានកើនពី ១,៩៩៦ លានហិកតា ទៅដល់២,៥៩១ លានហិកតា។

តម្លៃអង្ករអន្តរជាតិបានកើនឡើងយ៉ាងខ្លាំងក្នុងឆ្នាំ២០២៣ ដែលមានការលើកទឹកចិត្តយ៉ាងពេញទំហឹងសម្រាប់កសិករកម្ពុជា។ អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ (FAO) បានរាយការណ៍ថា សន្ទស្សន៍ថ្លៃនាំចេញអង្ករនៅខែធ្នូ ឆ្នាំ២០២៣ បានកើនឡើង ២១% បើប្រៀបធៀបទៅឆ្នាំមុន[2] ការបារម្ភជាចម្បងអំពីបាតុភូតអេនីញ៉ូ (El Niño) ដល់ការប្រមូលផលស្រូវ និងវិធានការកំណត់នាំចេញដែលបានដាក់ឱ្យអនុវត្តដោយប្រទេសឥណ្ឌា។ វិធានការរបស់ប្រទេសឥណ្ឌា ដែលចាប់ផ្តើមនៅខែកក្កដា-សីហា ឆ្នាំ២០២៣ រួមមានការហាមនាំចេញអង្ករសប្រភេទ Non-basmati និងការបង់ពន្ធលើប្រភេទអង្ករផ្សេងទៀតបន្ថយ

---

[2] FAO All Rice Price Index: https://www.fao.org/markets-and-trade/commodities/rice/fao-rice-price-update/en/

ការផ្គត់ផ្គង់នៅទីផ្សារពិភពលោកយ៉ាងខ្លាំង។ ត្រឹមខែកក្កដា ឆ្នាំ២០២៣ តម្លៃអង្ករពិភពលោកបានកើនឡើង ១២-១៤% ហើយបន្តកើនឡើង ដល់កម្រិតខ្ពស់បំផុតចាប់តាំងពីឆ្នាំ២០០៨ មក[3]។

វិទ្យាស្ថានស្រាវជ្រាវគោលនយោបាយស្បៀងអន្តរជាតិ (IFPRI) បានសង្កេតឃើញថា ៦ខែ បន្ទាប់ពីការហាមឃាត់នាំចេញរបស់ឥណ្ឌា តម្លៃអង្ករបាក់ថៃ ៥% មានការកើនឡើងប្រហែល ២២% ព្រោះការនាំចេញអង្ករមិនមែនបាសម៉ាទី (non-basmati) អង្ករ Parboiled និងអង្ករបាក់ របស់ឥណ្ឌា បានធ្លាក់ចុះខ្លាំង និងប្រទេសនាំចេញផ្សេងៗដូចជា វៀតណាម និងថៃ ក៏បានរងការខាតបង់ផលិតកម្មពាក់ព័ន្ធនឹងអេលនីញ៉ូ (El Niño) ផងដែរ[4]។

សក្តានុពលជាសាកលទាំងនេះបានប្រែក្លាយទៅជាចំណូលខ្ពស់នៃការនាំចេញសម្រាប់អង្ករកម្ពុជា។ ប្រព័ន្ធព័ត៌មានសកល និងព្រមានជាមុន របស់អង្គការស្បៀងនិងកសិកម្ម (FAO) បានរាយការណ៍ថា តម្លៃអង្ករលក់ដុំរបស់កម្ពុជាបានឈានដល់កំណត់ត្រា ឬជិតកំណត់ត្រាខ្ពស់នៅចន្លោះខែកក្កដា ឆ្នាំ២០២៣ ដល់ខែកុម្ភៈ ឆ្នាំ២០២៤។ គិតត្រឹមខែឧសភា ឆ្នាំ២០២៤ កម្រិតតម្លៃខ្ពស់ជាងកាលពីឆ្នាំមុន ៣៥% - ៤៥% ដែលបានផ្តល់លទ្ធភាពជំរុញទីផ្សារផលិតកម្មដល់កសិករបន្ថែម[5]។

ប្រទេសឥណ្ឌាជាធម្មតាមានការនាំចេញអង្ករច្រើនជាង ៤០% នៃពិភពលោក។ នៅពេលដែលការរឹតបន្តឹងទាំងនោះចូលជាធរមាន ការនាំចេញរបស់ប្រទេសឥណ្ឌាបានធ្លាក់ចុះ ៤៦% ចន្លោះពីខែសីហា និងខែវិច្ឆិកា ឆ្នាំ២០២៣ ដែលបានបង្កើតគម្លាតផ្គត់ផ្គង់ក្នុងទីផ្សារពិភពលោក។ ក្រុមប្រទេសនាំចេញដទៃទៀតដូចជា វៀតណាម និងថៃ ក៏បានប្រឈមមុខនឹងការកាត់បន្ថយការប្រមូលផលដោយសារតែ El Niño ដែលជាការរឹតបន្តឹងការផ្គត់ផ្គង់បន្ថែមទៀតផងដែរ។

បរិយាកាសនេះបានបង្កើតឱកាសថ្មីសម្រាប់ស្រូវអង្ករកម្ពុជា។ របាយការណ៍ប្រចាំឆ្នាំអំពីធញ្ញជាតិ និងចំណីអាហារ របស់នាយកដ្ឋានកសិកម្មសហរដ្ឋអាមេរិក (USDA) សម្រាប់កម្ពុជាបានបញ្ជាក់ថាពាណិជ្ជករវៀតណាមបានទិញអង្ករកម្ពុជាដោយសកម្ម និងផ្តល់តម្លៃលើកទឹកចិត្តដល់កសិករនៅតាមកសិដ្ឋាន ហើយមិនមានការជ្រើសរើសគុណភាពច្រើននោះទេ។ ពួកគេបានស្វែងរកជាពិសេសប្រភេទស្រូវធម្មតា ដូចជាប្រភេទ OM ដែលជាដំណាំរយៈពេលខ្លី និងមានទិន្នផលខ្ពស់។ យោងតាមអ្នកនាំពាក្យរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លោក **ខឹម ហ៊ីណាន់** បានឱ្យដឹងថាតម្លៃស្រូវក្រអូប ឈ្មោះសែនក្រអូប បានកើនឡើងពី ១ ០៧២ រៀល ក្នុងខែធ្នូ ឆ្នាំ២០២២ ទៅដល់ ១ ៤០០ រៀលនៅចុងឆ្នាំ២០២៣ ខណៈដែលអង្ករ វៀតណាម OM ទទួលបានតម្លៃ ៨០០-១ ០០០ រៀលក្នុងមួយគីឡូក្រាម[6]។ ជាមួយនឹងការផ្គត់ផ្គង់របស់ឥណ្ឌាមានកម្រិត និងតម្រូវការក្នុងតំបន់កាន់តែច្រើន កសិករកម្ពុជាមានទំនុកចិត្តថាស្រូវអង្កររបស់ពួកគេ នឹងមានទីផ្សារគ្រប់គ្រាន់។

---

[3] Radio Free Asia “El Niño, India rice export ban cause food security fears in SE Asia” https://www.rfa.org/english/news/vietnam/rice-exports-09282023153533.html#:~:text=But%20the%20staple%20food%20is,Ni%C3%B1o%20climate%20phenomenon%20reducing%20harvests

[4] IFPRI “India’s export restrictions on rice continue to disrupt global markets, supplies, and prices” https://www.ifpri.org/blog/indias-export-restrictions-rice-continue-disrupt-global-markets-supplies-and-prices/

[5] FAO “GIEWS Country Brief The Kingdom of Cambodia 15 July 2024” https://www.fao.org/giews/countrybrief/country/KHM/pdf_archive/KHM_Archive.pdf

[6] Phnom Penh Post “Farmers urged to prioritise local rice varieties as prices surge” https://www.phnompenhpost.com/business/farmers-urged-to-prioritise-local-rice-varieties-as-prices-surge

សរុបមក ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ ថ្ងៃ ខែ ឆ្នាំយោង (ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៤) ស្របពេលជាមួយនឹងរយៈពេលនៃការកើនឡើងតម្លៃអន្តរជាតិយ៉ាងខ្លាំងដែលបណ្តាលមកពីការខាតបង់ផលិតកម្មទាក់ទងនឹង El Niño និងការរឹតបន្តឹងការនាំចេញរបស់ប្រទេសឥណ្ឌា។ គ្រោះហានិភ័យជាសាកលទាំងនេះបានធ្វើឱ្យតម្លៃស្រូវអង្ករកើនឡើងពី ១២-២២% ហើយបានរក្សាតម្លៃលក់ដុំរបស់កម្ពុជានៅ ៣៥%-៤៥% លើសពីកម្រិតកាលពីឆ្នាំមុន។ តម្រូវការនាំចូលពីវៀតណាម និងទីផ្សារផ្សេងទៀត រួមជាមួយតម្លៃលើកទឹកចិត្តនៅកសិដ្ឋាន និងការគាំទ្រពីរដ្ឋាភិបាលចំពោះបរិក្ខារប្រើប្រាស់ និងការរក្សាតម្លៃទំនិញ បានជម្រុញឱ្យកសិករបន្ថែមផលិតកម្ម។ ដូច្នេះ គេសន្មតថាការពង្រីកនេះភាគច្រើនបណ្តាលមកពីទីផ្សារ និងអាចពន្យល់អំពីការកើនឡើងប្រហែល ៥៩៥ ០០០ ហិកតា នៃផ្ទៃដីដាំស្រូវធម្មតា និងការកើនឡើងសរុប ៥៨១ ០០០ ហិកតា នៃផ្ទៃដីកសិកម្ម ចន្លោះអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៣ និងអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤។

## តារាងឧបសម្ព័ន្ធ២

### តារាង២.១៖ ដើមឈើ ឬដំណាំជារុក្ខជាតិ ការគណនាបំលែងពីការរាប់ចំនួនដើមឈើទៅជាហិកតា

| ប្រភេទដើមឈើ/រុក្ខជាតិ | ការបំលែងឯកតាជាចំនួនដើម/ហិកតា |
|---|---|
| ក្រូចពោធិ៍សាត់ | 400 |
| ក្រូចឃ្វិច | 400 |
| ក្រូចថ្លុង | 400 |
| ក្រូចឆ្មារ | 400 |
| ក្រូចសើច | 400 |
| ផ្លែក្រូចផ្សេងៗ | 400 |
| ចេក | 1667 |
| ផ្លែទៀប | 400 |
| ផ្លែទៀបបារាំង | 400 |
| ផ្លែត្របែក | 400 |
| ផ្លែមៀន | 278 |
| ស្វាយ | 270 |

| | |
|---|---|
| ផ្លែល្មុង | 1600 |
| ផ្លែម្នាស់ | 14000 |
| ផ្លែខ្វិត | 400 |
| ផ្លែខ្នុរ | 270 |
| ចំប៉ាដក់ | 270 |
| ផ្លែទទឹម | 600 |
| ល្មុត | 278 |
| ផ្លែសាវម៉ាវ | 156 |
| ផ្លែមង្ឃុត | 100 |
| ផ្លែត្របៀក | 270 |
| អំពិលទឹក | 70 |
| ទុរេន | 270 |
| ផ្លែទឹកដោះគោ | 270 |
| ផ្លែឈូក | 25000 |
| ជម្ពូ | 278 |
| ផ្លែម៉ាក់ប្រាង | 270 |
| ផ្លែម្កាក់ | 278 |
| ផ្លែព្រីង | 270 |
| ផ្លែពុទ្រា | 278 |
| ផ្លែគូលែន | 156 |
| ផ្លែស្ពឺ | 300 |
| ផ្លែស្រកានាជ | 2500 |

| | |
|---|---|
| ផ្លែទលឹងទឹង | 300 |
| ផ្លែប៉ះស្បុង | 156 |
| ផ្លែកំពីងរាជ | 100 |
| កន្ទួត | 400 |
| ផ្លែល្មើ | 200 |
| ផ្លែញ | 300 |
| ផ្លែប៉ររ | 280 |
| ដំណាំផ្លែផ្សេងៗ | 280 |
| គ្រាប់ស្វាយចន្ទី | 278 |
| ស្លា | 2500 |
| ឈូក | 25000 |
| ដំណាំភេសជ្ជៈផ្សេងៗ | 1000 |
| ដូង | 278 |
| ដូងប្រេង | 278 |
| ដើមត្នោត | 1000 |
| ម្រេច | 2500 |
| ក្រសាំង | 250 |
| អំពិល | 70 |
| ដំណាំគ្រឿងទេសផ្សេងៗ | 1000 |
| កៅស៊ូ | 555 |
| ដំណាំយកជ័រ | 500 |
| ផ្កាម្លិះ | 5000 |

| | |
|---|---|
| ផ្កាចន្ទ | 3000 |
| ផ្កាចំប៉ី | 200 |
| ផ្កាម្លូ | 20000 |
| ដំណាំផ្កាផ្សេងៗ | 1500 |
| ដើមចេកមាស | 15000 |
| ដើមខ្ចី | 10000 |
| ដើមរាសី | 15000 |
| ឫស្សី | 10000 |
| ដើមប្រេងខ្យល់ | 7000 |
| ឈើច័ន្ទក្រឹស្នា | 1600 |

*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ   សាសនា   ព្រះមហាក្សត្រ

# អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤

## ផ្នែកទី៣: ការចិញ្ចឹមបសុសត្វ និងបសុបក្សី



**វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ**

សហការជាមួយ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

គាំទ្របច្ចេកទេសដោយៈ

អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ

គាំទ្រហិរញ្ញវត្ថុដោយៈ គំនិតផ្តួចផ្តើម ៥០x២០៣០

# ការចិញ្ចឹមបសុសត្វ និងបសុបក្សី

នៅក្នុងកម្ពុជា ការចិញ្ចឹមបសុសត្វ និងបសុបក្សី គឺជាសកម្មភាពកសិកម្មដ៏សំខាន់មួយដែលធ្វើឡើងដោយគ្រួសារកសិកម្ម ដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃ និងផ្តល់ប្រាក់ចំណូលដល់គ្រួសារនៅទីជនបទ។ ក្នុងចំណោមគ្រួសារកសិកម្មសរុបនៅកម្ពុជាមានគ្រួសារចូលរួមសកម្មភាពចិញ្ចឹមបសុសត្វ/បសុបក្សី/សត្វល្អិត ចំនួន ១ ៣៤២ ៧៥០គ្រួសារ។ ការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ បានបែងចែកបសុសត្វជាពីរ គឺប្រភេទបសុសត្វធំ (គោ និង ក្របី) និងប្រភេទបសុសត្វតូច (ជ្រូក និងពពែ)។

**តារាង៣.១. ចំនួនគ្រួសារកសិកម្មដែលចិញ្ចឹមបសុសត្វ និងបសុបក្សី (គិតជាពាន់)**

| កម្ពុជា (ចំនួនគ្រួសារ គិតជាពាន់) | | | |
|---|---|---|---|
| សរុប | បសុសត្វធំ<br>(គោ ក្របី សេះ) | បសុសត្វតូច<br>(ជ្រូក ពពែ) | បសុបក្សី<br>(មាន់ ទា ត្រចៀកកាំ) |
| ១ ៣៤៣ | ៧២២ | ១០១ | ១ ០៦៦ |

គ្រួសារកសិកម្មដែលបានចូលរួមធ្វើសកម្មភាពចិញ្ចឹមសត្វបានបង្ហាញថា បសុបក្សី និងបសុសត្វតូចភាគច្រើន គឺមាននៅតំបន់បឹងទន្លេសាប បន្ទាប់មកគឺតំបន់វាលទំនាប។ តែបសុសត្វធំ ត្រូវបានចិញ្ចឹមតំបន់វាលទំនាប ច្រើនជាងតំបន់បឹងទន្លេសាប។ តំបន់ភ្នំនិងខ្ពង់រាប មានការចិញ្ចឹមសត្វតិចជាងតំបន់ទាំងពីរខាងលើ ខណៈ ដែលតំបន់ឆ្នេរសមុទ្រមានចំនួនគ្រួសារ ដែលមានចិញ្ចឹមសត្វតិចជាងគេ។

**រូបភាព៣.១. ចំនួនគ្រួសារកសិកម្មដែលចិញ្ចឹម បសុសត្វ បសុបក្សី តាមតំបន់ ឆ្នាំ២០២៤**




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

## បសុសត្វប្រភេទធំ




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

## សត្វគោ

ជាទូទៅ បសុសត្វប្រភេទធំដែលគ្រួសារកសិកម្មបានចិញ្ចឹមច្រើនជាងគេ គឺ គោ ដែលមានប្រមាណជា ៣ ១១៥ ០០០ ក្បាល នៅទូទាំងកម្ពុជា។ តំបន់វាលទំនាប គឺជាតំបន់មួយដែលមានការចិញ្ចឹមគោច្រើនជាងគេ (១ ១៨២ ០០០ក្បាល) ហើយជាបន្តបន្ទាប់ គឺតំបន់បឹងទន្លេសាប (១ ១៥៨ ០០០ក្បាល) តំបន់ភ្នំនិងខ្ពង់រាប (៦១០ ០០០ក្បាល) និងតំបន់ឆ្នេរសមុទ្រដែលជាតំបន់មានការចិញ្ចឹមគោតិចជាងបំផុត (១៦៥ ០០០ក្បាល) បើប្រៀបធៀបទៅនឹងតំបន់ទាំងបួន។

**រូបភាព៣.២. ចំនួនគ្រួសារកសិកម្មដែលចិញ្ចឹមគោ និងចំនួនគោ តាមតំបន់ ឆ្នាំ២០២៤**




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

នៅទូទាំងកម្ពុជា គ្រួសារដែលចិញ្ចឹមគោមានចំនួនគោជាមធ្យមប្រមាណ ៤,៥ ក្បាល ក្នុងមួយគ្រួសារ។ គ្រួសារកសិកម្មភាគច្រើនចិញ្ចឹមគោចាប់ពី ៣ទៅ៩ក្បាល (៣៨៤ ០០០គ្រួសារ) ខណៈដែល ១ទៅ២ក្បាល មានចំនួន ២៣៥ ០០០ គ្រួសារ ១០ទៅ១៩ក្បាល មានចំនួន ៤៦ ០០០ គ្រួសារ និងមានតែ ១៤ ០០០ គ្រួសារប៉ុណ្ណោះ ដែលបានរាយការណ៍ថាមានការចិញ្ចឹមគោច្រើនជាងចំនួន ២០ ក្បាល។

**រូបភាព៣.៣. ចំនួនគ្រួសារកសិកម្មបានចិញ្ចឹមគោចែកតាមហ្វូង កម្ពុជាឆ្នាំ២០២៤ (គិតជាពាន់)**




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

ចំនួនគោដែលបានចិញ្ចឹមដោយគ្រួសារកសិកម្មភាគច្រើន គឺជាគោញី ក្នុងនោះគោញីប្រមាណ ១,៧ លានក្បាល (ប្រមាណជា ៥៣,៩%) មានអាយុលើសពី២ឆ្នាំ ខណៈដែលគោឈ្មោលមានអាយុលើសពី២ឆ្នាំ មានចំនួនតិចតួចជាងគេ។




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

ចំនួនគោដែលមានចិញ្ចឹមក្នុងគ្រួសារកសិកម្ម គឺបានមកពីការកើតកូនបន្តពីមេពូជច្រើនលើសលុបជាងការទិញចូលយកមកចិញ្ចឹម។ នៅតំបន់វាលទំនាប មានចំនួនគោដែលបានកើតពីមេពូជមានច្រើនជាងគេ (២៣១ ០០០ក្បាល) បន្ទាប់មក គឺតំបន់បឹងទន្លេសាប (២២៦ ០០០ក្បាល) តំបន់ភ្នំនិងខ្ពង់រាប (១៣២ ០០០ក្បាល) និងតិចជាគេនៅតំបន់ឆ្នេរសមុទ្រ (២៩ ០០០ក្បាល)។




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

បម្រែបម្រួលសត្វ គឺជាការកែប្រែប្រួលនូវចំនួនសត្វចិញ្ចឹមតាមគ្រួសារកសិកម្មក្នុងរយៈពេល១២ខែកន្លងមក ដូចជាការលក់ ការស្លាប់ សម្លាប់យកសាច់ ឬឱ្យទៅអ្នកផ្សេងជាដើម។ ការប្រែប្រួលចំនួនគោដែលបានចិញ្ចឹមដោយគ្រួសារកសិកម្មនូវទូទាំងប្រទេសក្នុងរយៈពេល១២ខែកន្លងមក បានបង្ហាញថា ភាគច្រើនគឺការចិញ្ចឹមលក់រស់ (៧៤៣ ០០០ក្បាល) ហើយបន្ទាប់មក គឺការស្លាប់ដោយធម្មជាតិឬដោយជំងឺមាន ១០១ ០០០ក្បាល ផ្តល់ជាអំណោយមាន ៨ ០០០ក្បាល ខណៈដែលការសម្លាប់យកសាច់ និងលួចមានចំនួន ៦ ០០០ ក្បាលដូចគ្នា។

**រូបភាព៣.៦. ចំនួនបម្រែបម្រួលសត្វគោ ប្រទេសកម្ពុជា ឆ្នាំ២០២៤**




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*



*ប្រភពរូបថត៖ វិទ្យាស្ថានជាតិស្ថិតិ គ្រួសារចិញ្ចឹមគោ ឆ្នាំ២០២៤*

## សត្វក្របី

គ្រួសារដែលប្រកបរបរកសិកម្មដែលមានចិញ្ចឹមក្របីនៅទូទាំងកម្ពុជាបានរាយការណ៍ថា មានក្របីសរុបប្រមាណ ២៩៩ ០០០ក្បាល។ នៅតំបន់បឹងទន្លេសាប មានក្របីច្រើនជាងគេ (១៣៨ ០០០ក្បាល) បន្ទាប់មកតំបន់វាលទំនាបមានចំនួន ១០៥ ០០០ក្បាល ហើយតំបន់ភ្នំនិងខ្ពង់រាប ដែលមានប្រមាណ ៤៣ ០០០ក្បាល និងតំបន់ឆ្នេរសមុទ្រ មានប្រមាណ ១៤ ០០០ក្បាល។

**រូបភាព៣.៧. ចំនួនគ្រួសារនិងចំនួនសត្វក្របីចែកតាមតំបន់ ឆ្នាំ២០២៤**




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

នៅទូទាំងកម្ពុជា ចំនួនសត្វក្របីជាហ្វូងគិតជាមធ្យម ប្រមាណ ៥,៨ក្បាល ក្នុង១គ្រួសារ។ គ្រួសារចិញ្ចឹមក្របីភាគច្រើនមានពី ៣ទៅ៩ក្បាល មានចំនួន ៣១ ០០០គ្រួសារ ហើយបន្ទាប់មក គឺពី១ ទៅ ២ក្បាល មានចំនួន ១៣ ០០០គ្រួសារ និងមានតែ ៧ ០០០គ្រួសារ ប៉ុណ្ណោះដែលបានរាយការណ៍ថាមានចិញ្ចឹមក្របីចាប់ពី ១០ក្បាល ឡើងទៅ។

**រូបភាព៣.៨. ចំនួនគ្រួសារកសិកម្មបានចិញ្ចឹមក្របី ចែកតាមចំនួនហ្វូង កម្ពុជាឆ្នាំ២០២៤ (គិតជាពាន់)**




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

ចំនួនក្របីដែលបានចិញ្ចឹមដោយគ្រួសារកសិកម្មភាគច្រើនគឺជាក្របីញី ដែលក្នុងនោះប្រមាណជា ៥២% មានអាយុលើសពី២ឆ្នាំ ចំណែក ក្របីឈ្មោលមានអាយុលើសពី២ឆ្នាំ មានចំនួនតិចជាងគេ។

**រូបភាព៣.៩. ចំនួនសត្វក្របី ចែកតាមអាយុ ភេទ កម្ពុជាឆ្នាំ២០២៤**




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

## បសុសត្វប្រភេទតូច

## សត្វជ្រូក

ប្រមាណជា ១០១ ០០០គ្រួសារ នៃគ្រួសារកសិកម្មបានចិញ្ចឹមជ្រូកនៅទូទាំងកម្ពុជា។ គ្រួសារនៅតំបន់បឹងទន្លេសាបមានការចិញ្ចឹមជ្រូកច្រើនជាងគេ (៣៩ ០០០គ្រួសារ) បន្ទាប់មក គឺ តំបន់វាលទំនាប

(៣២ ០០០គ្រួសារ) តំបន់ភ្នំនិងខ្ពង់រាប (២០ ០០០ក្បាល) និងនៅតំបន់ឆ្នេរសមុទ្រមានគ្រួសារចិញ្ចឹមជ្រូកតិចជាងគេ (៩ ០០០គ្រួសារ)។

**រូបភាព៣.១០. ចំនួនគ្រួសារចិញ្ចឹមជ្រូក និងចំនួនជ្រូកចែកតាមតំបន់ ឆ្នាំ២០២៤**




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

នៅទូទាំងកម្ពុជា ចំនួនជ្រូកដែលបានចិញ្ចឹមគិតជាមធ្យមក្នុងមួយគ្រួសារ គឺ ៩,៥ ក្បាល។ គ្រួសារកសិកម្មដែលចិញ្ចឹមជ្រូកចន្លោះពី ១ទៅ២ក្បាល មានចំនួន ២៣ ០០០គ្រួសារ ចាប់ពី ៣ទៅ៩ក្បាល មានចំនួន ៤១ ០០០ គ្រួសារ ពី១០ទៅ១៩ ក្បាល មានចំនួន ២០ ០០០គ្រួសារ និងគ្រួសារដែលចិញ្ចឹមជ្រូកចាប់ពី ២០ក្បាលឡើងទៅ មានចំនួន ១៣ ០០០ គ្រួសារ។

**រូបភាព៣.១១. ចំនួនគ្រួសារកសិកម្មចិញ្ចឹមជ្រូកចែកតាមចំនួនជ្រូក កម្ពុជាឆ្នាំ២០២៤ (គិតជាពាន់)**




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

ជ្រូកដែលចិញ្ចឹមក្នុងគ្រួសារភាគច្រើនជាសត្វដែលមានអាយុតិចជាង១ឆ្នាំ (ប្រមាណ ៧៣៨ ០០០ក្បាល ឬ ៧៧% នៃជ្រូកទាំងអស់)។ លើសពីនេះ ជ្រូក ប្រមាណ ៥៨% នៃជ្រូកសរុបគឺ ជាជ្រូកញី។

**រូបភាព៣.១២. ចំនួនសត្វជ្រូក ចែកតាមអាយុ និងភេទ កម្ពុជាឆ្នាំ២០២៤**




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

ចំនួនជ្រូកដែលចិញ្ចឹមក្នុងគ្រួសារកសិកម្ម គឺបានមកពីការកើតកូនបន្តពីមេពូជជាជាងការទិញចូលយកមកចិញ្ចឹម។ នៅតំបន់បឹងទន្លេសាប ចំនួនជ្រូកដែលបានកើតពីមេពូជមានច្រើនជាងគេ (២៨៣ ០០០ក្បាល) បន្ទាប់មក គឺតំបន់វាលទំនាប (២៣០ ០០០ក្បាល) នៅតំបន់ភ្នំ និងខ្ពង់រាបមាន ៨១ ០០០ក្បាល និងនៅតំបន់ឆ្នេរសមុទ្រមានចំនួន ៥២ ០០០ក្បាល។

**រូបភាព៣.១៣. ចំនួនជ្រូក បានកើត និងទិញ ចែកតាមតំបន់ ឆ្នាំ២០២៤**




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

# បសុបក្សី




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

ការប្រមូលទិន្នន័យអង្កេតកសិកម្មត្រូវបានប្រមូលព័ត៌មានពីការចិញ្ចឹមបសុបក្សីផងដែរ។ នៅក្នុងតារាងទិន្នន័យលទ្ធផលដែលបានផ្សព្វផ្សាយអំពីបសុបក្សី មានដូចជា មាន់ ទា និងក្ងាន ហើយរបាយការណ៍នេះផ្ដោតតែលើការចិញ្ចឹមបសុបក្សីដែលសំខាន់ជាងគេ គឺសត្វមាន់ និងទា។



## សត្វមាន់

មាន់ គឺជាប្រភេទបសុបក្សី ដែលគ្រួសារកសិកម្មបានចិញ្ចឹមច្រើនជាងគេមានចំនួន ១ ០៤២ ០០០ គ្រួសារ ស្មើនឹង ២៥លានក្បាល នៅទូទាំងប្រទេស។ នៅតំបន់បឹងទន្លេសាបមាន មានគ្រួសារចិញ្ចឹមមាន់ច្រើនជាងគេចំនួន ៤០៧ ០០០គ្រួសារ បន្ទាប់មកតំបន់វាលទំនាប មាន ៣៨១ ០០០គ្រួសារ ហើយតំបន់ភ្នំ និងខ្ពង់រាបមានចំនួន ១៥៦ ០០០គ្រួសារ ឬនៅតំបន់ឆ្នេរសមុទ្រមានចំនួន ៩៧ ០០០គ្រួសារ ។ ចំនួនមាន់ជាមធ្យមដែលចិញ្ចឹមក្នុងមួយគ្រួសារគឺ ២៤ក្បាល។

**រូបភាព៣.១៤. ចំនួនគ្រួសារកសិកម្មចិញ្ចឹមមាន់ ចែកតាមតំបន់ ឆ្នាំ២០២៤**




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

នៅតំបន់បឹងទន្លេសាប បានរាយការណ៍ថាមានចំនួនមាន់ច្រើនជាងគេសរុបប្រមាណ ១០លានក្បាល។ នៅតំបន់វាលទំនាប មានចំនួន ៩,១លានក្បាល តំបន់ភ្នំ និងខ្ពង់រាបមានចំនួន ៣,៥លានក្បាល និងនៅតំបន់ឆ្នេរសមុទ្រមានចំនួន ៣,២លានក្បាល។

**រូបភាព៣.១៥. ចំនួនមាន់សរុប ចែកតាមតំបន់ ឆ្នាំ២០២៤**




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

ការចិញ្ចឹមមាន់របស់គ្រួសារកសិកម្មគឺបានមកពីការកើតកូនបន្តពូជ ច្រើនជាងលើសលុបពីការទិញមាន់ចូលយកមកចិញ្ចឹម។ នៅតំបន់បឹងទន្លេសាប មានមាន់កើតកូនបន្តពូជច្រើនជាងគេចំនួនប្រមាណ ១០,៨លានក្បាល បន្ទាប់មកនៅតំបន់វាលទំនាប មាន ៨,៩លានក្បាល ហើយតំបន់ភ្នំ និងខ្ពង់រាប មានចំនួន ប្រមាណ ៣,៧ លានក្បាល និងតំបន់ឆ្នេរសមុទ្រមានចំនួនប្រមាណ ២,៤ លានក្បាល។

**រូបភាព៣.១៦. ចំនួនមាន់បានកើត ចែកតាមតំបន់ ឆ្នាំ២០២៤**




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

ចំពោះបម្រែបម្រួលសត្វមាន់ទូទាំងប្រទេសក្នុងរយៈពេល១២ ខែកន្លងមក ដែលបានចិញ្ចឹមដោយគ្រួសារកសិកម្មបានបង្ហាញថាភាគច្រើន គឺស្លាប់ដោយសារធម្មជាតិ និងជំងឺឆ្លងផ្សេងៗដែលមានចំនួន ១១,៦លានក្បាល ការសម្លាប់យកសាច់ ចំនួន ៩,២លានក្បាល និងមាន់ដែលបានលក់ទាំងរស់មានចំនួន ៦,១លានក្បាល។

**រូបភាព៣.១៧. បម្រែបម្រួលចំនួនមាន់ កម្ពុជាឆ្នាំ២០២៤**




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*



## សត្វទា

ទា គឺជាប្រភេទបសុបក្សីទី២ ដែលគ្រួសារកសិកម្មភាគច្រើនបានចិញ្ចឹម។ មានគ្រួសារកសិកម្មចំនួន ១៥៥ ០០០ គ្រួសារដែលបានចិញ្ចឹមទា ជាមួយនឹងចំនួនទា ១០,៥លានក្បាល នៅទូទាំងប្រទេស។ នៅតំបន់វាលទំនាប មានគ្រួសារចិញ្ចឹមទាច្រើនជាងគេចំនួន ៦៨ ០០០គ្រួសារ បន្ទាប់មកតំបន់បឹងទន្លេសាប មាន ៥៧ ០០០គ្រួសារ ហើយតំបន់ឆ្នេរសមុទ្រ មានចំនួន ១៧ ០០០គ្រួសារ និងតំបន់ភ្នំ និងខ្ពង់រាបមានចំនួន ១៤ ០០០គ្រួសារ។ ចំនួនទាជាមធ្យមដែលចិញ្ចឹមក្នុងមួយគ្រួសារគឺ ៦៧ក្បាល ។

**រូបភាព៣.១៨. ចំនួនគ្រួសារកសិកម្មចិញ្ចឹមទា ចែកតាមតំបន់ ឆ្នាំ២០២៤**




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

នៅតំបន់វាលទំនាប មានចំនួនទាសរុបប្រមាណ ៦,៤លានក្បាល ហើយតំបន់បឹងទន្លេសាប មានចំនួនប្រហែល ២,៨លានក្បាល។ ចំណែកឯតំបន់ឆ្នេរសមុទ្រ មានទាចំនួនប្រហែល ៩៤០ ០០០ក្បាល និងតំបន់ភ្នំ និងខ្ពង់រាបមានទាចំនួនប្រហែល ២៧៧ ០០០ក្បាល។

**រូបភាព៣.១៩ ចំនួនទាសរុប ចែកតាមតំបន់ ឆ្នាំ២០២៤**



*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

ក្នុងរយៈពេល១២ ខែកន្លងមក ការចិញ្ចឹមទារបស់គ្រួសារកសិកម្ម គឺបានមកពីការកើតកូនបន្តពូជច្រើនជាងលើសលុបពីការទិញទាចូលយកមកចិញ្ចឹម។ នៅតំបន់វាលទំនាប មានទាកើតកូនបន្តពូជច្រើនជាងគេចំនួន ៨៩៨ ០០០ក្បាល បន្ទាប់មកគឺតំបន់បឹងទន្លេសាប មាន ៧២៤ ០០០ក្បាល ហើយតំបន់ភ្នំ និងខ្ពង់រាបមានប្រមាណ ២២៤ ០០០ក្បាល និងនៅតំបន់ឆ្នេរសមុទ្រមានចំនួនប្រមាណ ១៧៥ ០០០ក្បាល។

**រូបភាព៣.២០. ចំនួនទាបានកើត ចែកតាមតំបន់ ឆ្នាំ២០២៤**




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

បម្រែបម្រួលសត្វទាទូទាំងប្រទេសក្នុងរយៈពេល១២ ខែកន្លងមក នៃការចិញ្ចឹមទារបស់គ្រួសារកសិកម្ម បានបង្ហាញថា ការលក់រស់មានចំនួនប្រមាណ ២,២ លានក្បាល ហើយចំនួន ១,២ លានក្បាល បានស្លាប់ដោយសារធម្មជាតិ ជំងឺ និងជំងឺឆ្លងផ្សេងៗ និងមាន ៧៩៤ ០០០ក្បាល ត្រូវបានសម្លាប់យកសាច់លក់ ឬធ្វើម្ហូប។

**រូបភាព៣.២១. បម្រែបម្រួលចំនួនទា កម្ពុជាឆ្នាំ២០២៤**




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

## ចំណីសត្វ

ការឱ្យសត្វស៊ីចំណីតាមធម្មជាតិត្រូវបានអនុវត្តភាគច្រើន ក្នុងចំណោមគ្រួសារកសិកម្មទាំងលើបសុសត្វ និងបសុបក្សី ខណៈការផ្តល់ចំណីសុទ្ធត្រូវបានអនុវត្តតិចតួចបំផុត។

**រូបភាព៣.២២. ការអនុវត្តការផ្តល់ចំណីឱ្យសត្វរបស់គ្រួសារកសិកម្ម កម្ពុជាឆ្នាំ២០២៤**




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

កាកសំណល់ផ្ទះបាយ ដូចជាកន្ទក់ ឬបាយស្រា ត្រូវបានប្រើប្រាស់ញឹកញាប់ជាងគេសម្រាប់ជាចំណីបសុបក្សីដោយគ្រួសារកសិកម្ម ដំណាំ/ស្មៅសម្រាប់សត្វ ជាជម្រើសបន្ទាប់ ខណៈដែល សំណល់ដំណាំដូចជាចំបើង ឬសំបកពោត និងដំណាំ/ស្មៅសម្រាប់សត្វ ត្រូវបានប្រើប្រាស់ញឹកញាប់ជាងគេសម្រាប់ជាចំណីបសុសត្វ

ដោយគ្រួសារកសិកម្ម។ ចំណែកឯ ផលិតផលកសិឧស្សាហកម្ម ដូចជាកាកគ្រាប់ប្រេង ឬកាកស្រូវសាឡី (កាកប៊ីយែរ) គឺត្រូវបានប្រើប្រាស់តិចតួចជាងគេទាំងលើបសុសត្វ និងបសុបក្សី។

**រូបភាព៣.២៣. ប្រភេទចំណីសត្វផ្តល់ឱ្យសត្វរបស់គ្រួសារកសិកម្ម កម្ពុជាឆ្នាំ២០២៤**




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤

## ផ្នែកទី៤៖ វារីវប្បកម្ម និងការនេសាទ



**វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ**

សហការជាមួយ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

គាំទ្របច្ចេកទេសដោយ៖

អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ

គាំទ្រហិរញ្ញវត្ថុដោយ៖ គំនិតផ្តួចផ្តើម ៥០x២០៣០

# វារីវប្បកម្ម និងការនេសាទ

វារីវប្បកម្ម និងនេសាទ ជាសកម្មភាពសេដ្ឋកិច្ចជំនួស ឬសកម្មភាពសេដ្ឋកិច្ចបន្ថែម សម្រាប់គ្រួសារកាន់កាប់កសិកម្មនៅក្នុងប្រទេសកម្ពុជា។ ការអង្កេតកសិកម្មឆ្នាំ២០២៤ នេះ អាចប៉ាន់ស្មានថា គ្រួសារដែលបានកាន់កាប់កសិកម្មចំនួន៨០ ៦០០គ្រួសារ បានបានចូលរួមទាំងនៅក្នុងសកម្មភាពវារីវប្បកម្ម និងនេសាទ។ ខណៈដែលការកាន់កាប់កសិកម្មគ្រួសារកសិកម្មមានចំនួន ៣៨៧ ៣០០ នាក់ ចូលរួមក្នុងសកម្មភាពនេសាទ និងគ្រួសារកាន់កាប់កសិកម្មចំនួន ២៦ ១០០ នាក់ បានចូលរួមទាំងវារីវប្បកម្ម និងសកម្មភាពនេសាទ។ តំបន់ដែលមានចំនួនគ្រួសារច្រើនជាងគេក្នុងវិស័យវារីវប្បកម្ម គឺតំបន់វាលទំនាបដែលមានគ្រួសារកាន់កាប់កសិកម្មចំនួន ៥៥ ១០០ គ្រួសារ បានរាយការណ៍ពីសកម្មភាពវារីវប្បកម្ម។ តំបន់ដែលមានចំនួនគ្រួសារច្រើនជាងគេបានចូលរួមក្នុងសកម្មភាពនេសាទ គឺតំបន់បឹងទន្លេសាប មានចំនួន១៧៤ ២០០ គ្រួសារ ដែលបានរាយការណ៍ពីសកម្មភាពនេសាទ។

## វារីវប្បកម្ម



*រូបភាព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០២៤ ស្រះចិញ្ចឹមត្រីនៅខេត្តកណ្តាល*

វារីវប្បកម្ម គឺសំដៅទៅលើវប្បកម្មវារីជាតិនៅក្នុងសមុទ្រ បឹង ទន្លេ និងតំបន់វាលល្បាប់ ឬដែនទឹកផ្សេងទៀត ដូចជា ស្រះ វាលស្រែ ឬតំបន់ផ្សេងទៀត នៅក្រោមគ្រប់គ្រង។ ក្នុងចំណោមសកម្មភាពខុសៗគ្នានៃវារីវប្បកម្មដែលបានប្រមូលទិន្នន័យនៅក្នុងការអង្កេតកសិកម្មឆ្នាំ២០២៤ ការធ្វើវារីវប្បកម្មនៅក្នុងស្រះ បែរ ទ្រុង វាលស្រែ តង់/លូ/ធុង/ស្តុរ/អាង អាងភ្ញាស់/អាងបំប៉ន កន្លែងផ្សាំ ឬសកម្មភាពវារីវប្បកម្មដទៃទៀត ដែលក្នុងនោះ សកម្មភាពដែលមានច្រើនជាងគេ គឺការធ្វើវារីវប្បកម្មក្នុងស្រះ ដែលមានគ្រួសារកសិកម្មចំនួន ៦៤ ៣០០

គ្រួសារ បានឆ្លើយពីវារីវប្បកម្មនៅក្នុងស្រះ។ មានគ្រួសារកសិកម្មត្រឹមតែ ៧ ៩០០ គ្រួសារកសិកម្មបានធ្វើវារីវប្បកម្មក្នុងបែរ ហើយ ៧ ០០០ គ្រួសារកសិកម្ម បានប្រើប្រាស់លូ/ធុង/ស្តូវ/អាង ឬទ្រុង។

រូបភាព៤.១ ចំនួនគ្រួសារកសិកម្ម ដែលរាយការណ៍អំពីសកម្មភាពវារីវប្បកម្មតាមតំបន់ ឆ្នាំ២០២៤




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

ផ្ទៃដីសរុបដែលបានប្រើប្រាស់សម្រាប់ធ្វើវារីវប្បកម្មក្នុងគ្រួសារកាន់កាប់កសិកម្មមាន ១ ៧០៨ ហិកតា ក្នុងនោះ តំបន់ដែលមានការកាន់កាប់សកម្មភាពវារីវប្បកម្មច្រើនជាងគេ គឺតំបន់វាលទំនាប ដែលមានផ្ទៃដី ១ ០៤៤ ហិកតា។ ការចិញ្ចឹមតាមវារីវប្បកម្ម ចំនួនត្រីដែលមាននៅថ្ងៃសម្ភាសន៍សម្រាប់ការអង្កេតនេះ គ្រួសារដែលចិញ្ចឹមត្រីប្រា (មានចំនួន ៥១ ៣០០ គ្រួសារ) និងគ្រួសារបានចិញ្ចឹមត្រីអណ្តែង (មាន១៧ ២០០ គ្រួសារកាន់កាប់កសិកម្ម)។ ចំណែកត្រីរ៉ស់ ត្រីទីឡាព្យា ត្រីឆ្ពិន កង្កែប និងត្រីឆ្ដោក គឺជាប្រភេទត្រីចិញ្ចឹមសម្រាប់ប្រើប្រាស់ក្នុងគ្រួសារតែប៉ុណ្ណោះ។

រូបភាព៤.២ ចំនួនគ្រួសារកាន់កាប់កសិកម្ម ដែលបានរាយការណ៍ពីសកម្មភាពវារីវប្បកម្ម ឆ្នាំ២០២៤




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

## ការនេសាទត្រី



*រូបភាព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០២៤ នេសាទត្រីនៅក្នុងខេត្តកណ្ដាល*

ការអង្កេតកសិកម្ម ឆ្នាំ២០២៤ សកម្មភាពនេសាទត្រូវបានបែងចែកទៅតាមប្រភេទទឹកសាប ទន្លេ ឬបឹង ទឹកសមុទ្រ ទឹកភ្លាវ ឬតាមវាលស្រែ។ សកម្មភាពនេសាទ រួមមាន ការនេសាទត្រី និងវារីជាតិដទៃទៀតក្នុងសមុទ្រ តំបន់ឆ្នេរសមុទ្រ និងក្នុងដែនទឹកសាបនានា ដោយមាន ឬមិនមានការប្រើប្រាស់ទូក ឬឧបករណ៍នេសាទឯកទេស។ ការនេសាទនេះ គិតចាប់ពីពេលណាមួយក្នុងអំឡុងឆ្នាំយោងនៃអង្កេតឆ្នាំ២០២៤ ដោយគិតចាប់ពីថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០២៣ ដល់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០២៤។ យោងតាមការអង្កេតកសិកម្ម បានប៉ាន់ប្រមាណថា តំបន់បឹងទន្លេសាប មានគ្រួសារកសិកម្មធ្វើនេសាទច្រើនជាងគេ មានចំនួន ១៧៤ ០០០ គ្រួសារ ដែលបានចូលរួមក្នុងសកម្មភាពនេសាទ ក្នុងនោះតំបន់វាលទំនាបមានចំនួន ១០៦ ០០០ គ្រួសារ ឬតំបន់ភ្នំ និងខ្ពង់រាប មានចំនួន ៨០ ០០០ គ្រួសារ និងតំបន់ឆ្នេរសមុទ្រមានចំនួន ២៧ ០០០ គ្រួសារ ដែលបានរាយការណ៍ពីសកម្មភាពការធ្វើនេសាទ។

រូបភាព៤.៣  ចំនួនគ្រួសារកសិកម្ម ដែលរាយការណ៍អំពីសកម្មភាពនេសាទបែងចែកតាមតំបន់ ឆ្នាំ២០២៤




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

សកម្មភាពនេសាទដែលបានរាយការណ៍ដោយមេគ្រួសារភាគច្រើនកើតឡើងនៅក្នុងទន្លេ ឬ បឹង (មានចំនួន ១៨០ ០០០គ្រួសារ) និងនេសាទតាមវាលស្រែ (ចំនួន ២៣១ ០០០ គ្រួសារ)។ ធៀបទៅនឹងរបាយការណ៍នៃគ្រួសារតិចតួចដែលបានចាប់យកការនេសាទនៅក្នុងទឹកសមុទ្រ (មានចំនួន ៨ ០០០ គ្រួសារ)។

រូបភាព៤.៤ ចំនួនគ្រួសារកាន់កាប់កសិកម្មដែលពាក់ព័ន្ធសកម្មភាពផលត្រីនេសាទ
នៅប្រទេសកម្ពុជា ឆ្នាំ២០២៤ (គិតតាមប្រភេទ)




*ប្រភព៖ អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

ផលនេសាទត្រីសរុប ត្រូវបានរាយការណ៍ថា មាន ៤១៦ លានគីឡូក្រាម។ បើយោងតាមទិន្នន័យនៃការធ្វើអង្កេត ឆ្នាំ២០២៤ ជាងពាក់កណ្តាលនៃអ្នកឆ្លើយ គឺមាន ៥៦% នៃគ្រួសារកសិកម្មដែលបានរាយការណ៍ថា ផលនេសាទក្នុងឆ្នាំបច្ចុប្បន្នបានផលប្រហាក់ប្រហែលនឹងផលនេសាទកាលពីឆ្នាំមុន ៣៨% នៃគ្រួសារកសិកម្ម បានរាយការណ៍ថា ផលនេសាទបានទាបជាងឆ្នាំមុន ហើយមាន ៦% នៃគ្រួសារកសិកម្ម បានរាយការណ៍ ថាផលនេសាទច្រើនជាងឆ្នាំមុន។

រូបភាព៤.៥ ការប្រៀបធៀបរវាងផលនេសាទក្នុងឆ្នាំបច្ចុប្បន្នទៅឆ្នាំមុន នៃគ្រួសារកសិកម្ម ឆ្នាំ២០២៤




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

ការអង្កេតកសិកម្មឆ្នាំ២០២៤ បានប្រមូលទិន្នន័យអំពីវារីជាតិជាច្រើនប្រភេទដែលបាននេសាទក្នុងនោះ រួមមាន ត្រី ក្តាម ខ្យង និងអន្ទង់។ ប្រមាណជា ៨១% គ្រួសារបានរាយការណ៍ពីសកម្មភាពនេសាទត្រី (ស្មើនឹង ៣៤៩ ៥០០ គ្រួសារ) ១១% នេសាទក្តាម (ស្មើនឹង ៤៩ ១០០ គ្រួសារ) ៦% នេសាទខ្យង (ស្មើនឹង ២៤ ៦០០ គ្រួសារ) និង ១% បាននេសាទអន្ទង់ (ស្មើនឹង ៣ ៦០០ គ្រួសារ)។

ឧបករណ៍នេសាទជាច្រើនប្រភេទត្រូវបានប្រើប្រាស់នៅក្នុងកម្ពុជា។ តាមលទ្ធផលនៃការអង្កេតកសិកម្មឆ្នាំ២០២៤ នេះ បានប៉ាន់ស្មានថា តើមានគ្រួសារប៉ុន្មានប្រើប្រាស់ឧបករណ៍នីមួយៗក្នុងសកម្មភាពនេសាទរបស់ពួកគេ។ ឧបករណ៍នេសាទដែលគ្រួសារបានប្រើប្រាស់ភាគច្រើន គឺ មង (មានប្រមាណ ២៣៩ ០០០ គ្រួសារ) សំណាញ់ (៩៦ ២០០ គ្រួសារ) ការចាប់ដោយដៃ (១៧ ៨០០ គ្រួសារ) និងប្រើប្រាស់មងក្តាម (២ ៤០០ គ្រួសារ) ក្រៅពីនេះមានគ្រួសាជាច្រើនទៀតប្រើឧបករណ៍នេសាទផ្សេងៗទៀត។

រូបភាព៤.៦ ចំនួនគ្រួសារកាន់កាប់កសិកម្ម បានរាយការណ៍ពីឧបករណ៍នេសាទ ឆ្នាំ២០២៤




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ   សាសនា   ព្រះមហាក្សត្រ

# អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤

## ផ្នែកទី៥: សកម្មភាពសេដ្ឋកិច្ច



**វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ**

សហការជាមួយ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

គាំទ្របច្ចេកទេសដោយ៖

អង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ

គាំទ្រហិរញ្ញវត្ថុដោយ៖ គំនិតផ្តួចផ្តើម ៥០x២០៣០

# គ្រឿងម៉ាស៊ីន និងឧបករណ៍សម្ភារបរិក្ខារកសិកម្ម

ផ្នែកគ្រឿងម៉ាស៊ីន និងឧបករណ៍សម្ភារបរិក្ខារកសិកម្ម (MEA) ត្រូវបានបញ្ចូល ដើម្បីបង្កើតទិន្នន័យដែលមានសារៈសំខាន់សម្រាប់គោលនយោបាយអំពីមធ្យោបាយផលិតកម្ម ដែលប្រើដោយកសិដ្ឋានជាផ្នែកបង្ហិលជុំមួយនៃការអង្កេតកសិកម្មឆ្នាំ២០២៤។ នៅកម្ពុជាវិស័យកសិកម្មនៅតែគ្របដណ្តប់ដោយគ្រួសារកសិករតូចៗ ហើយបញ្ហាកង្វះកម្លាំងពលកម្ម និងដីកសិកម្មកំពុងកើនឡើង ការយល់ដឹងអំពីលំនាំនៃការប្រើនិងការប្រើប្រាស់គ្រឿងម៉ាស៊ីន គឺមានសារៈសំខាន់ក្នុងការកែលម្អផលិតភាពកសិកម្ម និងជីវភាពរស់នៅជនបទ។

ហេតុផលសំខាន់ក្នុងការរួមបញ្ចូលផ្នែកគ្រឿងម៉ាស៊ីន និងឧបករណ៍សម្ភារបរិក្ខារកសិកម្ម (MEA) ទៅក្នុងការអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ គឺផ្អែកលើភស្តុតាងកាន់តែច្រើនដែលបង្ហាញអំពីលទ្ធភាពនៃការប្រើប្រាស់គ្រឿងម៉ាស៊ីនកសិកម្មយ៉ាងទូលំទូលាយទៅលើប្រព័ន្ធស្រោចទឹក យានជំនិះដឹកជញ្ជូន និងបច្ចេកវិទ្យាបន្ទាប់ពីការប្រមូលផល រួមចំណែកយ៉ាងសំខាន់ដល់ការធ្វើទំនើបកម្មកសិកម្ម។ លទ្ធភាពបែបនេះមិនត្រឹមតែជួយកាត់បន្ថយការចំណាយលើកម្លាំងពលកម្ម និងភាពគ្មានប្រសិទ្ធភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយបង្កើនផលិតភាព ប្រាក់ចំណូលកសិករ និងជីវភាពរស់នៅប្រជាជនជនបទផងដែរ។ ក្នុងពេលជាមួយគ្នានេះ ភាពមិនស្មើគ្នានៃកម្មសិទ្ធិនិងការប្រើប្រាស់ទ្រព្យសម្បត្តិទៅតាមភេទ តំបន់ភូមិសាស្ត្រ និងទំហំកសិដ្ឋានអាចជាហេតុបណ្តាលឱ្យមិនមានសមធម៌ជាបន្តបន្ទាប់ និង ការប្រើប្រាស់សក្តានុពលកសិកម្មមិនបានពេញលេញ។

គោលបំណងរបស់ផ្នែកគ្រឿងម៉ាស៊ីន និងឧបករណ៍សម្ភារបរិក្ខារកសិកម្ម (MEA) មានពីរចំណុចសំខាន់ៗ៖

- ទីមួយ ដើម្បីប្រមូលទិន្នន័យតំណាងជាតិជាប្រព័ន្ធស្តីពីកម្មសិទ្ធិ ការទទួលបាន និងការប្រើប្រាស់គ្រឿងម៉ាស៊ីន និងឧបករណ៍សម្ភារបរិក្ខារកសិកម្មរបស់គ្រួសារកាន់កាប់កសិកម្មនៅកម្ពុជា។ ទាំងនេះរាប់បញ្ចូលទាំងការកំណត់ប្រភេទនៃទ្រព្យសម្បត្តិដែលកាន់កាប់លក្ខខណ្ឌ និងទម្រង់ប្រើប្រាស់របស់ពួកគេ ព្រមទាំងយន្តការដែលកសិករប្រើឧបករណ៍សម្ភារដែលបានទិញរួមគ្នា ឬ ជួល។
- ទីពីរ ដើម្បីផ្តល់ជាមូលដ្ឋានភស្តុតាង សម្រាប់ជួយណែនាំការសម្រេចចិត្តផ្នែកគោលនយោបាយ និងការវិនិយោគដែលទាក់ទងនឹងយន្តការកសិកម្ម ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ ភាពមិនស្មើក្នុងការកាន់កាប់ទ្រព្យសម្បត្តិ និងការប្រើបច្ចេកវិទ្យា។ ផ្នែកនេះ មានគោលបំណងគាំទ្រដល់យុទ្ធសាស្ត្រជាតិក្នុងការបង្កើនលទ្ធភាពប្រើបច្ចេកវិទ្យាកសិកម្ម ដែលមានតម្លៃសមរម្យ សមស្រប និងរួមបញ្ចូលនូវបច្ចេកវិទ្យាសម្រាប់កសិករទាំងអស់ ជាពិសេសកសិករខ្នាតតូច និងស្ត្រី។

តាមរយៈការចាប់យកព័ត៌មាននេះ ក្នុងក្របខណ្ឌការស្ទង់មតិកាន់តែទូលំទូលាយ ផ្នែកម៉ាស៊ីន និងឧបករណ៍សម្ភារបរិក្ខារកសិកម្ម (MEA) ជួយភ្ជាប់យន្តការជាមួយសូចនាករសំខាន់ៗនៃវិស័យកសិកម្ម ដែលអនុញ្ញាតឱ្យអ្នកបង្កើតគោលនយោបាយរៀបចំវិធានការផ្តោតជាក់លាក់ ដើម្បីបង្កើនផលិតភាព និងសមធម៌នៅក្នុងសេដ្ឋកិច្ចជនបទរបស់កម្ពុជា។

## ការប្រើប្រាស់គ្រឿងម៉ាស៊ីន និងឧបករណ៍សម្ភារបរិក្ខារកសិកម្ម

អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ បានផ្តល់នូវទិដ្ឋភាពទូទៅដ៏ទូលំទូលាយនៃគ្រឿងម៉ាស៊ីន និងឧបករណ៍សម្ភារបរិក្ខារកសិកម្ម ដែលប្រើប្រាស់នៅទូទាំងប្រទេស ដោយបង្ហាញពីការប្រែប្រួលសំខាន់ៗរវាងតំបន់កសិអេកូឡូស៊ី។ គ្រឿងម៉ាស៊ីន និងឧបករណ៍សម្ភារបរិក្ខារកសិកម្ម ដែលបានរួមបញ្ចូលក្នុងការអង្កេតនេះ ត្រូវបានបែងចែកជា ១០ប្រភេទ ដូចខាងក្រោមៈ

១. ប្រភេទឧបករណ៍ប្រើប្រាស់ដោយដៃ

២. ប្រភេទឧបករណ៍ដំណើរការដោយកម្លាំងសត្វ

៣. ប្រភេទឧបករណ៍ម៉ាស៊ីនស្រោចស្រព

៤. ប្រភេទគ្រឿងម៉ាស៊ីន និងឧបករណ៍សម្ភារបរិក្ខារកសិកម្មទូទៅ

៥. ត្រាក់ទ័រ ម៉ាស៊ីនឈូសឆាយ និងគ្រឿងយន្តផ្សេងៗ

៦. ប្រភេទឧបករណ៍ម៉ាស៊ីនរៀបចំដី និងដាំដំណាំ

៧. ប្រភេទឧបករណ៍ម៉ាស៊ីនថែទាំដំណាំ

៨. ប្រភេទឧបករណ៍ម៉ាស៊ីនប្រមូលផលដំណាំ

៩. ប្រភេទឧបករណ៍ម៉ាស៊ីនក្រោយការប្រមូលផលដំណាំ

១០. ប្រភេទឧបករណ៍ម៉ាស៊ីនផលិតកម្មសត្វ

នៅទូទាំងប្រទេស ឧបករណ៍ម៉ាស៊ីនស្រោចស្រព គឺមានការប្រើប្រាស់ច្រើនបំផុត ដោយមានចំនួន ៦៥៤ ៧០០គ្រួសារ បានរាយការណ៍។ បន្ទាប់មកទៀត គឺឧបករណ៍ម៉ាស៊ីនរៀបចំដី (៦២៩ ៤២០ គ្រួសារ) និងឧបករណ៍ម៉ាស៊ីនថែទាំដំណាំ (៦១១ ៤៦០ គ្រួសារ)។ ទិន្នន័យទាំងនេះ បង្ហាញពីការកើនឡើងនៃការប្រើប្រាស់គ្រឿងម៉ាស៊ីន ក្នុងដំណាក់កាលសំខាន់ៗនៃផលិតកម្មកសិកម្ម ជាពិសេសក្នុងការស្រោចស្រព និងការរៀបចំដី។

រូបភាព៥.១ គ្រួសារកាន់កាប់កសិកម្មរាយការណ៍អំពីការប្រើប្រាស់ឧបករណ៍/គ្រឿងម៉ាស៊ីន តាមប្រភេទឧបករណ៍/គ្រឿងម៉ាស៊ីន តាមតំបន់ ឆ្នាំ២០២៤




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

ការប្រើប្រាស់កម្លាំងពលកម្មដោយដៃនៅតែមានសារៈសំខាន់ ដោយមានគ្រួសារកាន់កាប់កសិកម្មចំនួន ៥៩១ ៩០០ គ្រួសារ ប្រើប្រាស់ឧបករណ៍ដោយដៃ ដែលឆ្លុះបញ្ចាំងពីការបន្តពឹងផ្អែកលើឧបករណ៍ប្រពៃណីនៅក្នុងប្រព័ន្ធកសិកម្មជាច្រើន។ ផ្ទុយទៅវិញ ឧបករណ៍ម៉ាស៊ីនប្រមូលផល (៣០៦ ៩៦០ គ្រួសារ) និងត្រាក់ទ័រ ម៉ាស៊ីនឈូសឆាយ ឬគ្រឿងយន្តផ្សេងៗ (៣០៤ ០២០ គ្រួសារ) ត្រូវបានប្រើប្រាស់ដោយកសិដ្ឋានមានចំនួនតិច នេះបង្ហាញថា គ្រឿងម៉ាស៊ីនកសិកម្ម សម្រាប់ដំណាក់កាលប្រមូលផល និងដំណើរការដឹកជញ្ជូននៅមិនទាន់ការប្រើប្រាស់ទូលំទូលាយនៅឡើយ។

មានភាពខុសគ្នាគួរឱ្យកត់សម្គាល់ផងដែររវាងតំបន់នានា។ តំបន់វាលទំនាប ដែលជាតំបន់កសិកម្មចម្បងរបស់កម្ពុជា មានអត្រាប្រើប្រាស់គ្រឿងម៉ាស៊ីនខ្ពស់ជាងគេ ដែលស្មើនឹងជាងពាក់កណ្តាលនៃចំនួនសរុបទូទាំងប្រទេសក្នុងប្រភេទមួយចំនួន រួមមានការប្រើប្រាស់គ្រឿងម៉ាស៊ីន សម្រាប់ស្រោចស្រព (៣៤៦ ៦០០ គ្រួសារ) និងឧបករណ៍ដោយដៃ (២៦៩ ៣០០ គ្រួសារ)។ ផ្ទុយទៅវិញ តំបន់ឆ្នេរសមុទ្រ មានអត្រាប្រើប្រាស់ទាបបំផុតស្ទើរតែគ្រប់ប្រភេទគ្រឿងម៉ាស៊ីនទាំងអស់ ដោយមានតែ ៣៣ ៩០០ គ្រួសារ ប្រើឧបករណ៍ស្រោចស្រព និងការប្រើប្រាស់ម៉ាស៊ីនថែទាំដំណាំ ឬម៉ាស៊ីនប្រមូលផលនៅមានកម្រិត។

តំបន់បឹងទន្លេសាប បានបង្ហាញពីការវិនិយោគយ៉ាងច្រើនលើគ្រឿងម៉ាស៊ីនរៀបចំដី (៣១៧ ៧៤០ គ្រួសារ) និងត្រាក់ទ័រ ឬគ្រឿងយន្ត (១៤៨ ៦៦០ គ្រួសារ) ដែលបង្ហាញពីសារៈសំខាន់របស់តំបន់នេះ សម្រាប់ការផលិតដំណាំជាច្រើន។ ខណៈពេលដែលតំបន់ភ្នំនិងខ្ពង់រាប ទោះបីជាមានអត្រាគ្រឿងម៉ាស៊ីនកសិកម្មទាបជាងគេក៏ដោយក៏មានការប្រើប្រាស់ម៉ាស៊ីនថែទាំដំណាំ (១២៣ ៥០០ គ្រួសារ) និងម៉ាស៊ីនប្រមូលផល

(៧១ ៦៩០ គ្រួសារ) ដែលបង្ហាញពីការជ្រើសរើសប្រើគ្រឿងម៉ាស៊ីនកសិកម្ម តាមតួនាទីជាក់លាក់សមស្រប នឹងភូមិសាស្ត្ររបស់តំបន់។ គ្រឿងម៉ាស៊ីនកសិកម្មក្រោយការប្រមូលផលនៅមានកម្រិតទូទាំងប្រទេស ដោយមានតែ ៤៤ ២៨០ គ្រួសារ ប្រើគ្រឿងម៉ាស៊ីនក្រោយប្រមូលផល ខណៈដែលឧបករណ៍ដែលប្រើដោយកម្លាំងសត្វមានចំនួន ៣៩ ៩០០ គ្រួសារ ភាគច្រើននៅតំបន់ដែលមិនទាន់មានគ្រឿងម៉ាស៊ីនកសិកម្មទូលំទូលាយដូចជា តំបន់ភ្នំនិងខ្ពង់រាប និងតំបន់ឆ្នេរសមុទ្រ។ លំនាំទាំងនេះបង្ហាញថា ទោះបីកម្ពុជាកំពុងមានការរីកចម្រើននៃគ្រឿងម៉ាស៊ីនកសិកម្មក៏ដោយក៏ភាពខុសគ្នាសំខាន់ៗក្នុងតំបន់នៅតែមាន ការអនុវត្តប្រពៃណីនៅតែជាផ្នែកសំខាន់នៃទិដ្ឋភាពកសិកម្ម។

រូបភាព៥.២ គ្រួសារកាន់កាប់កសិកម្មរាយការណ៍អំពីការប្រើប្រាស់ឧបករណ៍/គ្រឿងម៉ាស៊ីនកសិកម្មច្រើនបំផុតទាំង២០ ប្រទេសកម្ពុជា ឆ្នាំ២០២៤




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

ម៉ាស៊ីនបូមទឹក គឺជាឧបករណ៍ដែលមានការរាយការណ៍ប្រើប្រាស់ច្រើនបំផុត ដោយមានចំនួន ៦៣៨ ៥០០ គ្រួសារ កំពុងប្រើប្រាស់ ក្នុងនោះ ៩៨ភាគរយ ជាម្ចាស់ឧបករណ៍នេះ ដែលឆ្លុះបញ្ចាំងពីតួនាទីសំខាន់របស់វាក្នុងការស្រោចស្រព និងអត្រាកម្មសិទ្ធិខ្ពស់របស់អ្នកប្រើប្រាស់។ ដូចគ្នានេះដែរ ឧបករណ៍បាញ់ថ្នាំក៏ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយផងដែរ ដោយមានចំនួន ៦០៦ ៩៤០ គ្រួសារ (កម្មសិទ្ធិ ៩៣ភាគរយ) ប្រើម៉ាស៊ីនឧបករណ៍បាញ់ថ្នាំ និង ៤៩៣ ៩០០ គ្រួសារ (កម្មសិទ្ធិ ៩៨ភាគរយ) ប្រើឧបករណ៍បាញ់ថ្នាំដោយដៃដែលបង្ហាញពីអត្រាកាន់កាប់របស់អ្នកប្រើប្រាស់ទាំងនេះ។

គ្រឿងម៉ាស៊ីនកសិកម្ម អាចបញ្ជាក់ឱ្យច្បាស់ថា តាមរយៈការប្រើប្រាស់ម៉ាស៊ីនភ្ជួរដី ដែលមានចំនួន ៥៧០ ១៦០ គ្រួសារ ប្រើប្រាស់និងអត្រាកម្មសិទ្ធិ ៨៧ភាគរយ និងត្រាក់ទ័រកង់ពីរ ឬត្រាក់ទ័រដៃ (១២១ ៩០០ គ្រួសារ កម្មសិទ្ធិ ៥៨ភាគរយ)។ ទោះយ៉ាងណា ត្រាក់ទ័រកង់បួននៅតែមានការប្រើប្រាស់តិចជាងគេ (៧២ ៤០០ គ្រួសារ) ដោយមានតែ ៣១ភាគរយ នៃអ្នកប្រើប្រាស់គឺជាម្ចាស់កម្មសិទ្ធិ ដែលបង្ហាញពីការប្រើប្រាស់មានកម្រិត ដោយសារការចំណាយខ្ពស់ ឬការពឹងផ្អែកលើសេវាកម្មជួល។

ការប្រើប្រាស់ឧបករណ៍ម៉ាស៊ីនប្រមូលផលនៅតែមានកម្រិត ដែលត្រូវបានរាយការណ៍មានចំនួន ១៦១ ២៩០គ្រួសារ បានប្រើប្រាស់ ប៉ុន្តែមានម៉ាស៊ីនប្រមូលផលដែលជាកម្មសិទ្ធិផ្ទាល់ខ្លួនត្រឹមតែ ៦ភាគរយប៉ុណ្ណោះ នេះបង្ហាញថា ការជួលឧបករណ៍ម៉ាស៊ីនប្រមូលផលនៅតែជាមធ្យោបាយឈានមុខគេក្នុងការប្រើប្រាស់។ ដូចគ្នានេះដែរ ម៉ាស៊ីនបោកស្រូវត្រូវបានប្រើប្រាស់មានចំនួន ៣៩ ២៣០គ្រួសារ ប៉ុន្តែជាកម្មសិទ្ធិមានត្រឹមតែ ១៣ភាគរយ ប៉ុណ្ណោះ ជាការបញ្ជាក់បន្ថែមពីតួនាទីសំខាន់នៃផ្តល់សេវាក្នុងការប្រមូលផលដោយប្រើម៉ាស៊ីន។

ឧបករណ៍ខ្នាតតូចដូចជា ឧបករណ៍ស្រោចស្រពដោយដៃ (៤៤ ៤០០ គ្រួសារ កម្មសិទ្ធិ ៩៨ភាគរយ) នង្គ័ល (៥០ ៥៩០ គ្រួសារ កម្មសិទ្ធិ ៨៦ភាគរយ) និងរទេះសត្វ (១១ ៥០០ គ្រួសារ កម្មសិទ្ធិ ៩៩ភាគរយ) នៅតែមានការប្រើប្រាស់យ៉ាងទូលំទូលាយ ដែលបង្ហាញពីការពឹងផ្អែកលើឧបករណ៍ប្រពៃណីនៅក្នុងតំបន់ជាច្រើន។

ការប្រើប្រាស់បច្ចេកវិទ្យាក្នុងការគ្រប់គ្រងកសិដ្ឋានកំពុងកើនឡើង ដោយមានកសិដ្ឋានចំនួន ៥៩ ២៥០ គ្រួសារ រាយការណ៍ថាបានប្រើកុំព្យូទ័រ ថេប្លេត ឬស្មាតហ្វូន សម្រាប់គ្រប់គ្រងកសិដ្ឋាន ដែលសម្ភារទាំងអស់នេះជាកម្មសិទ្ធិរបស់ម្ចាស់កសិដ្ឋានផ្ទាល់ (១០០ភាគរយ)។ ដូចគ្នានេះផងដែរ បន្ទះស្រូបពន្លឺព្រះអាទិត្យ ដើម្បីផលិតអគ្គិសនី (៤០ ៨១០ គ្រួសារ កម្មសិទ្ធិ ៩៩ភាគរយ) និងឧបករណ៍ស្រោចស្រពដំណក់ទឹក (២៩ ៥០០ គ្រួសារ កម្មសិទ្ធិ ១០០ភាគរយ) ក៏បង្ហាញពីការប្រើប្រាស់បច្ចេកវិទ្យាទំនើបប្រកបដោយនិរន្តរភាព។

ផ្ទុយទៅវិញ ឧបករណ៍ឯកទេសដូចជា ម៉ាស៊ីនដាក់ជី (២៨ ៦៧០ គ្រួសារ កម្មសិទ្ធិ ៩៤ភាគរយ) ម៉ាស៊ីនប្រឡេសគ្រាប់ធញ្ញជាតិ (៥៧ ៥២០ គ្រួសារ កម្មសិទ្ធិ ៤០ភាគរយ) និងម៉ាស៊ីនរាស់ដី (២០ ៨១០ គ្រួសារ កម្មសិទ្ធិ ៦១ភាគរយ) នៅតែមានការប្រើប្រាស់មិនសូវទូលំទូលាយ ខណៈដែលឧបករណ៍កសិកម្មមានតម្រូវការពិសេសដូចជា ម៉ាស៊ីនកាត់ស្មៅ (១ ៩៤០ គ្រួសារ) និងប្រព័ន្ធបាញ់ទឹកស្រោចដំណាំ (១ ៩០០ គ្រួសារ កម្មសិទ្ធិ ១០០ភាគរយ) មានការប្រើប្រាស់តែមួយចំនួនប៉ុណ្ណោះ។

រូបភាព៥.៣ ភាគរយនៃកសិដ្ឋានដែលរាយការណ៍ពីភាពជាម្ចាស់នៃឧបករណ៍/គ្រឿងម៉ាស៊ីន ធៀបនឹងអ្នកប្រើប្រាស់ ឧបករណ៍ទាំង១០ ដែលមានភាគរយទាបបំផុតនៃម្ចាស់កសិដ្ឋាន កម្ពុជាឆ្នាំ២០២៤




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

## ភាពជាកម្មសិទ្ធិនៃប្រភេទឧបករណ៍កសិកម្មដែលបានប្រើប្រាស់

នៅក្នុងចំនួនគ្រួសារសរុប ១ ៨៦៨ ១៦០គ្រួសារ ដែលជាគ្រួសារកាន់កាប់កសិកម្មនៅកម្ពុជា ត្រូវបានប៉ាន់ប្រមាណថាមានគ្រួសារចំនួន ១ ៣១១ ២១០គ្រួសារ ដែលមានម្ចាស់កម្មសិទ្ធជាបុរស (៧០ភាគរយ) និង ៥៥៦ ៩៦០គ្រួសារ ដែលមានម្ចាស់កម្មសិទ្ធជាស្ត្រី (៣០ភាគរយ)។ ទោះជាយ៉ាងណា ក្នុងករណីភាគច្រើន ការប្រើប្រាស់ឧបករណ៍បរិក្ខានិងគ្រឿងម៉ាស៊ីនកសិកម្ម ត្រូវបានប្រើប្រាស់មិនសមាមាត្រក្នុងចំណោមគ្រួសារ ដែលមានម្ចាស់កម្មសិទ្ធជាបុរស បើប្រៀបធៀបនឹងគ្រួសារដែលមានម្ចាស់កម្មសិទ្ធជាស្ត្រី។ ករណីលើកលែង គឺជាឧបករណ៍ប្រើប្រាស់ដោយដៃ ដែលមានតម្លៃថោកជាង ងាយស្រួលប្រើប្រាស់ និងជាវិធីសាស្ត្រប្រពៃណី ដែលគ្រួសារដែលមានម្ចាស់កម្មសិទ្ធជាស្ត្រីមានសមភាពនឹងគ្រួសារម្ចាស់កម្មសិទ្ធជាបុរស ឬស្មើរតែមាន ចំនួនលើសគ្រួសារម្ចាស់កម្មសិទ្ធជាបុរសផងដែរ។ ឧទាហរណ៍៖ ឧបករណ៍ស្រោចស្រពដោយដៃ ឬឧបករណ៍ ស្រោចស្រពដោយដៃផ្សេងទៀត ត្រូវបានប្រើប្រាស់ក្នុងចំនួន ៤៤ ៤០០ គ្រួសារ ដែលក្នុងនោះ ៣៩ភាគរយ ជាគ្រួសារដែលមានម្ចាស់កម្មសិទ្ធជាស្ត្រី។ ចំណែកឧបករណ៍ដាក់គ្រាប់ពូជ / ជី ត្រូវបានប្រើប្រាស់ក្នុងចំនួន ១០៨ ៧០០ គ្រួសារ ដែលក្នុងនោះ ៣១ភាគរយ ជាគ្រួសារដែលមានម្ចាស់កម្មសិទ្ធជាស្ត្រី។

ប្រភេទគ្រឿងម៉ាស៊ីន ឬឧបករណ៍បរិក្ខាកសិកម្ម ដែលបានប្រើប្រាស់ច្រើនបំផុត គឺឧបករណ៍ម៉ាស៊ីន ស្រោចស្រព ដែលត្រូវបានប្រើប្រាស់មានចំនួន ៦៥៤ ៧០០គ្រួសារ ប្រហែល ៣៥ភាគរយ នៃគ្រួសារកាន់កាប់ កសិកម្មទាំងអស់។ ក្នុងចំណោមម្ចាស់កសិដ្ឋានដែលប្រើប្រាស់គ្រឿងម៉ាស៊ីនប្រភេទនេះ មានចំនួន ៥០៣ ៦០០ គ្រួសារ ដែលមានម្ចាស់កម្មសិទ្ធជាបុរស ខណៈដែលមានតែ ១៥១ ១០០ គ្រួសារ (២៣ភាគរយ)

ដែលមានម្ចាស់កម្មសិទ្ធជាស្ត្រី។ ក្នុងចំណោមឧបករណ៍ស្រោចទឹកទាំងនេះ ម៉ាស៊ីនបូមទឹក គឺជាឧបករណ៍ដែលត្រូវបានប្រើប្រាស់ច្រើនបំផុត ដោយមានចំនួន ៦៣៨ ៥០០ គ្រួសារ ប្រើប្រាស់ក្នុងចំណោមនេះមាន ១៤៥ ២០០ គ្រួសារ មានម្ចាស់កម្មសិទ្ធជាស្ត្រី (២៣ភាគរយ)។

ប្រភេទម៉ាស៊ីនឬឧបករណ៍ដែលត្រូវបានប្រើប្រាស់ច្រើនបំផុតទីពីរ គឺឧបករណ៍ម៉ាស៊ីនរៀបចំដី និងដាំដំណាំ ដែលមានចំនួន ៦២៩ ៤០០គ្រួសារ ប្រើប្រាស់ក្នុងចំណោមនេះមាន ១៤៩ ២០០គ្រួសារ ដែលមានម្ចាស់កម្មសិទ្ធជាស្ត្រី (២៤ភាគរយ)។ បន្ទាប់មក គឺឧបករណ៍ម៉ាស៊ីនថែទាំដំណាំ ដែលមានចំនួន ៦១១ ៥០០ គ្រួសារប្រើប្រាស់ ក្នុងចំណោមនេះមាន ១៣៦,៥០០ គ្រួសារ ដែលមានម្ចាស់កម្មសិទ្ធជាស្ត្រី (២២ភាគរយ)។

ឧបករណ៍កសិកម្មដែលដំណើរការដោយកម្លាំងសត្វដូចជា នង្គ័លដែក និង រទេះសត្វ ត្រូវបានប្រើប្រាស់ដោយ ៣៩ ៩០០គ្រួសារ ក្នុងចំណោមនេះមាន ៩ ៨០០គ្រួសារដែលមានម្ចាស់កម្មសិទ្ធជាស្ត្រី (២៥ភាគរយ)។ អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះ គឺឧបករណ៍មួយប្រភេទដែលមានវិសមភាពយេនឌ័រច្រើនជាងគេក្នុងការប្រើប្រាស់ គឺបន្ទះស្រូបពន្លឺព្រះអាទិត្យសម្រាប់ផលិតអគ្គិសនីមានចំនួន ៤០ ៨០០ គ្រួសារបានប្រើប្រាស់ ដែលក្នុងចំណោមនេះ ៣៤ ៦០០ គ្រួសារ (៨៥ភាគរយ) មានម្ចាស់កម្មសិទ្ធជាបុរស។ ករណីនេះបង្ហាញឱ្យឃើញពីឱកាសសម្រាប់ក្រុមហ៊ុនផ្គត់ផ្គង់ថាមពលពន្លឺព្រះអាទិត្យ (សូឡា) ដើម្បីកំណត់គោលដៅអ្នកប្រើប្រាស់បន្ថែមទៀត សម្រាប់ថាមពលកកើតឡើងវិញនេះ។

**តារាង៥.១ ប្រភេទឧបករណ៍ដែលបានប្រើប្រាស់តាមភេទម្ចាស់កម្មសិទ្ធគ្រួសារកម្ពុជា ឆ្នាំ២០២៤**

| ប្រភេទឧបករណ៍ | ចំនួនគ្រួសារដែលបានរាយការណ៍អំពីការប្រើប្រាស់គ្រឿងម៉ាស៊ីន ឬ ឧបករណ៍សម្ភារបរិក្ខាកសិកម្ម | ម្ចាស់កម្មសិទ្ធគ្រួសារ (ប្រុស) | ម្ចាស់កម្មសិទ្ធគ្រួសារ (ស្រី) |
|---|---|---|---|
| | | ចំនួនគ្រួសារ | |
| ឧបករណ៍ប្រើប្រាស់ដោយដៃ | ៥៩១ ៩០០ | ៤៤៥ ០០០ | ១៤៦ ៩០០ |
| ឧបករណ៍បាញ់ថ្នាំ | ៤៩៣ ៩០០ | ៣៧៩ ៧០០ | ១១៤ ២០០ |
| ឧបករណ៍ដាក់គ្រាប់ពូជ / ជី | ១០៨ ៧០០ | ៧៥ ១០០ | ៣៣ ៦០០ |
| ស្នប់ ឬឧបករណ៍ស្រោចស្រពដៃផ្សេងទៀត | ៤៤ ៤០០ | ២៦ ៩០០ | ១៧ ៤០០ |
| ឧបករណ៍រោយ | ៤ ២០០ | ៣ ៨០០ | |
| ឧបករណ៍បោក | ២ ៦០០ | ១ ៨០០ | |
| ឧបករណ៍ដំណើរការដោយកម្លាំងសត្វ | ៣៩ ៩០០ | ៣០ ១០០ | ៩ ៨០០ |
| នង្គ័លដែក | ១៧ ៥០០ | ១៣ ២០០ | ៤ ៣០០ |
| រទេះសត្វ | ១១ ៥០០ | ៩ ០០០ | ២ ៥០០ |
| ឧបករណ៍ដាក់គ្រាប់ពូជ / ជី | ៨ ៣០០ | ៦ ០០០ | |

| | | | |
|---|---|---|---|
| នង្គ័លឈើ | ៥ ៥០០ | ៤ ៣០០ | |
| ឧបករណ៍សម្អាតដី | ៣ ៦០០ | ២ ៩០០ | |
| ឧបករណ៍ម៉ាស៊ីនស្រោចស្រព | ៦៥៤ ៧០០ | ៥០៣ ៦០០ | ១៥១ ១០០ |
| ម៉ាស៊ីនបូមទឹក | ៦៣៨ ៥០០ | ៤៩៣ ៣០០ | ១៤៥ ២០០ |
| ឧបករណ៍ស្រោចស្រពជាដំណក់ទឹក | ២៩ ៥០០ | ២១ ១០០ | ៨ ៤០០ |
| ឧបករណ៍ស្រោចស្រពបាញ់ទឹក | ១ ៩០០ | | |
| គ្រឿងម៉ាស៊ីន និងឧបករណ៍បរិក្ខាកសិកម្មទូទៅ | ១០៩ ៨០០ | ៨២ ៩០០ | ២៦ ៩០០ |
| កុំព្យូទ័រ កុំព្យូទ័រយួរដៃ ថេបប្លេត ឬ ស្មាតហ្វូន សម្រាប់គ្រប់គ្រងកសិដ្ឋាន | ៥៩ ២០០ | ៤០ ៥០០ | ១៨ ៧០០ |
| បន្ទះសូឡាស្រូបពន្លឺព្រះអាទិត្យ (ការប្រើប្រាស់ណាមួយ) | ៤០ ៨០០ | ៣៤ ៦០០ | ៦ ២០០ |
| ម៉ាស៊ីនភ្លើងសម្រាប់ផលិតអគ្គិសនី | ៥ ២០០ | ៣ ៦០០ | |
| ត្រាក់ទ័រ ម៉ាស៊ីនឈូសឆាយ និងយានយន្តផ្សេងៗ | ៣០៤ ០០០ | ២៣៤ ៦០០ | ៦៩ ៥០០ |
| ត្រាក់ទ័រកង់ពីរ / ត្រាក់ទ័រដៃ | ១២១ ៩០០ | ៩២ ៣០០ | ២៩ ៦០០ |
| ត្រាក់ទ័រកង់បួន | ៧២ ៤០០ | ៥៥ ៥០០ | ១៦ ៩០០ |
| ទូក | ៥៥ ១០០ | ៤៣ ៧០០ | ១១ ៤០០ |
| រទេះសន្ទោង | ៤៨ ៤០០ | ៣៨ ៩០០ | ៩ ៤០០ |
| រថយន្តដឹកទំនិញ | ១៧ ៦០០ | ១៣ ៧០០ | ៣ ៩០០ |
| ឧបករណ៍ម៉ាស៊ីនរៀបចំដី និងដាំដំណាំ | ៦២៩ ៤០០ | ៤៨០ ២០០ | ១៤៩ ២០០ |
| ម៉ាស៊ីនភ្ជួរ | ៥៧០ ២០០ | ៤៣៦ ១០០ | ១៣៤ ១០០ |
| ម៉ាស៊ីនដាក់គ្រាប់ពូជ | ៥៧ ៥០០ | ៤២ ៦០០ | ១៤ ៩០០ |
| នង្គ័ល | ៥០ ៦០០ | ៣៩ ២០០ | ១១ ៤០០ |
| ឧបករណ៍សម្អាតដី | ២២ ៦០០ | ១៧ ០០០ | |
| ឧបករណ៍រាស់បំបែកដី | ២០ ៨០០ | ១៥ ៣០០ | ៥ ៥០០ |
| ឧបករណ៍ដាក់គ្រាប់ពូជ/ជី | ៨ ៥០០ | ៦ ៨០០ | |
| ឧបករណ៍ដាំដំណាំ | ៧ ៩០០ | ៧ ៣០០ | |
| ឧបករណ៍ម៉ាស៊ីនថែទាំដំណាំ | ៦១១ ៥០០ | ៤៧៤ ៩០០ | ១៣៦ ៥០០ |
| ឧបករណ៍បាញ់ថ្នាំ | ៦០៦ ៩០០ | ៤៧២ ៤០០ | ១៣៤ ៦០០ |
| ឧបករណ៍ដាក់ជី | ២៨ ៧០០ | ១៩ ៣០០ | ៩ ៤០០ |
| ឧបករណ៍ម៉ាស៊ីនប្រមូលផល | ៣០៧ ០០០ | ២៣៣ ៣០០ | ៧៣ ៦០០ |
| ឧបករណ៍ច្រូត | ១៦១ ៣០០ | ១១៣ ៦០០ | ៤៧ ៧០០ |
| ឧបករណ៍កាត់ស្មៅសម្រាប់ដំណាំស្មៅ | ១៤៦ ៣០០ | ១២០ ៤០០ | ២៥ ៨០០ |
| ឧបករណ៍វិចខ្ចប់ស្មៅ | ១ ៩០០ | ១ ៤០០ | |

| | | | |
|---|---|---|---|
| ឧបករណ៍ផ្លុំ | ១ ៤០០ | | |
| ឧបករណ៍ម៉ាស៊ីនក្រោយការប្រមូលផល | ៤៤ ៣០០ | ៣២ ២០០ | ១២ ១០០ |
| ឧបករណ៍បោក | ៣៩ ២០០ | ២៧ ៧០០ | ១១ ៥០០ |
| ឧបករណ៍សម្អាតគ្រាប់ធញ្ញជាតិ | ៥ ២០០ | ៤ ៧០០ | |
| ឧបករណ៍ម៉ាស៊ីនផលិតកម្មសត្វ | ១ ៧០០ | ១ ៣០០ | |
| ឧបករណ៍ភ្ញាស់ | ១ ៧០០ | ១ ៣០០ | |

*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

## បរិក្ខារជួសជុលគ្រឿងម៉ាស៊ីនកសិកម្ម

គ្រួសារកាន់កាប់កសិកម្មបានរាយការណ៍ថា មានចំនួន ៦៤៩ ០០០គ្រួសារ បានប្រើប្រាស់សេវាកម្មជួសជុលគ្រឿងម៉ាស៊ីនកសិកម្មនៅក្នុងតំបន់។ ក្នុងចំណោមនោះ គ្រួសារចំនួន ៤០៤ ០០០គ្រួសារ (ប្រហែល ៦២ភាគរយ) បានប្រើប្រាស់សេវាកម្មជួសជុលនេះ ខណៈដែល ២៤៥ ០០០ គ្រួសារ បាននិយាយថាពួកគេមិនបានប្រើប្រាស់សេវាកម្មនេះទេ។ មានមូលហេតុផ្សេងៗគ្នាដែលពួកគេមិនប្រើប្រាស់សេវាកម្មជួសជុលដោយសារ មិនមានគ្រឿងម៉ាស៊ីនកសិកម្មសម្រាប់ជួសជុល (១៦០ ០០០ គ្រួសារ) គ្រឿងម៉ាស៊ីនមិនមានបញ្ហាដែលត្រូវការជួសជុល (៥៦ ០០០ គ្រួសារ) មានចំណេះដឹងជួសជុលដោយខ្លួនឯង (២៦ ០០០ គ្រួសារ)។ ចំនួនភាគតិចប៉ុណ្ណោះ គឺ ៤ ០០០ គ្រួសារ បានរាយការណ៍ថា មិនប្រើប្រាស់សេវាកម្មជួសជុលដោយសារតម្លៃថ្លៃពេក។

រូបភាព៥.៤ ចំនួនគ្រួសារកសិកម្មដែលបានរាយការណ៍ពីការប្រើប្រាស់ និងមិនប្រើប្រាស់សេវាកម្មជួសជុលគ្រឿងម៉ាស៊ីនកសិកម្ម កម្ពុជាឆ្នាំ២០២៤




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

## កន្លែងរក្សាទុក

គ្រួសារកាន់កាប់កសិកម្មចំនួន ២២១ ០០០គ្រួសារបានរាយការណ៍ថា បានប្រើប្រាស់អគារ ឬ សំណង់មិនមែនលំនៅឋាន សម្រាប់រក្សាទុកផលដំណាំ។ គ្រួសារភាគច្រើន (២០៦ ០០០ គ្រួសារ ឬ ប្រហែល ៩៣ភាគរយ) បានប្រើអគារសម្រាប់រក្សាទុកដំណាំធញ្ញជាតិ (ធញ្ញជាតិ និង សណ្តែក)។ មានគ្រួសារប្រហែល ៦ ០០០ គ្រួសារ បានប្រើប្រាស់សំណង់សម្រាប់គោលបំណងចម្រុះ ខណៈដែល ៨ ០០០ គ្រួសារ ប្រើប្រាស់សំណង់សម្រាប់គោលបំណងផ្សេងៗ។ ក្នុងចំណោមគ្រួសារដែលប្រើសំណង់សម្រាប់រក្សាទុកផលដំណាំធញ្ញជាតិមាន ១៧៣ ០០០គ្រួសារ រក្សាទុកក្នុងឃ្លាំង ១២ ០០០គ្រួសារ រក្សាទុកក្នុងស៊ីឡូ ១០ ០០០ គ្រួសារ រក្សាទុកក្នុងទូរ ឬ ជង្រុក ១០ ០០០គ្រួសារ រក្សាទុកនៅលើដី និងចំនួន ៩ ០០០ គ្រួសារប្រើប្រាស់បន្ទប់ដើម្បីរក្សាទុក។

រូបភាព៩.៥ ចំនួនគ្រួសារកសិកម្មដែលរាយការណ៍ពីកន្លែងរក្សាទុកនៃប្រភេទដំណាំ កម្ពុជាឆ្នាំ២០២៤




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

រូបភាព៥.៦ ចំនួនគ្រួសារកសិករបានរាយការណ៍ពីការប្រើប្រាស់ប្រភេទឃ្លាំងសម្រាប់រក្សាទុកធញ្ញជាតិ និងសណ្តែក កម្ពុជាឆ្នាំ២០២៤




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

សំណង់ដែលបានប្រើសម្រាប់សកម្មភាពកែច្នៃដំណាំ ត្រូវបានប្រើប្រាស់ក្នុងវិធីផ្សេងៗគ្នា។ គ្រួសារកាន់កាប់កសិកម្មចំនួន ៤២ ០០០ គ្រួសារ បានប្រើអគារ ឬសំណង់សម្រាប់រក្សាទុកគ្រឿងម៉ាស៊ីន និងឧបករណ៍បរិក្ខារកសិកម្ម ដែលទាក់ទងនឹងដំណាំ ៣៣ ០០០គ្រួសារ បានប្រើប្រាស់សម្រាប់រក្សាទុកជី ៨ ០០០ គ្រួសារ បានប្រើសម្រាប់រក្សាទុកផលិតផលការពារដំណាំ និង ៥ ០០០ គ្រួសារ បានប្រើសម្រាប់កែច្នៃដំណាំ។

រូបភាព៥.៧. ចំនួនគ្រួសារកសិកម្មដែលប្រើប្រាស់អគារ ឬសំណង់ នៅកម្រិតថ្នាក់ជាតិ កម្ពុជាឆ្នាំ២០២៤




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

## អគារ ឬ សំណង់ដែលប្រើសម្រាប់បសុសត្វ ឬ បសុបក្សី

គ្រួសារកាន់កាប់កសិកម្មសរុប ៤៥៤ ០០០ គ្រួសារ មានអគារ ឬសំណង់សម្រាប់ចិញ្ចឹមបសុសត្វធំ ឬបសុសត្វតូច។ ក្នុងចំណោមនេះ ១៧៧ ០០០ គ្រួសារ ស្ថិតនៅតំបន់បឹងទន្លេសាប ១៧៣ ០០០ គ្រួសារ ស្ថិតនៅតំបន់វាលទំនាប ៦០ ០០០ គ្រួសារ ស្ថិតនៅតំបន់ភ្នំនិងខ្ពង់រាប និង ៤៣ ០០០ គ្រួសារ ស្ថិតនៅតំបន់ឆ្នេរសមុទ្រ។ ក្នុងចំណោមសំណង់ដែលប្រើសម្រាប់ចិញ្ចឹមបសុសត្វធំ ឬបសុសត្វតូចទាំងនេះ មានតែភាគតិចប៉ុណ្ណោះ (៤០ ០០០ គ្រួសារ ឬ ៩ភាគរយ នៃគ្រួសារចិញ្ចឹមបសុសត្វធំ ឬបសុសត្វតូចទាំងអស់) ក៏បានប្រើប្រាស់អគារ ឬសំណង់ដូចគ្នាជាផ្ទះសម្រាប់មនុស្សរស់នៅផងដែរ។ ចំនួននេះមានការប្រែប្រួលទៅតាមតំបន់ ដែលមាន ១៥ភាគរយ (៩,០០០ គ្រួសារ) នៅតំបន់ភ្នំនិងខ្ពង់រាប ៩ភាគរយ (៤ ០០០ គ្រួសារ) នៅតំបន់ឆ្នេរសមុទ្រ ៨ភាគរយ (១៤ ០០០ គ្រួសារ) នៅតំបន់បឹងទន្លេសាប និង ៧ភាគរយ (១៣,០០០ គ្រួសារ) នៅតំបន់វាលទំនាប។

គ្រួសារកាន់កាប់កសិកម្មសរុប ៥១៣ ០០០ គ្រួសារ មានអគារឬសំណង់សម្រាប់ចិញ្ចឹមបសុបក្សី។ ក្នុងចំណោមនេះមាន ២១៩ ០០០គ្រួសារ ស្ថិតនៅតំបន់បឹងទន្លេសាប ១៥៩ ០០០ គ្រួសារ ស្ថិតនៅតំបន់វាលទំនាប ៨៣ ០០០ គ្រួសារ ស្ថិតនៅតំបន់ភ្នំ និងខ្ពង់រាប ៥៣ ០០០ គ្រួសារស្ថិតនៅតំបន់ឆ្នេរសមុទ្រ។ ក្នុងចំណោមសំណង់ដែលប្រើសម្រាប់ចិញ្ចឹមបសុបក្សី មានតែភាគតិចប៉ុណ្ណោះ (៤៧ ០០០ គ្រួសារ ឬ ៩ ភាគរយ នៃគ្រួសារចិញ្ចឹមបសុបក្សី) ក៏បានប្រើប្រាស់អគារឬសំណង់ដូចគ្នាជាផ្ទះសម្រាប់មនុស្សរស់នៅផងដែរ។ ចំនួននេះ មានការប្រែប្រួលទៅតាមតំបន់ ដែលមាន ១៦ភាគរយ (១៣ ០០០ គ្រួសារ) នៅតំបន់ភ្នំនិងខ្ពង់រាប ១២ភាគរយ (៦ ០០០ គ្រួសារ) នៅតំបន់ឆ្នេរសមុទ្រ ៩ភាគរយ (១៤ ០០០ គ្រួសារ) នៅតំបន់វាលទំនាប និង ៧ភាគរយ (១៤ ០០០ គ្រួសារ) នៅតំបន់បឹងទន្លេសាប។

រូបភាព៥.៨ ចំនួនគ្រួសារកសិកម្មដែលប្រើប្រាស់អគារ ឬសំណង់ សម្រាប់ចិញ្ចឹមបសុសត្វ និងបសុបក្សី តាមតំបន់ ឆ្នាំ២០២៤




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

ចំនួនមធ្យមនៃអគារ ឬសំណង់ដែលប្រើសម្រាប់បសុសត្វនិង/ឬបសុបក្សី នៅតែមានភាពថេរនៅទូទាំងប្រទេស ដោយជាមធ្យមមាន ១,២ អាគារ សម្រាប់ទូទាំងប្រទេស និងមានតែតំបន់វាលទំនាបប៉ុណ្ណោះដែលមានមធ្យមភាគខុសគេគឺ ១,៣ អាគារ។

សរុបមានអាគារ ឬសំណង់មិនមែនលំនៅឋានចំនួន ៧៤ ០០០អគារ ដែលសម្រាប់រក្សាទុកដំណាំជាកម្មសិទ្ធិ ប៉ុន្តែមិនបានប្រើប្រាស់នៅទូទាំងប្រទេស។ ទាំងនេះភាគច្រើនស្ថិតនៅតំបន់វាលទំនាប មានចំនួន ៣២ ០០០ អគារ ដែលមិនបានប្រើប្រាស់ បន្តដោយតំបន់បឹងទន្លេសាបចំនួន ២២ ០០០ អគារ តំបន់ភ្នំនិងខ្ពង់រាបចំនួន ១៣ ០០០ អគារ និងតំបន់ឆ្នេរសមុទ្រមានសំណង់មិនប្រើប្រាស់ចំនួន ៨ ០០០ អគារ។

## សកម្មភាពសេដ្ឋកិច្ច

រូបភាព៥.៩ បង្ហាញពីចំនួនអ្នកធ្វើការឱ្យកសិដ្ឋានផ្សេងទៀតបែងចែកតាមតំបន់។ ទិន្នន័យបានបង្ហាញថាតំបន់បឹងទន្លេសាប មានចំនួនអ្នកធ្វើការឱ្យកសិដ្ឋានផ្សេងច្រើនជាងគេមាន ១០៨ ០០០ ដោយតំបន់វាលទំនាបមាន ៩៤ ០០០ តំបន់ភ្នំ និងខ្ពង់រាបមាន ៤២ ០០០។ ទោះជាយ៉ាងណាតំបន់ឆ្នេរសមុទ្រ មិនមានការបង្ហាញអំពីទិន្នន័យលម្អិតទេ ដោយសារការតបសម្ភាសន៍មិនមានទិន្នន័យស្ថិតិលម្អិត។

**រូបភាព៥.៩ ចំនួនគ្រួសារកសិកម្មដែលធ្វើការឱ្យគ្រួសារកសិកម្មដទៃទៀត នៅតាមតំបន់ឆ្នាំ២០២៤**




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*



*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិឆ្នាំ២០២៤ ការដាំដំណាំនៅជុំវិញលំនៅឋាន*

រូបទី៥.១០ បង្ហាញពីការចំណាយថ្លៃប្រេងឥន្ធនៈនៅអំឡុងរដូវប្រាំង និងរដូវវស្សា សម្រាប់សកម្មភាពកសិកម្មពេញមួយឆ្នាំ។ ការចំណាយច្រើនបំផុតគឺនៅតំបន់បឹងទន្លេសាប ដែលនៅរដូវប្រាំងប្រហែល ៥៣ដុល្លារ និងរដូវវស្សាប្រហែល ៤៨,៥០ ដុល្លារ។ ដោយនៅតំបន់ភ្នំ និងខ្ពង់រាប អំឡុងរដូវប្រាំងប្រហែល ៤១,២៥ ដុល្លារ និងអំឡុងរដូវវស្សាប្រហែល ៣៩,២៥ ដុល្លារ នៅតំបន់វាលទំនាបចំណាយនៅរដូវប្រាំងប្រហែល ៣១,៥០ដុល្លារ និងរដូវវស្សាប្រហែល ២១,៧៥ ដុល្លារ សម្រាប់តំបន់ឆ្នេរសមុទ្រមានការចំណាយសម្រាប់រដូវប្រាំងប្រហែល ២០,៧៥ ដុល្លារ រដូវវស្សាប្រហែល ១៥,២៥ ដុល្លារ។

**រូបភាព៥.១០ ការចំណាយលើប្រេងឥន្ទនៈអំឡុងរដូវប្រាំងនិងរដូវវស្សា គិតជាដុល្លារ តាមរដូវ និងតំបន់ ឆ្នាំ២០២៤**




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

រូបទី៥.១១ បង្ហាញថា គ្រួសារកាន់កាប់កសិកម្មមានប្រមាណ ៨១៨ ០០០ ធ្វើកសិកម្មជាចម្បងសម្រាប់លក់ និងគ្រួសារកាន់កាប់កសិកម្មប្រមាណ ៥១១ ០០០ ជាចម្បងសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ។ ដោយឡែកគ្រួសារកាន់កាប់កសិកម្មចំនួនប្រមាណ ៤៥៩ ០០០ ធ្វើកសិកម្មសម្រាប់តែក្នុងគ្រួសារ និង គ្រួសារកសិកម្មប្រមាណ ៨០ ០០០០ ផលិតទិន្នផលសម្រាប់តែលក់ ប៉ុណ្ណោះ។

**រូបភាព៥.១១ គោលបំណងចម្បងនៃផលិតកម្មកសិកម្មរបស់គ្រួសារកាន់កាប់កសិកម្ម នៅកម្ពុជា ឆ្នាំ២០២៤**




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

ចំនួនគ្រួសារកាន់កាប់កសិកម្មប្រមាណ ៧០៩ ០០០ បានរាយការណ៍ថា ប្រហែលពាក់កណ្តាលនៃគ្រួសារកាន់កាប់កសិកម្មទាំងនោះមានចំណូលមកពីសកម្មភាពកសិកម្ម (៤០-៥៩ ភាគរយ)។ មានតែគ្រួសារកសិកម្មប្រមាណ ៩៧ ០០០ បានរាយការណ៍ថា មានចំណូលសរុបពឹងផ្អែកតែលើទិន្នផល កសិកម្ម។ គ្រួសារកសិកម្មជាច្រើនប្រហែលបីដងគឺ ១៦៨ ០០០ បានរាយការណ៍ថា ប្រាក់ចំណូលរបស់គ្រួសារបានមកពីសកម្មភាពកសិកម្មមានតិចជាង ១០ ភាគរយ។

### រូបភាព៥.១២ ភាគរយនៃប្រាក់ចំណូលពីកសិកម្មរួមចំណែកដល់ប្រាក់ចំណូលសរុបរបស់គ្រួសារ នៅកម្ពុជា ឆ្នាំ២០២៤




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

រូបទី៥.១៣ បានបង្ហាញពីការចូលរួមរបស់គ្រួសារកាន់កាប់កសិកម្ម នៅក្នុងសមាគមកសិករក្រៅផ្លូវការ និងផ្លូវការ (បានចុះបញ្ជីជាមួយរដ្ឋាភិបាល)។ ទាំងសមាគមកសិករផ្លូវការ និងក្រៅផ្លូវការ គឺមានចំនួនច្រើនជាងគេនៅក្នុងតំបន់បឹងទន្លេសាប។

## រូបភាព៥.១៣ ការចូលរួមនៅក្នុងសមាគមកសិករផ្លូវការ ឬសមាគមកសិករក្រៅផ្លូវការ តាមតំបន់ ឆ្នាំ២០២៤




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

លទ្ធភាពទទួលបានហិរញ្ញប្បទានមានសារៈសំខាន់ណាស់ សម្រាប់គ្រួសារកាន់កាប់កសិកម្មខ្នាតតូច នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដោយសារមូលហេតុមួយចំនួនរួមមាន ការកែលម្អ ផលិតភាព ការគ្រប់គ្រងហានិភ័យ ការដំណើរការទៅកាន់ទីផ្សារ ការរៀបចំខ្លួនចំពោះគ្រោះមហន្តរាយ និងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម។

នៅតំបន់បឹងទន្លេសាប មានគ្រួសារកាន់កាប់កសិកម្មចំនួន ២៥៩ ០០០ គ្រួសារ បានរាយការណ៍ថា មានកម្ចីឥណទានយ៉ាងហោចណាស់មួយ បន្ទាប់មកតំបន់វាលទំនាបមាន ២៥៧ ០០០ គ្រួសារ តំបន់ភ្នំនិងខ្ពង់រាបមាន ១៤២ ០០០ គ្រួសារ និងតំបន់ឆ្នេរសមុទ្រមាន ៤១ ០០០ គ្រួសារ។

**រូបភាព៥.១៤ ចំនួនគ្រួសារកសិកម្មដែលបានរាយការណ៍ថាមានសមាជិកយ៉ាងតិចម្នាក់ដែលមានកម្ចីឥណទាន តាមតំបន់ ឆ្នាំ២០២៤**




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

គ្រួសារកាន់កាប់កសិកម្មប្រហែល ៦១ភាគរយ បានប្រើប្រាស់ប្រាក់កម្ចីរបស់ពួកគេសម្រាប់គោលបំណងកសិកម្ម។ នៅតំបន់បឹងទន្លេសាប គ្រួសារកាន់កាប់កសិកម្មដែលបានរាយការណ៍ថាប្រើប្រាស់ប្រាក់កម្ចីរបស់ពួកគេមួយផ្នែកសម្រាប់គោលបំណងកសិកម្មមាន ១៨៤ ០០០ គ្រួសារ បន្ទាប់មកគឺតំបន់វាលទំនាបមាន ១៣៧ ០០០ គ្រួសារ តំបន់ភ្នំនិងខ្ពង់រាបមាន ៨៨ ០០០ គ្រួសារ និង តំបន់ឆ្នេរសមុទ្រមាន ១៧ ០០០ គ្រួសារ។

**រូបភាព៥.១៥ ចំនួនគ្រួសារកសិកម្មដែលរាយការណ៍ថាបានប្រើប្រាស់កម្ចីឥណទានមួយចំនួនសម្រាប់គោលបំណងកសិកម្ម តាមតំបន់ ឆ្នាំ២០២៤**




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

ប្រាក់កម្ចីច្រើនបំផុតត្រូវបានខ្ចីតាមរយៈស្ថាប័នមីក្រូហិរញ្ញវត្ថុ។ ជាសរុបគ្រួសារកាន់កាប់កសិកម្មមានចំនួនប្រមាណ ៣៣៦ ០០០ គ្រួសារ បានរាយការណ៍ថា បានប្រើប្រាស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សម្រាប់ប្រាក់កម្ចី យ៉ាងហោចណាស់មួយកម្ចី ចំនួនប្រើប្រាស់ច្រើនលំដាប់ទីពីរ គឺធនាគារ មានប្រមាណ ២៩១ ០០០ គ្រួសារ។ ក្រៅពីស្ថាប័នមីក្រូហិរញ្ញវត្ថុ និងធនាគារ មានប្រភពផ្តល់ប្រាក់កម្ចីក្រៅផ្លូវការដូចជា សាច់ញាតិ អ្នកចងការប្រាក់ មិត្តភក្តិ/អ្នកជិតខាង ក៏ត្រូវបានរាយការណ៍ផងដែរ។

**រូបភាព៥.១៦ ចំនួនគ្រួសារកសិកម្មដែលរាយការណ៍ថាមានសមាជិកគ្រួសារយ៉ាងតិចម្នាក់ដែលមានកម្ចីឥណទាន តាមប្រភពកម្ចីឥណទាន ឆ្នាំ២០២៤**




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

## គ្រោះហានិភ័យ

គ្រោះហានិភ័យក្នុងវិស័យកសិកម្មសំដៅទៅលើព្រឹត្តិការណ៍កើតមានឡើង ដែលមិនបានគិតទុកជាមុន ហើយប៉ះពាល់យ៉ាងខ្លាំងដល់ផលិតកម្ម ឬទីផ្សារកសិកម្ម។ នោះអាចអាស្រ័យលើកត្តាធម្មជាតិដូចជា គ្រោះរាំងស្ងួត ទឹកជំនន់ សត្វល្អិតចង្រៃបំផ្លាញ ឬ ជម្ងឺដែលអាចនាំឱ្យដំណាំខូច ប៉ុន្តែពួកវាក៏អាចបង្កើតដោយមនុស្សផងដែរដូចជា ការផ្លាស់ប្តូរគោលនយោបាយរដ្ឋាភិបាល ការរឹតបន្តឹងពាណិជ្ជកម្ម ឬ ជម្លោះដែលរំខានដល់ខ្សែសង្វាក់ផ្គត់ផ្គង់។ គ្រោះហានិភ័យទាំងនេះអាចជះឥទ្ធិពលយ៉ាងខ្លាំងដល់វិស័យកសិកម្ម និងសេដ្ឋកិច្ចកាន់តែធ្ងន់ធ្ងរ។ បញ្ហាទាំងនេះហើយដែលអាចនាំឱ្យមានការកើនឡើងតម្លៃស្បៀង កាត់បន្ថយប្រាក់ចំណូលកសិករ និងការកើនឡើងនៃភាពក្រីក្រ និងអសន្តិសុខស្បៀងក្នុងចំណោមប្រជាជនដែលងាយរងគ្រោះ។

នៅក្នុងអង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤ នៅតំបន់បឹងទន្លេសាបមានគ្រួសារកាន់កាប់កសិកម្មច្រើនជាងគេដែលរាយការណ៍ថា បានជួបគ្រោះហានិភ័យស្ទើរពេញមួយឆ្នាំ (២៥៤ ០០០ គ្រួសារ)។ តំបន់ឆ្នេរសមុទ្រមានចំនួនគ្រួសារកាន់កាប់កសិកម្មទាបជាងគេ (១៥ ០០០ គ្រួសារ) បានរាយការណ៍អំពីការជួបគ្រោះហានិភ័យ។

## រូបភាព៥.១៧ ចំនួនគ្រួសារកសិកម្មដែលរាយការណ៍ថាជួបគ្រោះហានិភ័យ តាមតំបន់ ឆ្នាំ២០២៤




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

យោងទៅតាមគ្រោះហានិភ័យធ្ងន់ធ្ងរនៃគ្រួសារកសិកម្មដែលបានជួបប្រទះភាគច្រើន គឺគ្រោះរាំងស្ងួត ដែលប៉ះពាល់ដល់គ្រួសារកសិកម្មប្រមាណ ២៩៥ ០០០ គ្រួសារ ក្នុងឆ្នាំ២០២៤។ គ្រោះហានិភ័យធំទីពីរគឺ សត្វល្អិតចង្រៃ ដែលមានគ្រួសារកសិកម្មប្រមាណ ១១៧ ០០០ គ្រួសារ បានរាយការណ៍ថា បានជះឥទ្ធិពល យ៉ាងខ្លាំងទៅលើគ្រួសារកសិកម្មក្នុងរយៈពេលយោង។ ទីបី គឺទឹកជំនន់ ត្រូវបានបញ្ជាក់ថា រងគ្រោះហានិភ័យ ធ្ងន់ធ្ងរទៅលើគ្រួសារកាន់កាប់កសិកម្មសរុបប្រមាណ ៩៦ ០០០ គ្រួសារ។

**រូបភាព៥.១៨ ចំនួនគ្រួសារកសិកម្មដែលរាយការណ៍ថាបានទទួលរងគ្រោះហានិភ័យ តាមប្រភេទគ្រោះហានិភ័យ ប្រទេសកម្ពុជា ឆ្នាំ២០២៤**




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*




ផែនទី ៤.៤៖ គ្រួសារប្រកបរបរកសិកម្មរាយការណ៍ថាគ្រោះរាំងស្ងួតជាគ្រោះមហន្តរាយ គិតជាភាគរយ បែងចែកតាមខេត្ត៖ ២០២៤

*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

នៅឆ្នាំ២០២៤ គ្រួសារកាន់កាប់កសិកម្មដែលបានទប់ទល់នឹងការរងគ្រោះហា និភ័យ មានភាពខុសគ្នាខ្លាំងទៅតាមតំបន់នីមួយៗ។ តំបន់បឹងទន្លេសាប បានបង្ហាញពីភាពងាយរងគ្រោះខ្ពស់បំផុត ដោយមានគ្រួសារចំនួន ១៦៥ ០០០គ្រួសារ មិនទាន់មានភាពប្រសើរឡើងវិញបានពេញលេញ និងមាន ២០២ ០០០ គ្រួសារ មិនមានសមត្ថភាពទប់ទល់បានល្អទេ។ ផ្ទុយទៅវិញ តំបន់វាលទំនាបបង្ហាញពីលទ្ធផលមានតុល្យភាពជាង ខណៈដែលតំបន់ឆ្នេរសមុទ្រ ក៏បានរាយការណ៍ពីសមត្ថភាព ស្តារឡើងវិញ និងការទប់ទល់មានភាពខ្លាំងជាងមុន ទោះបីជាមានប្រជាជនតិចជាងក៏ដោយ ។ តំបន់ភ្នំនិងខ្ពង់រាប បានបង្ហាញពីភាពដែលអាចទប់ទល់បានជាមធ្យម ដោយសមាមាត្រស្មើរស្មើគ្នានៃគ្រួសាររាយការណ៍ពីការស្តារឡើងវិញ និងបង្កើនសមត្ថភាពទប់ទល់នឹងគ្រោះហានិភ័យ។

**រូបភាព៥.១៩ ចំនួនគ្រួសារកសិកម្មដែលបានស្តារឡើងវិញពីគ្រោះហានិភ័យ តាមតំបន់ ឆ្នាំ២០២៤**




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*

ការឆ្លើយតបរបស់គ្រួសារកាន់កាប់កសិកម្ម ដែលទទួលរងគ្រោះមហន្តរាយធ្ងន់ធ្ងរតាមតំបន់នីមួយៗ។ តំបន់ទន្លេសាបបានរាយការណ៍ថា មានចំនួនគ្រួសារកាន់កាប់កសិកម្មដែលការទទួលរងគ្រោះច្រើនជាងគេ ដោយមាន ២០២ ០០០ គ្រួសារ ជាគ្រួសារកាន់កាប់កសិកម្មដែលជ្រើសរើសមិនធ្វើសកម្មភាពណាមួយ បើប្រៀបធៀបនឹង ៥៣ ០០០ គ្រួសារ ជាគ្រួសារកាន់កាប់កសិកម្មដែលបានលក់ដី និង/ឬ អគារ។ សម្រាប់តំបន់វាលទំនាប មានគ្រួសារកាន់កាប់កសិកម្មប្រហែលគ្នាដោយ ៨៤ ០០០ គ្រួសារ មិនបានធ្វើសកម្មភាពអ្វី និង ៨៣ ០០០ គ្រួសារ បានលក់ទ្រព្យសម្បត្តិ។ តំបន់ភ្នំនិងខ្ពង់រាប បានបង្ហាញពីភាពស្មើគ្នាផ្សេងទៀត ដោយមាន ៤៣ ០០០ គ្រួសារ ជ្រើសរើសទាំងពីរជម្រើស គឺលក់ទ្រព្យសម្បត្តិ ឬ មិនធ្វើអ្វីសោះ។ តំបន់ឆ្នេរសមុទ្រមានចំនួនទាបជាងគេ ដោយមានត្រឹមតែ ៦ ០០០ គ្រួសារ មិនបានចាត់វិធានការធ្វើអ្វីទេ និង ៩ ០០០ គ្រួសារ បានលក់ដី និង/ឬអគារ។

**រូបភាព៥.២០ ចំនួនគ្រួសារកសិកម្មដែលបានរាយការណ៍មធ្យោបាយចម្បង ដើម្បីទប់ទល់នឹងគ្រោះហានិភ័យ តាមតំបន់ ឆ្នាំ២០២៤**




*ប្រភព: អង្កេតកសិកម្មកម្ពុជាឆ្នាំ២០២៤*